# ធម្មទេសនា ៨ យ៉ាង



រៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **មិញ សាវ៉ាន**

**ព.ស. ២៥៥៦ - គ.ស. ២០១២**

**សម្រាប់ចែកជាធម្មទាន**

# ធម្មុទ្ទេស ៤ យ៉ាង

រៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **មុិញ សាវ៉ាន**

វាយពុម្ពអក្សរនិងចាត់ចែងជាសៀវភៅដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ **វ៉ាត តិរក្ស**

**ព.ស. ២៥៥៦ - គ.ស. ២០១២**

**ក្រុងម៉ុងរេអាល - កេបិក - កាណាដា**



**សម្រាប់ចែកជាធម្មទាន**

# សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្ដេចព្រះមហាសុមេធាធិបតី **ជួន ណាត**
២. ធម៌នមស្ការព្រះរតនត្រ័យ  ពិស្ដារ - សង្ខេប
៣. ប្រស្នា គិហិប្រតិបត្តិពិស្ដារ ( ឈឹម  ទូច, សុង  ស៊ីវ )
៤. ប្រជុំនានាធម៌សង្ខេគ ( ជ័យ  ម៉ៃ )
៥. អានាបានស្សតិកម្មដ្ឋាន  វិបស្សនាបញ្ហាធម្មបរិយាយ ( គង់  ឌឹប )
៦. ធម្មនិយាម ៣០  និងកំណាព្យផ្សេង ៗ ( ប៊ុត  សាវង្ស, ភិក្ខុ សាន  សុជា )
៧. ជីវិតកថា  ( ម៉ិញ  សាវ៉ាន ) ថ្មី
៨. ធម្មប្រទីប ( ប្រជុំកងធម៌  យិន  វន់ )
៩. រឿង  ព្រះភិក្ខុពនេចរ  ( ឱម  ណាគ្រី )
១០. រឿង  នគរកាយ ( ចាប  ពិន )
១១. ច្បាប់គោរពមាតាបិតា ( អ៊ូ  ចុង )
១២. ត្រៃកូដធម៌  ( សុង  ស៊ីវ )
១៣. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម  អ៊ុម  ស៊ុម )
១៤. ឱវាទបាតិមោក្ខ ( ចាប  ពិន )
១៥. កម្រងកំណាព្យ ( ហ៊ិម  ឆាន់ ) ថ្មី
១៦. ឧបនីយតិសូត្រ ( ព្រះមហាវិរិយបណ្ឌិតោ ប៉ាង  ខាត់ )



# យើងខ្ញុំ

*សូមឧទ្ទិសនូវស្នាដៃនេះជូនចំពោះ*

*ឧបាសិកា* **សិម ចាន់ធូរ៉ា** . . .

*ម. សារ៉ាន / វ. ភិរក្ស*



# មាតិកាអត្ថបទ


១. អារម្ភកថា .................... ទំព័រ

២. រតនប្បណាម .................... ១៣

៣. រដ្ឋបាលសូត្រ ទីពីរ .................... ១៥

៤. រដ្ឋបាលលាមាតាបិតាចេញបួស .................... ១៩

៥. ព្រះរដ្ឋបាលត្ថេរ ត្រឡប់មកជួបមាតាបិតាវិញ .................... ២៣

៦. សេចក្តីសាបសូន្យ ៤ យ៉ាង .................... ២៩

៧. ធម្មុទ្ទេស ៤ ប្រការ .................... ៣៣

៨. អត្ថន័យនៃធម្មុទ្ទេស .................... ៣៥

៩. សំណួរ - ចម្លើយ .................... ៤៣

១០. អធិប្បាយបញ្ជាក់ ( បន្ថែមដោយកម្រងកំណាព្យ ) .................... ៦៣

១២. ព្រះបាទ មន្ធាតុ .................... ៨៩

១៣. អវសានកថា .................... ៩៥

១៤. កម្រងកំណាព្យ .................... ១០៣

១៥. សមាសភាពចូលរួម .................... ១១០

# អារម្ភកថា

**កាល**វេលា ជាខ្នាត ជារង្វាស់សម្រាប់អាយុសត្វលោក ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះបរមសាស្តាសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់បំភ្លឺ សត្វលោកឲ្យយល់ច្បាស់ ចូលចិត្តអំពីសភាវពិតរបស់ជីវិត ។

ពាក្យថាកាលវេលា ជាខ្នាត ជារង្វាស់បានន័យថា សត្វលោកយកកាលវេលាដែលកន្លងទៅ គ្រប់ខណៈ វិនាទី នាទី ម៉ោង ថ្ងៃ ខែ ឆ្នាំ មកធ្វើជាខ្នាតសម្រាប់វាស់ ប្រៀបធៀបជាមួយអាយុជីវិត ដោយបូកយករាប់ការកើនចម្រើនឡើង ដូចជាកាលវេលាកន្លងទៅបាន ១ ឆ្នាំ, ១០ ឆ្នាំ, ២០ ឆ្នាំ, ៤០ ឆ្នាំ ឬ ៧០ ឆ្នាំដូច្នេះជាដើម ក៏នាំគ្នារាប់ថា អាយុគឺការរស់នៅរបស់ខ្ញុំបាន ១ ឆ្នាំ, ១០ ឆ្នាំ, ២០ ឆ្នាំ, ៤០ ឆ្នាំ ឬ ៧០ ឆ្នាំហើយ យ៉ាងនេះជាដើម ទើបនាំគ្នាត្រេកអរសាទរ រីករាយសប្បាយធ្វើបុណ្យកំណើត បុណ្យចម្រើនជន្មាយុទៅតាមចំណង់ចំណូលចិត្តតែរៀង ៗ ខ្លួន ។

ក៏ប៉ុន្តែទន្ទឹមគ្នានឹងការយល់ឃើញថា ជាការចម្រើនកើនឡើងនៃអាយុជីវិតនោះ ក៏មិនខុសគ្នាពីការកំពុងតែសូន្យសោះអស់ទៅ ឬថាដំណើរជីវិតនេះ កំពុងតែរំកិលចូលជិតខិតទៅរក ចុងបញ្ចប់គឺសេចក្តីស្លាប់នោះឯង ។

( កាលវេលាទំពារស៊ី អាយុជីវិតសត្វលោក ) ព្រះពុទ្ធដីកាព្រះអង្គទ្រង់ត្រាស់បញ្ជាក់ថា ៖

## ខយវយ ធម្មសង្ខារ

## សង្ខារទាំងឡាយ មានការអស់ទៅ និងសូន្យទៅជាធម្មតា ។

ឧទាហរណ៍ មនុស្សម្នាក់គាត់មានអាយុរស់នៅ បានកំណត់តែ ៥០ ឆ្នាំ បើកាលវេលាកន្លងទៅបានម្ភៃឆ្នាំហើយ បានន័យថា អាយុជីវិតគឺកាលវេលានៃការរស់នៅរបស់គាត់ ត្រូវបាននៅសល់តែសាមសិបឆ្នាំទៀតប៉ុណ្ណោះឯង ។ អាយុគាត់សូន្យសោះអស់ទៅម្ភៃឆ្នាំហើយ ដំណើរជីវិតប្រព្រឹត្តទៅកាន់តែចូលជិតខិតទៅរកការបញ្ចប់ និងការអស់ទៅហើយ ។

ត្រង់ចំណុចនេះ ដែលបានបញ្ជាក់ឲ្យឃើញ និងចូលចិត្តយល់កាន់តែបានច្បាស់អំពីសេចក្តីពិតរបស់ជីវិត ។ សត្វលោករស់នៅក្នុងរង្វង់នៃសេចក្តីវិនាសបាត់បង់សូន្យសោះអស់ទៅ ឥតមានអ្វីឲ្យតាំងនៅតាមសភាពដើមឡើយ សត្វលោកគ្មានអំណាចអាចនឹងការពារ ហួងហែងប្រកាន់ចំពោះជីវិតឲ្យឋិតនៅតាមគោលបំណងប៉ងប្រាថ្នារបស់ខ្លួនក៏ទេដែរ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ បានដកស្រង់ព្រះពុទ្ធដីកាដែលព្រះអង្គទ្រង់ត្រាស់សម្តែងអំពី **ធម្មទ្ទេស ៤ ប្រការ** [១] មករៀបរៀងជាសៀវភៅដើម្បីឲ្យងាយស្រួលដល់លោក-អ្នកអាន ព្រមទាំងបានជាបញ្ញាសម្រាប់ពិចារណា តាមសេចក្តីពិតនៃជីវិត ដើម្បីបន្ទោបង់នូវភាពងងឹត វង្វេងភ្លាំងភ្លេចស្មារតី សញ្ជឹងសញ្ជប់ជ្រប់ជ្រុលងងុលងប់ជាប់ជំពាក់ធ្លាក់ក្នុងភាពស្រវឹងនឹងជីវិតវ័យ រហូតដល់មានក្តីប្រមាទ

---

( ១ ). បិដកលេខ ២៤ **មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ បញ្ចមភាគ រដ្ឋបាលសូត្រទី ២** ទំព័រ ២៦៨ ។

ជាហេតុនាំឲ្យខាតបង់ ការរៀបចំដំណើរជីវិតដែលកំពុងតែប្រព្រឹត្តទៅ កាន់តែខិតជិតចូលទៅរកសេចក្តីស្លាប់ គ្រប់តែខណៈនោះឡើយ ។

សេចក្តីបរិយាយក្នុង **ធម្មទេសន ៤ ប្រការ** ព្រះអរហន្តសម្មា - សម្ពុទ្ធ ព្រះអង្គទ្រង់សម្តែងបញ្ជាក់ ឆ្លុះបញ្ចាំងឲ្យឃើញពីដំណើរជីវិតយ៉ាងពិតប្រាកដដែលមានប្រចាំក្នុងលោក កាលបើបានស្តាប់ហើយក៏រមែងធ្វើឲ្យឆាប់យល់ ចូលចិត្តបានងាយ និងជាតម្រាយបង្ហាញគោលខប្រតិបត្តិកំចាត់បង់សេចក្តីក្តៅក្រហាយ ក្រវល់ក្រវាយ សោកសៅតក់ស្លុតរន្ធត់ចិត្ត ក្នុងកាលដែលជីវិតត្រូវជួបប្រទះភ័យវិបត្តិណាមួយដែលនឹងមានមកដល់ ។

យើងខ្ញុំព្រះករុណា ខ្ញុំបាទ សូមលំឱនកាយថ្វាយបង្គំ ចំពោះព្រះករុណាម្ចាស់ ព្រមទាំងលោក-អ្នក ជាប្រាជ្ញបណ្ឌិតព្រឹទ្ធាចារ្យកវីនិពន្ធគ្រប់ជាន់ថ្នាក់ ព្រមទាំងលោក-អ្នកអានទាំងឡាយ ដែលជាអ្នកយល់ច្បាស់ពិតប្រាកដ ក្នុងអត្ថវិន័យធម៌ បាលី សូមមេត្តាខន្តីអភ័យទោសរាល់កំហុសឆ្គង មិនស្របទំនងដោយអក្ខរៈ ព្យញ្ជនៈ វគ្គឃ្លា បាលីសេចក្តីអធិប្បាយប្រការណា សូមព្រះករុណាម្ចាស់អស់លោកមេត្តាជួយជួសជុល កែតម្រូវដើម្បីឲ្យបានជាគុណប្រ-យោជន៍ក្នុងព្រះពុទ្ធសាសនាអស់កាលជាអង្វែងទៅហោង ។

ដោយវីរិយចិត្តចេតនា ជ្រះថ្លា នៃយើងខ្ញុំព្រះករុណាទាំងអស់គ្នា ក្នុងការព្យាយាមបោះពុម្ពជាសៀវភៅនេះឡើង ដើម្បីប្រគេនជូនជាធម្មទាន យើងខ្ញុំព្រះករុណា ខ្ញុំបាទ សូមលើកយកផលានិសង្សដែលកើតចេញបានពីធម្មទាន និងអាមិសទាននេះ ឧទ្ទិសប្រគេនជូន ថ្វាយ ចំពោះបុព្វការីជនទាំងឡាយមាន មាតាបិតា គ្រូឧបជ្ឈា-

យាចារ្យ បងប្អូនញាតិមិត្រសាច់សាលោហិត លោកអ្នកប្រាជ្ញរាជបណ្ឌិត ព្រមទាំងសត្តនិករ ដែលបានបែកធ្លាយរំលាយខន្ធ ទៅកាន់បរលោកហើយ សូមឲ្យលោកអ្នកដ៏មានគុណទាំងនោះ ព្រមទាំងសត្តនិករទាំងអស់ មានដំណើរជីវិតប្រព្រឹត្តទៅកាន់សុគតិភព និងសូមឲ្យបានឆ្លងផុតអន្លង់ទុក្ខក្នុងសង្សារវដ្តនេះ សមតាមសេចក្តីប្រាថ្នារបស់លោកអ្នកដ៏មានគុណទាំងឡាយនោះ កុំបីឃ្លាតក្លាយទៅជាបការៈដទៃទេសោះឡើយ ។

ម្យ៉ាងវិញទៀត ដោយតេជៈនៃព្រះធម្មា ជាព្រះពុទ្ធដីការបស់ព្រះសាស្តាសម្មាសម្ពុទ្ធ សូមឲ្យសព្វសត្វលោកបានជ្រកកោនក្រោមម្លប់ និងបានក្រេបជញ្ជក់នូវរសជាតិព្រះធម៌ គឺការបដិបត្តិដើម្បីឆ្លងកាត់បំបាត់បង់នូវអន្លង់ទុក្ខទាំងបួនប្រការ ធ្វើដំណើរតាមធម្មមាគ៌ាយាត្រាឆ្ពោះទៅរកអមតស្ថាន គឺព្រះនិព្វានជាឋានក្សេមផុតចាកចំណងចំណីមច្ចុមារតាមចេតនាឧបនិស្ស័យរៀង ៗ ខ្លួនទៅហោង ។

**សូមអនុមោទនា** . . . ! ! !

សរសេរចប់នៅក្រុងម៉ុងរេអាល, ថ្ងៃ ៤ ៀ ៩ ឆ្នាំថោះ ត្រីស័ក ព.ស. ២៥៥៥[១] ត្រូវនឹងថ្ងៃពុធទី៦ ខែកក្កដា គ.ស. ២០១១

**ម៉ិញ សាវ៉ាន**

**វ៉ាត តិរក្ស**

(១) អានថា ថ្ងៃពុធ ៦កើត ខែអាសាឍ ឆ្នាំថោះត្រីស័ក ព.ស. ២៥៥៥

# ពុទ្ធភាសិត

**យថាបិ កុម្ភការស្ស   កតំ មត្តិកភាជនំ**
**ខុទ្ទកញ្ច មហន្តញ្ច   យញ្ច បក្កំ យញ្ច អាមកំ**
**សព្វំ ភេទបរិយន្តំ   ឯវំ មច្ចាន ជីវិតំ ។**

**ភាជន៍ដីដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ ។**

## អត្តភាពគឺរាងកាយ រមែងតែបែកធ្លាយទៅ

( បទពាក្យប្រាំបី )

ភាជន៍ដីដែលនាយស្មូនឆ្នាំងធ្វើហើយ
បិតមិនយូរឡើយតែងបែកធ្លាយទៅ
តូចធំឆៅឆ្អិនមិនបានតាំងនៅ
រមែងតែងត្រូវវិនាសយ៉ាងណា ។
រីឯរូបកាយជីវិតសព្វសត្វ
តែងជួបវិបត្តិនៅក្នុងលោកា
ទោះកើតផ្សេងគ្នាភពឋានទីណា
មច្ចុរាជប្រហារគេចមិនរួចឡើយ ។

## រូបកាយពិតសូន្យអស់ តែកេរ្តិ៍ឈ្មោះពិតគង់នៅ

( បទព្រហ្មគីតិ )

រស់នៅត្រឹមមួយថ្ងៃ មានតម្លៃសាងគុណធម៌
កេរ្តិ៍ឈ្មោះពីរោះល្អ ទុកបន្តដល់ញាតិមិត្ត ។
រាងកាយបែកធ្លាយទៅ គុណធម៌នៅតំណាងពិត
ដិតជាប់ក្នុងដួងចិត្ត ជនឆ្ងាយជិតគិតបូជា ។

## ជីវិតនៅរស់ តែឈ្មោះដូចស្លាប់

( បទព្រហ្មគីតិ )

រស់នៅមួយរយឆ្នាំ សាងតែកម្មឥតបានការ
អំពើបាបពាលា ជនគ្រប់គ្នាខ្លាចរអា ។
រស់ហ្នឹងឈ្មោះឥតន័យ ជនប្រុសស្រីគេស្តីថា
ស្លាប់ទៅបង់អាសា គ្មានជនណាគេនឹករក ។

* ដោយឧបាសក **ម៉ិញ សាវ៉ាន**

# រតនប្បណាម

## នមត្ថុ រតនត្តយស្ស

ខ្ញុំព្រះករុណា សូមលើកកំបង់អញ្ជលី ថ្វាយបង្គំចំពោះប្រជុំបីនៃព្រះត្រៃរតន៍គឺ ព្រះពុទ្ធរតនៈ ១, ព្រះធម្មរតនៈ ១, ព្រះសង្ឃរតនៈ ១ ដោយសេចក្តីគោរព ។

ខ្ញុំសូមឱនសិរសា លើកហត្ថាថ្វាយវន្ទា
ចំពោះព្រះពុទ្ធា ជាសាស្តានៃសព្វសត្វ ។
សូមថ្វាយបង្គំផ្ទង់ អង្គព្រះធម៌ផ្លូវប្រតិបត្តិ
ចម្លងពពួកសត្វ ឆ្លងកាត់ផុតវដ្តសង្សារ ។

និងសូមលើកកំបង់ គោរពសង្ឃអង្គថ្លៃថ្លា
សាវ័កព្រះសាស្តា ថែរក្សាធម៌វិន័យ ។
ដោយចិត្តខ្ញុំជ្រះថ្លា ថ្វាយវន្ទាទ្វារទាំងបី
ឆ្ពោះគុណរតនត្រ័យ សូមនិស្ស័យបាននិព្វាន ។

# បូជាព្រះរតនត្រ័យ

( បទពាក្យប្រាំពីរ )

បូជាព្រះពុទ្ធមានតេជះ បានជ័យជំនះមារសត្រូវ
យល់ច្បាស់មាគ៌ាដែលគួរទៅ ជាផ្លូវសំដៅដល់និព្វាន ។
បូជាព្រះធម៌កើតបញ្ញា រស្មីភ្លឺថ្លាប្រាកដមាន
ទុកដូចប្រទីបជាប់ជិតប្រាណ ដំណើរឆ្ពោះបានក្សាន្តចាកទុក្ខ។
បូជាព្រះសង្ឃធ្វើឲ្យមាន សម្បត្តិធនធានបានក្តីសុខ
គឺជាស្រែបុណ្យដាំពូជទុក ជាតិនេះជាតិមុខឥតខ្វះខាត ។

* ដោយឧបាសក **ម៉ិញ សាវ៉ាន**

# រដ្ឋបាលសូត្រ ទីពីរ

**ស**ម័យមួយព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅក្នុងដែនកុរុ ជាមួយនឹងពួកភិក្ខុច្រើនរូប ទៅដល់ថុល្លកោដ្ឋិតនិគមរបស់អ្នកដែនកុរុទាំងឡាយ ។ ព្រាហ្មណ៍និងគហបតីទាំងឡាយ កាលបើបានឮដំណឹងថាព្រះសមណគោតម ជាសក្យបុត្រទ្រង់ចេញចាកសក្យត្រកូល ទ្រង់ព្រះផ្នួស ឥឡូវទ្រង់ពុទ្ធដំណើរមកក្នុងដែនកុរុជាមួយភិក្ខុច្រើនរូប ពួកព្រាហ្មណ៍និងគហបតីទាំងឡាយនោះ មានសេចក្តីជ្រះថ្លាចំពោះគុណព្រះសម្មាសម្ពុទ្ធដ៏យ៉ាងក្រៃលែង ទើបនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះក៏រាក់ទាក់

ពួកខ្លះគ្រាន់តែប្រណម្យអញ្ជលី ពួកខ្លះគ្រាន់តែប្រកាសនាមនិងគោត្រ ហើយនាំគ្នាអង្គុយក្នុងទីដ៏សមគួរក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ លុះព្រាហ្មណ៍និងគហបតី អ្នកស្រុកថុល្លកោដ្ឋិតអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យហ៊ាន ឲ្យរីករាយដោយធម្មីកថា ។

ទទួលចួនជាសម័យនោះឯង មានកុលបុត្រម្នាក់ឈ្មោះ **រដ្ឋបាល** ជាកូនរបស់អ្នកមានត្រកូលដ៏ប្រសើរ ក្នុងថុល្លកោដ្ឋិតនិគមនោះឯង បានអង្គុយស្តាប់ព្រះធម៌ក្នុងបរិស័ទនោះដែរ បានត្រិះរិះយ៉ាងនេះថា ៖

- អាត្មាអញបានដឹងធម៌ដែលព្រះមានព្រះភាគសំដែងយ៉ាងណា ៗ តែព្រហ្មចរិយធម៌នេះមិនមែនសម្រាប់បុគ្គលអ្នកគ្រប់គ្រងផ្ទះងាយនឹងប្រព្រឹត្តឲ្យបានបរិបូណ៌សព្វគ្រប់ បរិសុទ្ធផូរផង់បានទេ បើដូច្នេះគួរតែអាត្មាអញកោសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស ។

លុះដល់ព្រាហ្មណ៍និងគហបតីទាំងឡាយ ស្តាប់ព្រះធម៌ចប់ហើយ ក៏បានក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណជៀសចេញទៅ ។

**រដ្ឋបាល** កុលបុត្រ បានចូលទៅក្រាបបង្គំទូលព្រះដ៏មានព្រះភាគ រៀបរាប់ពីការបានស្តាប់ព្រះធម៌ មានសេចក្តីជ្រះថ្លា ប្រាថ្នាចេញចាកផ្ទះ ទូលសូមព្រះដ៏មានព្រះភាគបាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងសំណាក់ព្រះអង្គ ។

ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា ៖

- ម្នាល **រដ្ឋបាល** មាតាបិតាបានអនុញ្ញាត ឲ្យអ្នកបានចេញចាកផ្ទះមកបួសហើយឬ ?

**រដ្ឋបាល** ឆ្លើយតបនឹងព្រះដ៏មានព្រះភាគវិញថា ៖

- បពិត្រព្រះអង្គដ៏ចំរើន មាតាបិតាខ្ញុំព្រះអង្គមិនទាន់បានអនុញ្ញាតឲ្យខ្ញុំព្រះអង្គចេញចាកផ្ទះមកបួសទេ ។

ព្រះដ៏មានព្រះភាគ ៖

- ម្នាល **រដ្ឋបាល** ព្រះតថាគតទាំងឡាយមិនបំបួសកូនដែលមាតាបិតាមិនបានអនុញ្ញាតទេ ។

- បពិត្រព្រះអង្គដ៏ចំរើន មាតាបិតាខ្ញុំព្រះអង្គនឹងអនុញ្ញាតឲ្យខ្ញុំព្រះអង្គចេញចាកផ្ទះមកបួសយ៉ាងណា ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ។ **រដ្ឋបាល** ឆ្លើយតបនឹងព្រះដ៏មានព្រះភាគវិញ ។

ខណៈនោះឯង **រដ្ឋបាល** កុលបុត្រក្រោកចាកអាសនៈហើយថ្វាយបង្គំព្រះមានជោគ ធ្វើប្រទក្សិណលាត្រឡប់មករកមាតាបិតា ។





# រដ្ឋបាលកុលបុត្រ
## លាមាតាបិតាចេញបួស

**រដ្ឋ**បាលកុលបុត្រ បានមកដល់ផ្ទះ ចូលទៅជួបមាតាបិតា ទើបនិយាយយ៉ាងនេះថា ៖

- បពិត្រលោកម្តាយលោកឪពុក ខ្ញុំបានយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគបានសំដែងហើយយ៉ាងណា ព្រហ្មចរិយធម៌នេះ មិនមែនសម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះងាយនឹងប្រព្រឹត្តឲ្យបរិបូណ៌ផូរផង់បានណាស់ ខ្ញុំប្រាថ្នានឹងកោរសក់ កោរពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះទៅបួស សូមលោកម្តាយលោកឪពុកអនុញ្ញាតឲ្យខ្ញុំបានបួសចុះ ។

កាល **រដ្ឋបាល** និយាយយ៉ាងនេះហើយ មាតាបិតាក៏និយាយតបនឹង **រដ្ឋបាល** កុលបុត្រវិញថា ៖

- ម្នាល **រដ្ឋបាល** កូន ! អ្នកឯងជាបុត្រតែមួយជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់ចំរើនដោយសេចក្តីសុខ នែ៎ **រដ្ឋបាល** កូន បាឯងមិនដែលស្គាល់សេចក្តីទុក្ខលំបាក សូម្បីតែបន្តិចបន្តួចសោះឡើយនឹងទៅបួសម្តេចកើត, នែ៎កូន ! អ្នកចូរមកបរិភោគបាយ ផឹកទឹក ទាំងឲ្យគេបម្រើហើយបរិភោគកាម និងធ្វើបុណ្យតាមស្ម័គ្រចិត្តចុះ យើងមិនអនុញ្ញាតឲ្យអ្នកចេញចាកទៅបួសទេ, ទុកជាដល់ស្លាប់ក៏យើងមិនចង់ឃ្លាតពីបាដែរ ចំណង់បើបានៅរស់យ៉ាងនេះ យើងនឹងអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ទៅបួសម្តេចបាន ។

**រដ្ឋបាល** និយាយសូមអនុញ្ញាតពីមាតាបិតា ជាគំរប់ពីរដងជាគំរប់បីដងផង តែមាតាបិតាមិនព្រមអនុញ្ញាត ។ **រដ្ឋបាល** កុលបុត្រក៏ដួលដេកនៅលើទីដែលគ្មានកម្រាលក្រាល មានចិត្តគិតថា អាត្មាអញនឹងបានបួស ឬនឹងត្រូវស្លាប់នៅក្នុងទីនេះ . . . ។

ទោះបីជាអ្នកបម្រើយកម្ហូបអាហារនំចំណី មាតាបិតាអង្វរឲ្យបរិភោគ ឲ្យផឹក ក៏ធ្វើនៅស្ងៀមហី មិនខ្វីរវល់អើពើឡើយ ។ កាលបើឃើញ **រដ្ឋបាល** មិនបរិភោគអាហារនំចំណីដូច្នោះ, សម្លាញ់ **រដ្ឋបាល** ជាច្រើននាក់បានមកនិយាយអង្វរ មិនឲ្យ **រដ្ឋបាល** កុលបុត្រចេញទៅបួស ដោយពោលនូវពាក្យដូចមាតាបិតាបានពោលរួចមកហើយដែរ ។ ទោះបីជាមិត្តសម្លាញ់ខំអង្វរយ៉ាងណា ក៏ **រដ្ឋបាល** នៅតែស្ងៀមហី ឥតព្រមខ្វីរវល់ស្តាប់ ឬតបតសោះឡើយ ។

ពួកសម្លាញ់ ឃើញ **រដ្ឋបាល** ស្ងៀមហី មិនស្តី មិនបរិភោគ មិនផឹកដូច្នោះ ក៏ចូលទៅរកមាតាបិតា **រដ្ឋបាល** និយាយយ៉ាងនេះ

• • •

ថា ៖

- បពិត្រមាតាបិតា **រដ្ឋបាល** នេះមិនព្រមទេ នៅដេកដួលលើទីមិនក្រាល មិនព្រមបរិភោគអាហារសោះ បើសិនជាមាតាបិតាមិនអនុញ្ញាតទេ **រដ្ឋបាល** កុលបុត្រនេះនឹងស្លាប់ អ្នកប្រាកដជាលែងបានឃើញមុខកុលបុត្រនេះតទៅទៀតហើយ ។ ដូច្នេះបើអ្នកអនុញ្ញាតឲ្យ **រដ្ឋបាល** ចេញទៅបួស អ្នកបានឃើញ **រដ្ឋបាល** រស់នៅផង ម្យ៉ាងទៀតបើកុលបុត្រមានការធុញទ្រាន់នឹងភេទបួសពេលណា នឹងលាសិក្ខាមកកាន់ហីនភេទវិញមិនខាន ។

មាតាបិតាក្រោយពីបានស្តាប់ពាក្យពន្យល់ដូច្នោះហើយ ក៏យល់ព្រមអនុញ្ញាតឲ្យកូនចេញទៅបួស គ្រាន់តែផ្តាំថា ៖

- បើបាបួសហើយ សូមឲ្យត្រឡប់មករកមាតាបិតាបានឃើញមុខកូនផង ។

**រដ្ឋបាល** កុលបុត្រមានសេចក្តីត្រេកអរណាស់ ស្ទុះក្រោកឡើង សម្រាកកាយឲ្យមានកម្លាំងបន្តិច ទើបលាមាតាបិតាធ្វើដំណើរទៅកាន់សំណាក់ព្រះបរមសាស្តាសម្មាសម្ពុទ្ធ ថ្វាយបង្គំទូលព្រះមានព្រះភាគថា ៖

- បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាបុគ្គលដែលមាតាបិតាបានអនុញ្ញាតឲ្យចេញចាកផ្ទះមកបួសហើយ សូមព្រះមានព្រះភាគបំបួសខ្ញុំព្រះអង្គ ។

**រដ្ឋបាល** កុលបុត្រក៏បាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងសំណាក់នៃព្រះមានព្រះភាគ ។ **រដ្ឋបាល** ដ៏មានអាយុ បួសត្រឹមតែកន្លះខែ ព្រះដ៏មានព្រះភាគគង់នៅក្នុងថុល្លកោដ្ឋិតនិគមតាមពុទ្ធ

អាធ្យាស្រ័យហើយ ទ្រង់ស្តេចចេញចាកទីនោះ ទ្រង់ព្រះពុទ្ធដំណើរឆ្ពោះទៅកាន់ក្រុងសាវត្ថី ។

មានសេចក្តីតំណាលថា កាលព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ព្រះ**រដ្ឋបាល**ដ៏មានអាយុ បានជៀសចេញទៅម្នាក់ឯង ជាអ្នកមិនប្រហែសធ្វេសខំព្យាយាមដុតបង់នូវកិលេស បញ្ជូនចិត្តឲ្យចូល ( ទៅកាន់និព្វាន ) មានចិត្តរួចផុតចាកកិលេស ជាព្រះអរហន្តមួយរូប ទើបត្រឡប់មកថ្វាយបង្គំព្រះមានជោគ ដើម្បីបានព្រះពុទ្ធានុញ្ញាតវិលត្រឡប់ទៅកាន់ថុល្លកោដ្ឋិតនិគមជាស្រុកកំណើត ឲ្យមាតាបិតាបានឃើញផង ព្រះពុទ្ធទ្រង់ជ្រាបដោយព្រះពុទ្ធញាណថា ព្រះ **រដ្ឋបាល** មានចិត្តរួចផុតស្រឡះចាកកិលេសាសវៈ មិនវិលត្រឡប់កាន់ភេទថោកទាបវិញទេ ទើបទ្រង់មានព្រះពុទ្ធានុញ្ញាត ។



# ព្រះរដ្ឋបាល
## ត្រឡប់មកជួបមាតាបិតាវិញ

**ព្រះរដ្ឋបាល** ដ៏មានអាយុ បានចូលទៅសំណាក់ក្នុងឧទ្យាន ឈ្មោះមិគាចីរៈរបស់ព្រះបាទកោរព្យៈ ជិតថុល្លកោដ្ឋិតនិគមនោះ ។

ក្នុងបុព្វណ្ហសម័យលោកបានចូលទៅបិណ្ឌបាត តាមលំដាប់ ច្រករៀងទៅដល់ទីនៅអាស្រ័យរបស់បិតាលោក ។ ទទួលចួន សម័យនោះឯង បិតាកំពុងឲ្យជាងកោរកាត់នៅក្នុងរោង បានចោល ភ្នែកក្រឡេកឃើញព្រះ **រដ្ឋបាល** ដ៏មានអាយុពីចម្ងាយ គាត់ឥត បានស្គាល់ថាជាកូនទេ ដោយការមិនពេញចិត្ត គាត់ក៏និយាយ យ៉ាងនេះថា ៖

- ពួកស្រមណ៍កំណោរទាំងនេះហើយ ដែលបំបួសកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង ។

គ្រានោះឯង ព្រះ **រដ្ឋបាល** ដ៏មានអាយុ មិនបាននូវទានផង ទាំងមិនបាននូវពាក្យប្រាប់មកវិញក្នុងលំនៅរបស់បិតានៃខ្លួនសោះ បានត្រឹមតែពាក្យជេរប៉ុណ្ណោះឯង ។

ពេលដែលលោកកំពុងតែនិមន្ត គាប់ចួនសម័យនោះឯងនាងទាសីរបស់ញាតិព្រះ **រដ្ឋបាល** បានយកនំកុម្មាសផ្អូមទៅចាក់ចោល លោកក៏និយាយនឹងនាងទាសីថា ៖

- នែ៎នាង ! បើនំនេះជារបស់ត្រូវចោល ចូរនាងដាក់មកក្នុងបាត្រអាត្មានេះចុះ ។

លំដាប់នោះ ស្រីបម្រើបានដាក់នំកុម្មាសផ្អូមទៅក្នុងបាត្រហើយ ទើបសម្គាល់ថាជា **រដ្ឋបាល** កុលបុត្រ ក៏ម្នីម្នារត់ទៅប្រាប់មាតាបិតាព្រះ **រដ្ឋបាល** ឲ្យជ្រាបថា, ព្រះ **រដ្ឋបាល** បានធ្វើដំណើរមកដល់ស្រុកនេះហើយ ។

មាតាបិតា កាលបើជ្រាបថាកូនត្រឡប់មកវិញដូច្នេះ មានសេចក្តីត្រេកអរណាស់, គហបតីជាបិតាបានដើររកកូន ទទួលពេលនោះ ព្រះ **រដ្ឋបាល** លោកកំពុងឆាន់នំកុម្មាសផ្អូមប្របជញ្ជាំងសាលាមួយ បិតាគ្រាន់តែបានឃើញ ក៏ពោលពាក្យយ៉ាងនេះថា ៖

- នែ៎ **រដ្ឋបាល** កូន ! មានដែរឬលោកមកឆាន់នំកុម្មាសផ្អូមវិញ ? កូនគួរតែទៅឯផ្ទះយើងវិញ ។

ព្រះ **រដ្ឋបាល** បានឆ្លើយថា ៖

- នែ៎គហបតី ! ពួកយើងអ្នកបួសចេញចាកផ្ទះ នឹងមានផ្ទះមកពីណាទៀត, ពួកយើងគ្មានផ្ទះទេ អាត្មាបានទៅដល់ផ្ទះអ្នក

ហើយ តែមិនបាននូវទានផង ឥតបាននូវពាក្យនិយាយរាក់ទាក់ផង ក្នុងសំណាក់ផ្ទះអ្នកសោះ បានត្រឹមតែពាក្យជេរប៉ុណ្ណោះឯង ។

បិតារបស់ព្រះ **រដ្ឋបាល** បានឆ្លើយតបវិញថា ៖

- **រដ្ឋបាល** កូនលោកចូលមក យើងនឹងទៅផ្ទះ,

- ណ្ហើយគហបតី ថ្ងៃនេះអាត្មាឆាន់រួចហើយ, ព្រះ **រដ្ឋ-បាល** បានឆ្លើយតបនឹងបិតាវិញ ។

- **រដ្ឋបាល** កូនបើដូច្នោះ សូមលោកនិមន្តទទួលចង្ហាន់ក្នុងថ្ងៃស្អែក ។

ព្រះ **រដ្ឋបាល** មានអាយុ ទទួលនិមន្តដោយតុណ្ហីភាព[១] ។

គ្រានោះបិតាដឹងថាកូនទទួលនិមន្តហើយ ក៏ត្រឡប់ចូលទៅកាន់លំនៅរបស់ខ្លួន ហើយប្រើអ្នកបម្រើឲ្យយកប្រាក់មកចាក់គរមួយគំនរ មាសមួយគំនរកំពស់មួយជំហរ, បុរសដែលឈរខាងអាយមិនអាចមើលឃើញបុរសឈរខាងនាយបាន, ហើយឲ្យបិទបាំងគំនរទាំងពីរនោះដោយកន្ទេល ឲ្យក្រាលអាសនៈទុកត្រង់ចន្លោះកណ្ដាលគំនរមាសនិងប្រាក់នោះ, ហើយហៅពួកស្រីជាគូពីមុនរបស់ព្រះ **រដ្ឋបាល** ដ៏មានអាយុមកបង្គាប់ថា ៖

- នែ៎កូនស្រី ! ឯងរាល់គ្នាចូរមកណេះ គ្រឿងប្រដាប់ណាដែលឯងរាល់គ្នាធ្លាប់ប្រដាប់តាក់តែងហើយពីកាលមុន ធ្វើឲ្យកូនយើងចាប់ចិត្តផ្ចិតអារម្មណ៍ ពួកឯងចូរតាក់តែង ស្អិតស្អាងរាងកាយ

---

(១) តុណ្ហីភាព តុន-ហី-ភាប បា.; សំ. (ន.) ភាពស្ងៀម, ដំណើរស្ងៀមមិនបញ្ចេញវាចា : ព្រះសាស្ដាទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ; ព្រះករុណាជាម្ចាស់ជីវិតទ្រង់ព្រះតុណ្ហីភាព ។

ដោយគ្រឿងប្រដាប់ទាំងនោះចុះ ។

លុះកន្លងរាត្រីនោះទៅ គហបតីបានចាត់ចែងខាទនីយភោ-ជនីយាហារដ៏ឆ្ងិតឆ្ងង់ក្នុងលំនៅរបស់ខ្លួន ស្រេចបាច់ហើយដល់កាលវេលា ប្រាប់នូវកាលដល់ព្រះ **រដ្ឋបាល** ដ៏មានអាយុថា ៖

- **រដ្ឋបាល** កូន ! កាលគួរហើយ ភត្តសម្រេចហើយ ។

ចំណែកព្រះ **រដ្ឋបាល** មានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយនិមន្តចូលត្រង់លំនៅរបស់បិតាខ្លួន ។ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលបម្រុងទុក ។ ទើបបិតាប្រាប់ឲ្យគេបើកគំនរប្រាក់ និងមាសនោះ ហើយក៏និយាយនឹងកូនថា ៖

- ទ្រព្យនេះជារបស់មាតាលោក, ទ្រព្យខាងនេះជារបស់បិតា ដោយឡែកទ្រព្យប៉ុណ្ណោះ ជាទ្រព្យរបស់ជីដូនជីតា . . . **រដ្ឋបាល** កូន លោកអាចប្រើប្រាស់ភោគៈទាំងឡាយផង ធ្វើបុណ្យផង ចូរកូនមក ចូរលាសិក្ខាមករកភេទទាប ហើយប្រើប្រាស់ភោគៈទាំងឡាយ និងធ្វើបុណ្យផងចុះ ។

- បពិត្រគហបតី បើលោកធ្វើតាមពាក្យរបស់អាត្មា ញោមត្រូវប្រើមនុស្សឲ្យជញ្ជូនគំនរប្រាក់មាសនេះ ផ្ទុកក្នុងរទេះហើយយកទៅចាក់ចោល ក្នុងកណ្តាលខ្សែទឹកទន្លេគង្គា, ហេតុអ្វីបានជាអាត្មាថាដូច្នេះ គហបតី ! ព្រោះជាសេចក្តីខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់ មុខជាកើតឡើងដល់ញោម ព្រោះតែទ្រព្យទាំងនោះជាហេតុ, ព្រះ **រដ្ឋបាល** និយាយពន្យល់ទៅបិតាវិញ។

ពេលនោះពួកស្រីជាគូពីមុនរបស់ **រដ្ឋបាល** ដ៏មានអាយុបាននាំគ្នាឱបជើងម្ខាងម្នាក់ ហើយនិយាយយ៉ាងនេះថា ៖

- បពិត្រព្រះអយ្យបុត្រ ! លោកប្រព្រឹត្តព្រហ្មចរិយធម៌ព្រោះហេតុ ( ចង់បាន ) ពួកស្រីអប្សរណា ពួកស្រីអប្សរទាំងនោះតើល្អដូចម្ដេចទៅ ?

- ម្នាលនាង ! អាត្មាមិនមែនប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុ ( ចង់បាន ) ពួកស្រីអប្សរទេ ។

ពួកស្រីទាំងនោះ គ្រាន់តែឮពាក្យ **រដ្ឋបាល** អយ្យបុត្រហៅរកថា " នាង " ដូច្នេះ ក៏ដួលជ្រប់ក្នុងទីនោះតែម្ដង ទើបព្រះ**រដ្ឋបាល** មានអាយុនិយាយនឹងបិតាថា ៖

- បពិត្រគហបតី ! បើញោមត្រូវការឲ្យភោជនក៏ឲ្យមក កុំបៀតបៀនអាត្មាឡើយ ។

- **រដ្ឋបាល** កូន សូមលោកនិមន្តឆាន់ចុះ ភត្តសម្រេចហើយ ។

គ្រានោះបិតា បានចាត់ចែងខាទនិយភោជនិយាហារដោយផ្ចិតផ្ចង់ ប្រគេន **រដ្ឋបាល** មានអាយុ ឆាន់ដោយដៃខ្លួនឯងត្រាតែឆ្អែត ។

នៅពេលជាខាងក្រោយភត្ត ព្រះ **រដ្ឋបាល** បានឈរសម្ដែងគាថាទាំងឡាយយ៉ាងនេះថា ៖

- **ញោមចូរមើលនូវអត្តភាព ដែលជាសង្ខារវិចិត្រហើយ ជាទីប្រជុំនៃដំបៅប្រាំបួន ( ៩ ) អន្លើ ផ្គុំឡើងដោយឆ្អឹងបីរយកំណាត់ ( ៣០០ ) ក្ដៅរោលរាល ដែលជនច្រើនគ្នាត្រូវការ ជាកាយមិនទៀងទាត់បិតថេរឡើយ ។ ញោមចូរមើលរូប ដែលសង្ខារវិចិត្រហើយ ប្រកបដោយកុណ្ឌលមណី ដែលរួបរឹតហើយដោយឆ្អឹងនិងស្បែក**

ល្អដោយសារតែសំពត់, ជើងទាំងឡាយវិចិត្រហើយដោយទឹកល័ខ, មុខមាត់លាបហើយដោយគ្រឿងលំអិត អាចឲ្យមនុស្សពាលវង្វេងបាន តែមិនអាចបំភាន់ដល់អ្នកស្វែងរកត្រើយ គឺព្រះនិព្វានបានឡើយ, សក់ទាំងឡាយដែលវិចិត្រហើយ មានសណ្ឋានដូចជាក្រឡាចត្រង្គ, ភ្នែកទាំងឡាយលាបហើយ ដោយថ្នាំសម្រាប់បន្តក់ល្មមឲ្យបុគ្គលពាលភាន់ភាំងបាន តែមិនអាចបំភាន់បុគ្គលអ្នកស្វែងរកត្រើយបានឡើយ, កាយស្អុយដែលបានប្រដាប់ហើយ ដូចជាបំពង់ថ្នាំដាក់ភ្នែកយ៉ាងថ្មីដ៏វិចិត្រ អាចបំភាន់ដល់បុគ្គលពាលបាន តែមិនអាចបំភាន់បុគ្គលអ្នកស្វែងរកត្រើយបានឡើយ, ព្រានម្រឹគដាក់នូវបង្កាត់ជាអន្ទាក់ តែម្រឹគមិនជាប់អន្ទាក់ កាលបើព្រានកំពុងកន្ទក់កន្ទេញ អាត្មាបរិភោគបន្លែរួចហើយ ត្រឡប់ទៅវិញ ។



# សេចក្តីសាបសូន្យបួនយ៉ាង

**សេច**ក្តីសាបសូន្យបួនយ៉ាង ដែលព្រះបាទកោរព្យៈលើកយកមកបរិយាយ ហើយបានតាំងជាគោលខ សួរដល់ព្រះ **រដ្ឋ - បាល** ដ៏មានអាយុ អំពីមូលហេតុដែលនាំឲ្យព្រះ **រដ្ឋបាល** ចេញចាកផ្ទះទៅបួស ។

មានសេចក្តីតំណាលថា ក្រោយពីសម្តែងគាថាចប់ហើយព្រះ **រដ្ឋបាល** បានត្រឡប់ចេញពីផ្ទះ និមន្តត្រង់ទៅឧទ្យានឈ្មោះមិគា-ចីរៈ របស់ព្រះបាទកោរព្យៈ ។ លុះចូលទៅដល់ហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃក្បែរគល់ឈើមួយដើម ។

គ្រានោះព្រះបាទកោរព្យៈ ត្រាស់ហៅនាយឧទ្យានបាលឈ្មោះមិគវៈថា ៖

- ឯងចូររៀបចំឧទ្យានភូមិឈ្មោះមិគាចីរៈ យើងនឹងទៅមើលទីដ៏សប្បាយ ។

មិគវៈទទួលព្រះរាជឱង្ការហើយ បានចូលទៅរៀបចំឧទ្យានឃើញព្រះ **រដ្ឋបាល** មានអាយុកំពុងសម្រាកក្នុងវេលាថ្ងៃក្បែរគល់ឈើមួយដើម ។ ក៏បានត្រឡប់មកទូលព្រះបាទកោរព្យៈយ៉ាងនេះថា ៖

- បពិត្រព្រះសម្មតិទេព ឧទ្យានមិគាចីរៈរបស់ព្រះអង្គស្អាតបាតហើយ ក៏ប៉ុន្តែទីនោះមានកុលបុត្រជាកូនរបស់ត្រកូលដ៏ប្រសើរក្នុងថុល្លកោដ្ឋិតនិគមនេះឯង, ដែលព្រះអង្គតែងសរសើរជារឿយ ៗ ឥឡូវនេះលោកសម្រាកក្នុងវេលាថ្ងៃ ក្បែរគល់ឈើមួយដើម ។

ព្រះបាទកោរព្យៈ គ្រាន់តែបានជ្រាបដំណឹងនោះភ្លាម មានព្រះរាជហឫទ័យជ្រះថ្លាខ្លាំងណាស់ ទ្រង់បញ្ជាឲ្យលើកឈប់ទៅក្រសាលឧទ្យាន ដោយមានព្រះរាជឱង្ការ ៖

- ណ្ហើយចុះ ! ដំណើរទៅលេងទីឧទ្យានថ្ងៃនេះចូរឈប់សិនចុះ យើងនឹងចូលទៅអង្គុយជិតព្រះ **រដ្ឋបាល** ដ៏ចម្រើននោះវិញ ។

ព្រះរាជាទ្រង់យាងទៅជួបព្រះ **រដ្ឋបាល** ព្រមដោយបរិស័ទយ៉ាងច្រើនកុះករ ។ លុះទៅដល់បានធ្វើសេចក្តីរីករាយរាក់ទាក់ជាមួយព្រះ **រដ្ឋបាល** ដ៏មានអាយុហើយ ទើបគង់លើអាសនៈដ៏សមគួរ ។

កាលព្រះបាទកោរព្យៈ គង់លើអាសនៈដ៏សមគួរហើយ ព្រះរាជាបានលើកយកសេចក្តីសាបសូន្យបួនយ៉ាង មកអធិប្បាយប្រាស្រ័យសួរព្រះ **រដ្ឋបាល** ដូច្នេះថា ៖

- បពិត្រព្រះ **រដ្ឋបាល** ដ៏ចម្រើន ! សេចក្តីសាបសូន្យបួនយ៉ាង ដែលមនុស្សខ្លះក្នុងលោកនេះជួបប្រទះហើយ តែងកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស, សេចក្តីសាបសូន្យបួនយ៉ាងនោះគឺ ៖

- សេចក្តីសាបសូន្យ ព្រោះជរា ១ ;
- សេចក្តីសាបសូន្យ ព្រោះព្យាធិ ១ ;
- សេចក្តីសាបសូន្យ ព្រោះភោគៈ ១ ;
- សេចក្តីសាបសូន្យ ព្រោះញាតិ ១ ។

បពិត្រព្រះ **រដ្ឋបាល** ដ៏ចម្រើន មនុស្សខ្លះក្នុងលោកនេះជាអ្នកមានវ័យច្រើន ចូលដល់វ័យជរា កម្លាំងថមថយ ភ្លេចមុខភ្លេចក្រោយ មិនអាចប្រកបការងារជាអាជីវៈ ដើម្បីរកទ្រព្យឲ្យចម្រើនបានផង មិនអាចថែរក្សាការពារទ្រព្យ ដែលមាននៅឲ្យគង់វង្សផង ។

មនុស្សខ្លះទៀត ជាអ្នកត្រូវព្យាធិបៀតបៀន ឈឺចុកចាប់មិនអាចចិញ្ចឹមជីវិតបាន នាំឲ្យរំខានក្នុងជីវិត ទើបកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស តែនេះព្រះ **រដ្ឋបាល** ដ៏ចម្រើននៅវ័យក្មេង មានកម្លាំងមាំទាំ មានសក់ខ្មៅស្រិល មានសុខភាពល្អបរិបូណ៌ ដោយសាច់ដុំកំភួនដៃ

សាច់ជុំភ្លៅ ឥតមានព្យាធិអ្វីមកបៀតបៀន ជាអ្នកបរិបូណ៌ដោយកាយសម្បទា ឥតមានសេចក្ដីសាបសូន្យដោយជរា ឬដោយព្យាធិណាមួយទេ ចុះតើព្រះ **រដ្ឋបាល** ដ៏ចម្រើន ដឹងហើយ ឃើញហើយ ឬឮអ្វីហើយ បានជាចេញចាកផ្ទះទៅសាងផ្នួស ។

ប្រការទីបីនិងទីបួន មនុស្សខ្លះក្នុងលោកនេះ ធ្លាប់ជាត្រកូលគហបតី សេដ្ឋី ព្រាហ្មណ៍មហាសាល ជាអ្នកមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ សមប្រកបដោយមុខរបរ រស់នៅលើគំនរមាសប្រាក់បរិភោគប្រើប្រាស់ប្រកបដោយសេចក្ដីសុខចម្រើនគ្រប់បែប យ៉ាងទាំងជាអ្នកមានញាតិមិត្រអាមាត្យ មានបរិវារកម្មករ កំដរបម្រើទាំងថ្ងៃយប់គ្រប់បរិបូណ៌ឥតមានខ្វះអ្វីឡើយ ដល់ពេលក្រោយមក មនុស្សទាំងនោះ ត្រូវវិនាសទ្រព្យដោយប្រការផ្សេង ៗ ដូចជាត្រូវទឹកលិច ភ្លើងឆេះ ចោរលួច ព្រះរាជារឹបអូស ញាតិមិត្រជិតឆ្ងាយបៀតបៀន កេងប្រវ័ញ្ច ទាំងត្រូវវិនាសបាត់បង់ សាបសូន្យចាកញាតិដោយឧបទ្ទវហេតុ ឬដោយប្រការណា ៗ ក្ដី ។ មនុស្សនោះអត់មានទីពឹងពាក់ពំនាក់អាស្រ័យ ទើបកោរសក់ ចេញចាកផ្ទះទៅបួស ។ ចុះព្រះ **រដ្ឋបាល** ដ៏ចម្រើន ជាអ្នកបរិបូណ៌ដោយទ្រព្យសម្បត្តិ ជាអ្នកបរិបូណ៌ដោយត្រកូល ញាតិមិត្រសាច់សាលោហិតជិតឆ្ងាយ រស់នៅដោយសប្បាយគ្មានភ័យអន្តរាយវិនាសសាបសូន្យដោយហេតុទាំងពីរប្រការនេះទេ តើព្រះ **រដ្ឋបាល** ដ៏ចម្រើន ដឹងហើយ ឮហើយ ឃើញហើយ ដោយហេតុយ៉ាងណា ទើបចេញចាកផ្ទះទៅបួស ?...

# រាជវគ្គ រដ្ឋបាលសូត្រ

## ធម្មុទ្ទេសបួនប្រការ

**ព្រះរដ្ឋបាល** ថ្វាយព្រះពរថា ៖

- បពិត្រមហារាជ មានធម្មុទ្ទេសបួនប្រការដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮហើយផង ទើបចាកចេញពីផ្ទះទៅបួស ។

## ធម្មុទ្ទេសបួនយ៉ាងដូចម្តេច ?

- បពិត្រមហារាជ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ

ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយថា ៖

- ធម្មុទ្ទេសទីមួយ សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅរក ( មរណៈ ) ;
- ធម្មុទ្ទេសទីពីរ សត្វលោកមិនមានគ្រឿងការពារមិនមានទីពឹងឡើយ ;
- ធម្មុទ្ទេសទីបី សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួងដូច្នេះ ;
- ធម្មុទ្ទេសទីបួន សត្វលោកមានតែសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ។

ធម្មុទ្ទេសទាំងបួនយ៉ាងនេះឯង ដែលព្រះមានបុណ្យព្រះអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សម្តែងហើយដូច្នេះ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស ។

ព្រះបាទកោរព្យៈ ក្រោយពីបានស្តាប់ការរៀបរាប់ធម្មុទ្ទេសទាំងបួនយ៉ាងនោះហើយ ព្រះរាជាទូលសូមឲ្យព្រះ **រដ្ឋបាល** មានអាយុ សម្តែងអធិប្បាយពន្យល់ឲ្យបានយល់សេចក្តីនៃធម៌ទាំងបួនប្រការនោះ . . .

# ព្រះរដ្ឋបាល
## បរិយាយសេចក្តីនៃធម្មុទ្ទេស

**ព្រះ**បាទកោរព្យៈត្រាស់សួរថា ៖

- ព្រះ **រដ្ឋបាល** ដ៏ចម្រើន ត្រាស់សម្តែងថា " សត្វលោកមិនទៀង " តែងត្រូវជរានាំចូលទៅរកមរណៈ សេចក្តីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្តេច ?

- ថ្វាយព្រះពរមហារាជ កាលដែលមហាបពិត្រមានព្រះជន្មក្នុងរវាងម្ភៃ ( ២០ ) ឆ្នាំ, គ្រប់ម្ភៃ ( ២០ ) ឆ្នាំហើយផង បានចេះចាំស្ទាត់ដោយមុខវិជ្ជាដំរីផង សេះផង ស្ទាត់ដោយវិជ្ជាបាញ់ធ្នូផង វិជ្ជាដងដាវផង, ព្រះរាជាបរិបូណ៌ដោយព្រះសុខភាព មានកម្លាំង

កាយខ្លាំងក្លា អង់អាចក្នុងសង្គ្រាមបាន តើព្រះអង្គសម្គាល់សេចក្ដីថា ក្នុងពេលនោះដូចម្ដេច ? ។ ព្រះ **រដ្ឋបាល** មានអាយុត្រាស់សួរទៅព្រះបាទកោរព្យៈវិញ ។

- បពិត្រព្រះ **រដ្ឋបាល** ដ៏ចម្រើន ពេលនោះនិងពេលឥឡូវនេះ មិនដូចគ្នាទេ ឥឡូវនេះខ្ញុំជរាហើយ ចម្រើនដោយវ័យចាស់អាយុច្រើន ដល់នូវសេចក្ដីថមថយជាលំដាប់ វ័យខ្ញុំដល់ប៉ែតសិបឆ្នាំហើយ, បពិត្រ **រដ្ឋបាល** ដ៏ចម្រើន ចួនកាលខ្ញុំគិតថា នឹងជាន់ត្រង់នេះ ស្រាប់តែខ្ញុំត្រឡប់ទៅជាជាន់កន្លែងឯទៀតវិញ ។

- បពិត្រមហារាជ ពាក្យថាសត្វលោកមិនទៀង ត្រូវជរានាំចូលទៅកាន់មរណៈ ដែលព្រះមានព្រះភាគព្រះអង្គសម្ដែងយ៉ាងនេះឯងថា " **សត្វលោកមិនទៀង** " ។

ព្រះបាទកោរព្យៈត្រាស់សួរជាបន្តទៅទៀតថា ៖

- ព្រះ **រដ្ឋបាល** ដ៏ចម្រើន ! " សត្វលោកមិនមានគ្រឿងការពារ " សេចក្ដីនៃភាសិតនេះ តើយល់ដោយប្រការដូចម្ដេច ?

- បពិត្រមហារាជ ! ព្រះអង្គសម្គាល់សេចក្ដីនោះដូចម្ដេច ? ព្រះអង្គធ្លាប់មានអាពាធ ទាល់តែផ្ទុំដាបលើទីបន្ទំដែរឬ ?

- បពិត្រ **រដ្ឋបាល** ដ៏ចម្រើន ! ខ្ញុំធ្លាប់មានអាពាធ ទាល់តែដាបនៅលើបន្ទំដែរ ចួនណាពួកមិត្រ អាមាត្យ ញាតិសាលោហិត ឈរចោមរោមខ្ញុំនិយាយថា " ព្រះបាទកោរព្យៈ នឹងទីវង្គត់ឥឡូវនេះ ៗ "

- បពិត្រមហារាជ ! ព្រះអង្គសម្គាល់សេចក្ដីនោះដូចម្ដេច តើព្រះអង្គអាចអង្វរ សូមញាតិមិត្រសាច់សាលោហិត ពួកអាមាត្យទាំងនោះឲ្យជួយរំលែក យកសេចក្ដីទុក្ខវេទនាបន្តិចបន្តួចបានពីព្រះ

អង្គដែរឬទេ ?

- បពិត្រ **រដ្ឋបាល** ដ៏ចម្រើន ! ក្នុងពេលនោះគ្មាននរណាម្នាក់ អាចជួយរំលែកទុក្ខខ្ញុំបានទេ ។

- បពិត្រមហារាជ ! យ៉ាងនេះឯង ដែលព្រះសាស្ដាសម្មាសម្ពុទ្ធ ព្រះអង្គសម្ដែងថា " **សត្វលោកមិនមានគ្រឿងការពារ** " ។ អាត្មាឃើញច្បាស់ដូច្នេះឯង ទើបចេញចាកផ្ទះទៅបួស ។

- ព្រះ **រដ្ឋបាល** ដ៏ចម្រើន ! សម្ដែងថា " សត្វលោកសុទ្ធតែគ្មានអ្វីជារបស់ខ្លួន " សុទ្ធតែត្រូវលះរបស់ទាំងពួងដូច្នេះ សេចក្ដីនៃភាសិតនេះ តើយល់ដោយប្រការដូចម្ដេច ? ព្រះបាទកោរព្យៈត្រាស់សួរជាបន្តទៅទៀត ។

- បពិត្រព្រះរាជសម្ភារ, ត្រាស់តបព្រះ **រដ្ឋបាល** , ព្រះអង្គសម្គាល់សេចក្ដីនោះថាដូចម្ដេច ? ឥឡូវនេះព្រះអង្គបានឆ្អែតស្កប់ស្កល់គ្រប់សព្វ ឲ្យគេបម្រើដោយកាមគុណទាំងប្រាំយ៉ាងណាតទៅលោកខាងមុខទៀតព្រះអង្គនឹងបានដូចបំណងថា អាត្មាអញគង់នឹងបានឆ្អែតស្កប់ស្កល់គ្រប់សព្វ ឲ្យគេបម្រើដោយកាមគុណទាំងប្រាំនេះឯង យ៉ាងនោះទៀតដែរឬ ? ឬពួកជនដទៃ គេនឹងគ្រប់គ្រងភោគសម្បត្តិនេះជំនួសវិញ ស្ដេចនឹងទ្រង់ទៅតាមយថាកម្ម ។

- បពិត្រ **រដ្ឋបាល** ដ៏ចម្រើន ! កាលឥឡូវនេះ ខ្ញុំបានបរិបូណ៌ដោយភោគសម្បត្តិ ញាតិមិត្រ សាច់សាលោហិត ស្រីស្នំទាំងឡាយ ព្រមទាំងកាមគុណប្រាំយ៉ាងស្កប់ស្កល់គ្រប់ធួនទាំងអស់តែទៅលោកខាងមុខ ខ្ញុំប្រាកដជាយកអ្វីទៅពុំបានសោះឡើយ របស់ទាំងនោះនឹងត្រូវបានអ្នកដទៃគ្រប់គ្រងជំនួសវិញ ចំណែកខ្ញុំ

នឹងត្រូវទៅកាន់លោកខាងមុខ ( តាមយថាកម្ម ) ។

- បពិត្រមហារាជ, ត្រាស់តបព្រះ **រដ្ឋបាល** , យ៉ាងនេះហើយ ដែលព្រះដ៏មានជោគ ព្រះអង្គទ្រង់ត្រាស់សម្ដែងថា " **សត្វលោកសុទ្ធតែគ្មានអ្វីជាប់ខ្លួន** " ។

ព្រះបាទកោរព្យៈត្រាស់សួរជាបន្តទៅទៀតថា ៖

- ព្រះ **រដ្ឋបាល** ដ៏ចម្រើនសម្ដែងថា " សត្វលោកសុទ្ធតែមានសេចក្ដីខ្វះខាត មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា " បពិត្រព្រះ **រដ្ឋបាល** ដ៏ចម្រើន សេចក្ដីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្ដេច ?

- បពិត្រមហារាជ, ត្រាស់តបព្រះ **រដ្ឋបាល** , ព្រះអង្គសម្គាល់នូវសេចក្ដីនោះថាដូចម្ដេច ព្រះអង្គគ្រប់គ្រងដែនកុរុ ដែលជាដែនស្ដុកស្ដម្ភមែន, បពិត្រមហារាជ ! បើមានបុរសរបស់ព្រះអង្គក្នុងទីនេះដែលគួរជឿពាក្យ គួរទទួលស្ដាប់ពាក្យបានមកពីទិសខាងកើត មកពីទិសខាងលិច មកពីទិសខាងត្បូង មកពីទិសខាងជើង បុរសនោះចូលមកគាល់ព្រះអង្គ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់មេត្តាប្រោស សូមព្រះអង្គទ្រង់ជ្រាប ខ្ញុំព្រះអង្គទើបនឹងមកពីទិសខាងនេះ ឬទិសខាងនោះ បានឃើញជន-បទធំក្នុងទិសនោះ ជាជនបទមាំមួនស្ដុកស្ដម្ភ មានជនច្រើន មានមនុស្សកុះករ ក្នុងជនបទនោះមានពួកពលដំរី ពួកសេះ ពលរថ និងពលថ្មើរជើងជាច្រើន មានភ្លុកមាសប្រាក់ ព្រមទាំងបរិវារ និងពួកស្ត្រីជាច្រើន . . . បពិត្រមហារាជ ! សូមព្រះអង្គច្បាំងយក តើព្រះអង្គនឹងធ្វើជនបទនោះដូចម្ដេច ?

ព្រះបាទកោរព្យៈត្រាស់ឆ្លើយថា ៖

- បពិត្រព្រះ **រដ្ឋបាល** ដ៏ចម្រើន ! ខ្ញុំត្រូវតែច្បាំងយកជនបទនោះមកគ្រប់គ្រងឲ្យបាន ។

ព្រះ **រដ្ឋបាល** ថ្វាយព្រះពរថា ៖

- បពិត្រមហារាជ, ពាក្យថា " **សត្វលោក សុទ្ធតែមានសេចក្តីខ្វះខាត មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា** " នេះឯងដែលព្រះដ៏មានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ឃើញច្បាស់ ទ្រង់សម្តែងដោយកហេតុនោះ ដែលអាត្មាភាពបានដឹង បានឃើញ បានឮ ចេញចាកផ្ទះមកបួស ។

- បពិត្រព្រះ **រដ្ឋបាល** ដ៏ចម្រើន ព្រោះថាសត្វលោកសុទ្ធតែមានសេចក្តីខ្វះខាតមិនចេះឆ្អែត សុទ្ធតែជាខ្ញុំនៃតណ្ហាពិតមែន ។

ព្រះ **រដ្ឋបាល** មានអាយុ បានសម្តែងធម្មុទ្ទេសទាំងបួននេះចប់ហើយ ទើបបានសម្តែងគាថានេះតទៅទៀតថា ៖

- អាត្មាភាពឃើញ ពួកមនុស្សអ្នកមានទ្រព្យក្នុងលោកបានទ្រព្យគាប់ចិត្តហើយ ( មិនឲ្យទាន ) ព្រោះតែសេចក្តីវង្វេង រមែងធ្វើនូវការសន្សំ ព្រោះជាប់ជំពាក់នឹងទ្រព្យ រឹងរិតតែប្រាថ្នានូវកាមទាំងឡាយឲ្យក្រៃលែងទៅទៀត ព្រះរាជាប្រាប់ប្រាមឈ្នះមនុស្សលើផែនដី មានសមុទ្រជាទីបំផុត នៅតែមិនស្កប់ដោយប្រទេសខាងអាយសមុទ្រ តែងប្រាថ្នានូវប្រទេសខាងនាយសមុទ្រទៀត ព្រះរាជាក្តី មនុស្សទាំងឡាយដទៃច្រើនក្តី តែមិនទាន់អស់តណ្ហាហើយ រមែងចូលទៅកាន់សេចក្តីស្លាប់ មានសភាពខ្វះខាត តែងមិនលះបង់នូវរាងកាយឡើយ ឈ្មោះថាសេចក្តីឆ្អែតឆ្អន់ដោយកាមទាំង-ឡាយមិនមានក្នុងលោកជាដាច់ខាត ។ ពួកញាតិរំសាយសក់ទាំង-ឡាយ ហើយកន្ទក់កន្ទេញនឹងអ្នកស្លាប់នោះថា " ឱហ្ន៎ ! ញាតិយើង

ស្លាប់ហើយ ″ យកបុគ្គលស្លាប់នោះរុំដោយសំពត់ នាំទៅដល់ជើងថ្ករ ហើយដុតក្នុងទីនោះ ។ បុគ្គលស្លាប់ហើយនោះ លះបង់ភោគៈទាំងឡាយ នៅតែសំពត់មួយ ត្រូវគេចាក់ដោយឈើស្នូល៍ ត្រូវភ្លើងឆេះ គ្រឿងការពារទាំងឡាយរមែងមិនមានដល់បុគ្គលស្លាប់ទេ មានតែពួកញាតិឬពួកសម្លាញ់ជាទាយាទ នាំយកទ្រព្យរបស់អ្នកស្លាប់នោះទៅ ចំណែកសត្វក៏ទៅតាមយថាកម្ម ទ្រព្យបន្តិចបន្តួចរមែងមិនទៅតាមបុគ្គលស្លាប់ឡើយ ពួកកូនប្រពន្ធទ្រព្យ និងដែន ក៏មិនជាប់ទៅតាមទេ ។ បុគ្គលមិនបានអាយុវែងព្រោះតែទ្រព្យទេ ទាំងមិនមែនលះបង់ជរាបាន ព្រោះតែទ្រព្យដែរ ។ អ្នកប្រាជ្ញពោលថា ″ **ជីវិតនេះតិចណាស់ មិនទៀងទាត់ មានសភាពប្រែប្រួលជាធម្មតា** ″ ពួកអ្នកស្តុកស្តម្ភក្តី អ្នកកំសត់ក្តី តែងពាល់ត្រូវនៅសេចក្តីស្លាប់ ទាំងពាលទាំងប្រាជ្ញ ក៏ពាល់ត្រូវដូច្នេះដែរ តែថាមនុស្សពាលរមែងដេកទាំងតក់ស្លុត ព្រោះសេចក្តីល្ងង់ ចំណែកអ្នកប្រាជ្ញ បើពាល់ត្រូវសម្ផស្សស្លាប់ ក៏មិនញាប់ញ័រឡើយ ព្រោះហេតុនោះ បុគ្គលបានដល់អរហត្តផល ជាទីបំផុតកិច្ចក្នុងលោកនេះដោយបញ្ញាណា បញ្ញានោះប្រសើរវិសេសជាងទ្រព្យ ។ ព្រោះតែខ្លួនមិនទាន់ដល់កិច្ចជាទីបំផុត ពួកជនរមែងធ្វើអំពើអាក្រក់ ក្នុងភពតូចនិងភពធំទាំងឡាយព្រោះតែសេចក្តីវង្វេង ។ បុគ្គលរមែងចូលទៅកាន់គភ៌ផង កាន់លោកខាងមុខផង ព្រោះដល់នូវភាពអន្ទោលទៅត ៗ គ្នា ។ បុគ្គលអប្បប្រាជ្ញា ជឿបុគ្គលនោះ ក៏ចូលទៅកាន់គភ៌ផង កាន់លោកខាងមុខផង ។ ចោរកាន់ធម៌អាក្រក់ដែលគេចាប់បាន ត្រូវគេបៀតបៀនព្រោះកម្មរបស់ខ្លួន តើយ៉ាងណា ? ពួកសត្វកាន់ធម៌អាក្រក់ លះលោកនេះទៅហើយ រមែង

ក្តៅក្រហាយព្រោះកម្មរបស់ខ្លួន ។ ក្នុងលោកខាងមុខយ៉ាងនោះដែរ ព្រោះតែកាមទាំងឡាយ ដ៏វិចិត្រ មានរសឆ្ងាញ់ និងជាទីរីករាយដល់ចិត្តដោយសភាវៈផ្សេង ៗ ។

បពិត្រមហារាជ ព្រោះហេតុនោះអាត្មាភាពឃើញទោសក្នុងកាមគុណទាំងឡាយហើយបានជាបួស មនុស្សទាំងក្មេង ទាំងចាស់ លុះបែកធ្លាយសរីរៈហើយ រមែងជ្រុះចុះដូចជាផ្លែឈើទាំងឡាយ ។

បពិត្រមហារាជ អាត្មាភាពបានយល់ច្បាស់នូវហេតុនេះថា សមណភាព ជាការប្រតិបត្តិមិនខុស ប្រសើរជាទីបំផុត ដូច្នេះបានជាបួស ។

បពិត្រព្រះករុណាម្ចាស់ ព្រមទាំងលោក-អ្នកអានទាំងឡាយ សេចក្តីដូចបានសរសេររៀបរាប់មកនេះ គឺខ្ញុំព្រះករុណា ខ្ញុំបាទបានដកស្រង់ដោយសង្ខេបចេញពី **បិដកលេខម្ភៃបួន** ( **២៤** ) ត្រង់ **រដ្ឋបាលសូត្រ** ទំព័រពីររយហុកសិបប្រាំបី ( ២៦៨ ) ។ ជាប្រវត្តិនិទានរៀបរាប់ បញ្ជាក់អំពីជីវិត **រដ្ឋបាលកុលបុត្រ** ។

ក្រោយពីបានយល់សេចក្តីនៃព្រះធម៌របស់ព្រះដ៏មានព្រះភាគ ហើយមានចិត្តជ្រះថ្លា លាមាតាបិតាចេញសាងផ្នួស បដិបត្តិព្រះធម៌លុះបានសម្រេចជាព្រះអរហន្តបុគ្គល ។ ព្រមទាំងបានលើកយក គាថាជាថេរដីការបស់លោកជាមួយមាតាបិតាក្តី ជាសំណួរចម្លើយជាមួយនឹងព្រះរាជាកោរព្យៈក្តីដើម្បីប្រគេន ជូន ព្រះករុណាម្ចាស់ ព្រមទាំងលោក-អ្នកអានទាំងឡាយ ឲ្យបានយល់ន័យសេចក្តី ពិតប្រាកដកំណត់ចែងសម្តែងក្នុងបិដក ដើម្បីបណ្តុះឧបនិស្ស័យ សេចក្តីជ្រះថ្លាការយល់ដឹង ឲ្យរឹងរិតតែប្រសើរឧត្តមវិសេសខ្ពស់ទៅទៀត ។ ហើយម្យ៉ាងទៀតដើម្បីឲ្យលោក-អ្នកដែល

មិនធ្លាប់បានអាន បានស្ដាប់ពាក្យពេចន៍ក្នុងបិដកសោះនោះ ឲ្យបានអានបានស្ដាប់ ទុកជាគោលខប្រតិបត្តិ និងឲ្យបានជាបញ្ញាពិចារណា តាមព្រះពុទ្ធដីកាផងនិងជាថេរដីការបស់ព្រះ **រដ្ឋបាល** ជាព្រះអរហន្តបុគ្គលផង ។ កាលបើព្រះករុណាម្ចាស់ ព្រមទាំងលោក-អ្នកអាន បានអានបានស្ដាប់ហើយ ក៏ហាក់ដូចជាបានយល់ចូលចិត្ត ទៅតាមដំណើររឿងរ៉ាវ និងសេចក្ដីបានច្រើនដែរហើយ ដូច្នេះខ្ញុំព្រះករុណា ខ្ញុំបាទ គ្រាន់តែសរសេរជាសំណួរ និងចម្លើយ ព្រមទាំងធ្វើនូវសេចក្ដីអធិប្បាយ បន្ថែមបញ្ជាក់ដើម្បីឲ្យបានកាន់តែច្បាស់មួយកំរិតទៀត ។



# សំណួរ - ចម្លើយ

**សំណួរ.** ព្រោះហេតុអ្វីបានជាកុលបុត្រ **រដ្ឋបាល** ចេញចាកផ្ទះទៅបួស ?

**ចម្លើយ.** បានជាកុលបុត្រ **រដ្ឋបាល** ចេញចាកផ្ទះទៅសាងផ្នួស ព្រោះបានស្តាប់ធម្មុទ្ទេសបួនប្រការ ដែលព្រះបរមសាស្ដាសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់សម្ដែង ។

**ស.** ពាក្យថា **ធម្មុទ្ទេស** បានសេចក្ដីដូចម្ដេច, សូមពន្យល់ឲ្យបានយល់ផង ?

**ច.** ពាក្យថា **ធម្មុទ្ទេស** បានសេចក្ដីថា ការលើកយកចំនួនធម៌ ឬមាតិកាធម៌នីមួយ ៗ មកសម្ដែងប្រាប់ឲ្យដឹង បញ្ជាក់ឲ្យយល់ទៅតាមការណ៍ពិត ឲ្យកើតគំនិតខាងផ្លូវចិត្ត ។

• • •

**ស**. ចុះធម៌ទាំងបួនប្រការ តើអ្វីខ្លះ, ចូរសរសេរអធិប្បាយប្រាប់ទាំងបួនមកមើល៍ ?

**ច**. ធម៌ទាំងបួនប្រការនោះគឺ ៖

**១. ឧបនីយតិ លោកោ អទ្ធុវោតិ**
**សត្វលោកមិនទៀង ត្រូវជរានាំចូលទៅកាន់ (មរណៈ) ;**

**២. អតាណោ លោកោ អនភិស្សរោ**
**សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹងឡើយ ;**

**៣. អស្សកោ លោកោ សព្វំបហាយ គមនីយន្តិ**
**សត្វលោកសុទ្ធតែគ្មានអ្វីជារបស់ខ្លួន ត្រូវតែលះរបស់ទាំងពួងដូច្នេះ ;**

**៤. ឩនោ លោកោ អតិត្តោ តណ្ហា ទាសោតិ**
**សត្វលោកមានតែសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ។**

ខ្ញុំបានស្តាប់បានអាន ពីខាងដើមមកហើយ ឃើញថាការស្តាប់ព្រះធម៌ទេសនាដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងក្នុងថុល្លកោដ្ឋិតនិគមនោះ ពុំមែនមានតែ **រដ្ឋបាល** កុលបុត្រម្នាក់ឯងទេ មានពួកព្រាហ្មណ៍, គហបតី, សេដ្ឋី ពួកជនទាំងឡាយច្រើនគ្នាណាស់ ដែលជ្រះថ្លាស្តាប់ព្រះធម៌របស់ព្រះអង្គ ក្រោយពេលស្តាប់ព្រះធម៌ចប់ ពួកបរិស័ទទាំងនោះ គេបាននាំគ្នាក្រាបបង្គំលាព្រះសាស្តាត្រឡប់ទៅលំនៅស្ថានវិញតែរៀង ៗ ខ្លួន មានតែ **រដ្ឋបាល** កុលបុត្រ ដែលមានចេតនាប្រាថ្នាសូមបួស ។

**ស**. តើការស្តាប់ព្រះធម៌មានការផ្សេងគ្នាដូចម្តេច ?

**ច**. មានការផ្សេងគ្នាទៅតាមឧបនិស្ស័យ និងសេចក្តីយល់

ដឹងទៅតាមអត្ថន័យ នៃការស្តាប់ដោយឡែកផ្សេង ៗ គ្នា ។

**ស**. សូមមេត្តា ជួយធ្វើអត្ថាធិប្បាយឲ្យបានក្បោះក្បាយ បន្ថែមសេចក្តីពន្យល់ដើម្បីឲ្យបានយល់ចូលចិត្តផងមើល៍ ?

**ច**. ការស្តាប់ព្រះធម៌នេះ ពុំមែនចេះតែបានយល់ចូលចិត្តជ្រួតជ្រាបឲ្យបានច្បាស់លាស់ស្មើដូចគ្នានោះទេ ព្រោះការសន្សំឧបនិស្ស័យនៃការស្តាប់មិនបានស្មើគ្នា ម្យ៉ាងវិញទៀតអត្ថន័យនៃព្រះធម៌ មានជម្រៅល្អិតសុខុមក្រៃលែងពេកណាស់ ន័យក្នុងព្រះធម៌ដែលព្រះមានព្រះភាគព្រះអង្គទ្រង់ត្រាស់សម្តែង សុទ្ធតែបញ្ជាក់អំពីសេចក្តីពិត បង្ហាញហេតុផលរបស់ជីវិត ទៅតាមសភាវពិតដែលផ្ទុយអំពីចិត្តគំនិតរបស់សត្វលោក ។ សត្វលោកពោរពេញដោយកិលេស ជាប់ជិតបិតនៅក្នុងចិត្តសន្តាន ច្រើនតែយល់ចូលចិត្ត ផ្ទុយស្រឡះបញ្ច្រាសពីព្រះធម៌ ដូចជាព្រះធម៌សម្តែងថាសត្វលោកមិនទៀងត្រូវជរានាំទៅដូច្នេះជាដើម តែទន្ទឹមនឹងភាពមិនទៀងនេះ សត្វលោកនាំគ្នាសំគាល់ថា ជាការចំរើនកើនឡើងទៅវិញ ។ ការផ្លាស់ប្តូររូបរាងកាយតាំងតែពីនៅក្នុងគភ៌ រហូតប្រសូតចេញមក រូបរាងកាយប្រែប្រួលជាទារកទារិកា ជាកុមារាកុមារី ជីវិតវ័យចេះតែអស់ទៅតាមកាលវេលា តែសត្វលោកវង្វេងនាំគ្នាយល់ចូលចិត្តទៅតាមការប្រកាន់ ថាជាការចម្រើនកើនឡើងនៃរូបរាងកាយទៅវិញ ។ ( សត្វលោកត្រូវតែលះរបស់ទាំងពួងហើយទៅ ) ការជាប់ជំពាក់ចិត្តស្អិតប្រកាន់ចំពោះវត្ថុកាម កិលេសកាម សត្វលោកញៀនញ៉ាម ហួងហែងប្រកាន់ថាជាការរីករាយសប្បាយ ទើបធ្វើឲ្យចិត្តងងឹត ស្រវឹងជ្រុបងងុលងប់ ពុំបានគិតដល់យល់ស្គាល់ពីសភាវពិត ថាជីវិតនឹងត្រូវលះបង់របស់ទាំងនោះទៅទេ ។

ចំណែក **រដ្ឋបាល** កុលបុត្រ ជាអ្នកមានឧបនិស្ស័យខ្ពស់ ជាអ្នកបានស្ដាប់ព្រះធម៌ ប្រកបដោយបញ្ញា បានពិចារណាយល់ច្បាស់ ចូលចិត្តទៅតាមសេចក្ដីពិត ទើបប្រាថ្នាចេញចាកផ្ទះទៅបួស ។

**ស**. បើដូច្នេះមានតែអ្នកបួសទេឬ ដែលអាចបដិបត្តិតាមព្រះធម៌បានសម្រេច ?

**ច**. ពុំមែនសម្រាប់តែអ្នកបួសទេ ព្រះធម៌ដែលព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់សម្ដែង គឺជាសាធារណៈសម្រាប់សត្វលោក មិនថាសត្វប្រភេទណា សូមឲ្យតែសត្វនោះមានសោតប្រសាទស្អាតល្អទទួលស្ដាប់ចាប់យកសម្លេងនៃព្រះធម៌ ព្រមទាំងឈោងដៃគឺសទ្ធា ក្រសោបក្ដាប់យកព្រះធម៌មកប្រតិបត្តិទៅតាមសមត្ថភាព និងឧបនិស្ស័យតែរៀង ៗ ខ្លួន គ្រាន់តែថាភេទអ្នកបួសចាត់ថាជាឧត្ដមភេទ ជាភេទវាលស្រឡះ មិនចង្អៀតចង្អល់ ជាប់ជំពាក់ច្រើនដូចជាភេទគ្រហស្ថ អ្នកគ្រប់គ្រងផ្ទះ ដូច្នេះភេទជាអ្នកបួស បើមានចិត្តប្រតិបត្តិតាមព្រះធម៌ពិត ៗ ឃើញថាជាការងាយស្រួលជាជាងភេទជាគ្រហស្ថ ។

**ស**. ខ្ញុំនៅមានចម្ងល់ សូមសួរបញ្ជាក់លោកទៀត ត្រង់ដែលព្រះ **រដ្ឋបាល** គង់លើអាសនៈក្នុងចន្លោះមាសនិងប្រាក់ ក្នុងពេលនោះព្រះបិតាលោកបានរៀបរាប់អំពីទ្រព្យសម្បត្តិ និងបានពោលពាក្យអង្វរករ សូមឲ្យព្រះ **រដ្ឋបាល** លាសិក្ខាមកកាន់ភេទគ្រហស្ថវិញ ព្រះ **រដ្ឋបាល** បានប្រាប់ញោមថា ឲ្យប្រមូលទ្រព្យផ្ទុកដោយរទេះយកទៅចោលក្នុងទន្លេគង្គា, ខ្ញុំសូមសួរថា ពាក្យដែលព្រះ **រដ្ឋបាល** ប្រាប់ដល់បិតាលោកដូច្នោះ ពុំមែនជាសម្ដី

ទ្រគោះបោះបោក បញ្ចោះបន្សោក ពេកទៅហើយទេឬ ?

**ច.** ពិតមែនហើយ បើយើងគ្រាន់តែស្ដាប់ តាមសាមញ្ញភាសា យើងប្រាកដជាយល់ថាជាពាក្យទ្រគោះបោះបោកពិតមែន តែយើងត្រូវយល់ថា ព្រះ **រដ្ឋបាល** រូបនេះលោកពុំមែនឋិតនៅក្នុងភាពជាបុថុជ្ជនទៀតទេ លោកជាព្រះអរិយៈ ថ្នាក់ជាព្រះអរហន្តបុគ្គលទៅហើយ លោកបានប្រតិបត្តិកំចាត់បង់ដុតកំទ្បោច ធ្វើឲ្យរីងស្ងួតនូវកិលេសាសវៈ ព្រមទាំងសំយោជនៈ [១] រីងស្ងួតរបូតអស់រសោះចេញពីសន្ដានលោកគ្មានធូលីគឺ **រាគៈ**, **ទោសៈ**, **មោហៈ** សូម្បីតែបន្តិចបន្តួចក៏ទេដែរ ដូច្នេះថេរដីកានៃព្រះ **រដ្ឋបាល** គឺជាពាក្យពិត ហូរចេញពីចិត្តប្រកបដោយករុណាថ្លាបរិសុទ្ធផូរផង់ក្នុងការទូន្មានបិតាលោកឲ្យយល់ស្គាល់ទៅតាមហេតុផលពិត ។ បិតាលោក ដែលខំព្យាយាមហាមឃាត់លោក មិនឲ្យបានទៅបួសក្ដី ព្រមទាំងបានខំរកវិធីគ្រប់បែបយ៉ាង ធ្វើឲ្យលោកលាចាកភេទបួសមកជាគ្រហស្ថដើម្បីបរិភោគកាមវិញក្ដី ក៏ព្រោះតែទឹកចិត្តជាប់ជំពាក់ក្រវល់ក្រវាយចំពោះត្រកូលទ្រព្យសម្បត្តិនោះឯងដែលជាហេតុធ្វើឲ្យកើតទោមនស្ស ថ្នាំងថ្នាក់អន់អាក់ ខ្សឹកខ្សួលសោកសៅ ក្ដៅក្រ - ហល់ក្រហាយ មិនឲ្យមានចិត្តសប្បាយទៅកើត ។ ដូច្នេះការពោលទៅតាមហេតុផលពិតដែលហូរចេញអំពីទឹកចិត្តនៃព្រះអរហន្តដូចជាព្រះ **រដ្ឋបាល** ពុំបានចាត់ថាជាសម្ដីគ្រោតគ្រាតទេ ។

---

( ១ ) សំយោជនៈ ស័ង-យោជៈ នៈ សំ. បា. ( ន. ) (សំយោជន ឬ សញ្ញោជន) កិលេសជាគ្រឿងប្រកបចិត្ត គឺកិលេសរឹងត្អឹងជាគ្រឿងទាក់ទាក់រូបរឹត ដែលអាស្រ័យនៅនឹងចិត្ត...

**ស**. ពាក្យថា បុថុជ្ជន និង អរិយជន មានសេចក្ដីផ្សេងគ្នាដូចម្ដេច តើគេអាចសម្គាល់បានដោយប្រការយ៉ាងណា ?

**ច**. ពាក្យថា បុថុជ្ជន បានដល់ជនមានកិលេសក្រាស់ ជាអ្នកមានសេចក្ដីសៅហ្មង ឬថាសត្វលោកក្រៅពីអរិយបុគ្គលប្រាំបីពួក ពាក្យថា អរិយៈ ប្រែថា ប្រសើរ ត្រឹមត្រូវ សុភាពរៀបរយ មានបែបបទល្អ ស្លូតត្រង់ ដែលឥតទោស ។ **អរិយជន** : ជនដ៏ប្រសើរ ជនមានតម្លៃ អ្នកដែលមានធម៌ ជនដែលបានសម្រេចលោកុត្តរធម៌ តាំងពីសោតាបតិមគ្គ សោតាបត្តិផល រៀងជាលំដាប់រហូតដល់អរហត្តមគ្គ អរហត្តផល ។

បុថុជ្ជន និង ព្រះអរិយជន បើយើងចោលភ្នែកក្រឡេកមើលត្រឹមតែរូបរាងកាយខាងក្រៅ ក៏មិនខុសប្លែកពីគ្នាទេ ហើយយើងក៏ពុំអាចយល់ស្គាល់បានថា ជនណាជាបុថុជ្ជន ឬជនណាជាព្រះអរិយជនដែរ សូម្បីតែបិតាព្រះ **រដ្ឋបាល** ក៏ពុំអាចដឹងថាកូនរបស់ខ្លួនជាអរិយជនថ្នាក់អរហន្តបុគ្គលផង ។ ប៉ុន្តែបើពោលតាមផ្លូវចិត្តពិតជាផ្សេងដោយឡែកពីគ្នាប្រាកដហើយ **បុថុជ្ជន** ជាអ្នកធ្ងន់ដោយកិលេស មានរាគៈ ទោសៈ មោហៈ ព្រមទាំងចំណងចងឆ្វាក់ទាក់ចិត្តគ្រប់ប្រការសូម្បីតែចំណងណាមួយ ក៏មិនទាន់លះកាត់បានទេ ជាអ្នកនៅមានចិត្តញាប់ញ័រ ដោយលោកធម៌[១]ទាំងប្រាំបីប្រការ ពេលមានអារម្មណ៍ជាទីប្រាថ្នាត្រូវចិត្តពេញចិត្ត( ឥដ្ឋារម្មណ៍ )

---

(១) លោកធម៌ទាំង ៨ ប្រការ : មានលាភ ១, គ្មានលាភ ១, មានយស ១, គ្មានយស ១, និន្ទា ១, សរសើរ ១, សុខ ១, ទុក្ខ ១ ។

(**សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត នវមភាគ ទំព័រ ១៥**)

ក៏ធ្វើឲ្យចិត្តស្ទុះលោតប៉ោងឡើងទៅតាមអារម្មណ៍នោះ គឺធ្វើឲ្យចិត្តសប្បាយរីករាយ ភ្លើតភ្លើនស្រើបស្រាល តែបើជួបប្រទះប៉ះទង្គិចនឹងអារម្មណ៍មិនជាទីប្រាថ្នា មិនជាទីពេញចិត្ត ( អនិដ្ឋារម្មណ៍ ) ក៏ក្លាយទៅជាខឹងថ្នាំងថ្នាក់ អាក់អន់ស្រពន់ចិត្ត ខ្សឹកខ្សួលសោកសៅក្តៅក្រហាយ ចេញមកតាមកាយវាចា ឲ្យឃើញបានយ៉ាងងាយ ។

ចំណែកព្រះអរិយបុគ្គល ថ្នាក់ជាព្រះអរហន្ត សូម្បីមានអារម្មណ៍ជាឥដ្ឋារម្មណ៍ក្តី អនិដ្ឋារម្មណ៍ក្តី មកពាល់ត្រូវក្នុងចិត្ត ក៏ចិត្តលោកនៅស្មើ មិនចុះមិនឡើង ឥតមានប៉ោងផុសស្ទុះទៅតាមអារម្មណ៍នោះ ៗ ឡើយ ដូច្នេះកាយឥន្ទ្រិយលោកស្រគត់ស្រគំសមរម្យគួរជាទីជ្រះថ្លា ។ បើពោលឲ្យខ្លីបានដល់អ្វី ៗ ជាសេចក្តីសៅហ្មង ជាចំណងចងឆ្នាក់ដែលបុថុជ្ជននៅមាន ព្រះអរហន្តបុគ្គលលោកបានកាត់បង់ បំបាក់ជម្រុះចោលអស់អំពីខន្ធសន្តានដោយឥតសេសសល់សូម្បីតែបន្តិចបន្តួចឡើយ ។

**ស**. ចុះពាក្យថា ចំណងគឺជាអ្វី ?

**ឆ**. ពាក្យថា " **ចំណង** " បានដល់កិលេសទាំងពួង ជាគ្រឿងចងសត្វលោកមិនឲ្យចេញផុតចាកភពទៅបាន គឺធ្វើឲ្យសត្វលោកអន្ទោលវិលវល់ កើតចាស់ឈឺស្លាប់នៅក្នុងសង្សារវដ្តពុំអាចគេចផុតរត់ឲ្យរួចទៅបាន ។

**ស**. ស្តាប់ទៅហើយធ្វើឲ្យច្របូកច្របល់ កាន់តែពិបាកយល់ទៅ ៗ ដូចពាក្យថា កិលេសសជាគ្រឿងចងសត្វលោក បានដល់អ្វីខ្លះទៅ ហើយកិលេសសទាំងនោះចងចំពោះតែបុថុជ្ជន មិនចងព្រះអរិយជនផងទេឬ ?

**ឆ**. កិលេសចាត់ថាជាចំណងចងសត្វលោកនោះ មាន

ច្រើនឈ្មោះ ច្រើនប្រការ ដូចជាតណ្ហាមួយរយប្រាំបី ( ១០៨ ), កិលេសមួយពាន់ប្រាំរយ ( ១៥០០ ) ចែកចេញជាឈ្មោះមានគន្ថៈ, យោគៈ, សំយោជនៈ, អាសវៈ, អនុសយៈ និងមានជាច្រើនឈ្មោះទៀត សុទ្ធតែជាហេតុធ្វើចិត្តឲ្យសៅហ្មងកករល្អក់ ប្រឡាក់ប្រឡូស ធ្វើចិត្តឲ្យធ្លាក់ជំពាក់ប្រទាក់ប្រកបចងរុំព័ន្ធព័ទ្ធ ដេកត្រាំឲ្យសើមជោក ចងគ្រៀកងាកចេញមិនរួច ។ កិលេសនេះ មិនមែនចងតែបុថុជ្ជនទេ សូម្បីតែព្រះអរិយជនពួកខ្លះក៏នៅជាប់ចំណងដែរ។

**ស.** ខ្ញុំស្តាប់ទៅដូចចេះតែមានជម្រៅទៅ ឯក្បាលរបស់ខ្ញុំចេះតែតឹងទៅដែរ គ្រាន់តែតណ្ហាមួយរយប្រាំបី ( ១០៨ ), កិលេសមួយពាន់ប្រាំរយ ( ១៥០០ ) មិនដឹងថាឲ្យយល់ម្តេចកើត សូមលោកចោះយកតែចំណុចខ្លះ មកអធិប្បាយប្រៀបធៀបឲ្យបានយល់ចូលចិត្ត អំពីការលះកាត់ចំណងកិលេសរបស់បុថុជ្ជន និងព្រះអរិយៈឲ្យឃើញថាផ្សេងគ្នាដូចម្តេច ?

**ច.** ពិតមែនហើយ បើតាមព្រះពុទ្ធដីកា ជាវោហារទេសនារបស់ព្រះអង្គ ឃើញថាកិលេសតណ្ហាមានច្រើនប្រការ ទៅតាមឧបនិស្ស័យសត្វដែលប្រាថ្នាស្តាប់យកសេចក្តី អត្ថន័យជាពិស្តារ តែចំពោះសត្វណាមានបញ្ញា យល់ដឹងឆាប់ក៏ព្រះអង្គទ្រង់សម្តែងជាសង្ខេបដោយបទខ្លី ៗ ដែរ ដូចជាពាក្យថា " **កិលេស** " បើបំព្រួញឲ្យខ្លីនៅសល់តែបីគឺ ៖ **រាគៈ ទោសៈ មោហៈ** នេះឯង ដែលជាមូល ជាឫសគល់បណ្តុះបង្កើតឲ្យមានកិលេសផ្សេង ៗ ទៀតបាន ។

ការលះបង់កិលេស និងការផ្តាច់កាត់ចំណង មានការផ្សេងដោយឡែកពីគ្នា ។ បុគ្គលជាបុថុជ្ជន ទោះបីជាខំព្យាយាមបំពេញកុសល មានថ្នាក់ទាន សីល ភាវនា ជាគ្រឿងកំចាត់បង់

អកុសលកិលេសនោះ ៗ ក៏បានត្រឹមតែមួយពេល មួយខណៈប៉ុណ្ណោះឯង ។ ដូចជានៅពេលបំពេញទាន រក្សាសីលចម្រើនភាវនា ក៏ធ្វើឲ្យអកុសលកិលេសពួកខ្លះមានមច្ឆរិយៈ សេចក្ដីកំ - ណាញ់ស្រកស្រុត ទោសៈការប្រទូស្តខឹងថ្នាំងថ្នាក់ មោហៈភាពវង្វេងថមថយបាត់ទៅ ។ មួយខណៈដែលកំពុងចាត់ចែងការកុសលហ្នឹង សូម្បីព្រះយោគាវចរបុគ្គលដែលបានចម្រើនភាវនាបានជាអប្បនាសមាធិចូលកាន់ឈាន មានបឋមជ្ឈានជាដើមទៅ តែនៅជាលោកិយឈាន កំចាត់កិលេសបានត្រឹមតែខណៈចិត្តដែលកំពុងមានឈានប៉ុណ្ណោះ ។ បន្ទាប់អំពីនោះទៅ កិលេសមានឱកាសកើតមកវិញដដែល ពោលឲ្យខ្លីងាយស្ដាប់ទៅ លោកិយជនឬបុថុជ្ជន មិនទាន់មានសម្ថភាពអាចកំចាត់បង់កិលេសណាមួយបានជាសមុច្ឆេទ គឺឲ្យដាច់ស្រឡះនៅឡើយទេ ។

ចំណែកព្រះអរិយបុគ្គល ទៅតាមលំដាប់ថ្នាក់តាំងពីសោតា - បន្នបុគ្គលឡើងទៅ កិលេសណាដែលលោកបានលះបង់កាត់ផ្ដាច់ហើយ កិលេសនោះមិនអាចកើតមកវិញទៀតទេ ប្រៀបដូចជាគេគាស់រំលើងដើមឈើ តាំងពីឫសគល់ដុតកម្ទេចមិនឲ្យមានសេសសល់ មិនអាចមានពូជកើតទៀតបាន ។

**ស**. បុគ្គលជាបុថុជ្ជនមានប៉ុន្មានពួក, បុគ្គលជាព្រះអរិយចែកចេញជាប៉ុន្មានពួក ?

**ច**. បុគ្គលជាបុថុជ្ជន មានបួនពួកគឺ ៖

១. បាបបុថុជ្ជន ;

២. កល្យាណបុថុជ្ជន ;

៣. ពាលបុថុជ្ជន ;

• • •

៤. បណ្ឌិតបុថុជ្ជន ។

ចំណែកព្រះអរិយបុគ្គល មានបួនគឺ ៖

១. សោតាបន្នបុគ្គល ;

២. សកិទាគាមិបុគ្គល ;

៣. អនាគាមិបុគ្គល ;

៤. អរហន្តបុគ្គល ។

បើចាត់ទៅតាមមគ្គ និងផលមានប្រាំបីគឺ ៖ សោតាបត្តិមគ្គ ១, សោតាបត្តិផល ១, សកិទាគាមិមគ្គ ១, សកិទាគាមិផល ១, អនាគាមិមគ្គ ១, អនាគាមិផល ១, អរហត្តមគ្គ ១, អរហត្តផល ១ ។

**ស**. ចំពោះបុថុជ្ជនទាំងបួនពួក ខ្ញុំមិនឆ្ងល់ទេ ពីព្រោះទោះបីជាយ៉ាងណា បុថុជ្ជនសុទ្ធតែជាអ្នកនៅមានបាបបុណ្យលាយឡំគ្នា ខ្ញុំមានចម្ងល់ចំពោះតែព្រះអរិយជនទាំងប្រាំបីពួក ពេលខ្លះចាត់ថាជាបុគ្គល, ពេលខ្លះចាត់ថាជាមគ្គ, ពេលខ្លះចាត់ថាជាផល ធ្វើឲ្យស្តាប់ច្របូកច្របល់យល់មិនបាន សូមពន្យល់ឲ្យចូលចិត្តផ្ចិតសេចក្តីឲ្យបានច្បាស់ផងមកមើល៍ ?

**ឆ**. ត្រង់ដែលហៅថាជាបុគ្គល ដូចពាក្យថា សោតាបន្នបុគ្គល ជាលំដាប់ដល់អរហន្តបុគ្គល យ៉ាងនេះជាដើម គឺជាវោហារបញ្ញត្តិ ជាពាក្យសម្តីដើម្បីពោលស្តី និយាយឲ្យងាយប្រាស្រ័យ ទាក់ទងសម្គាល់ហៅ ស្តាប់ឆាប់យល់ ស្រួលស្គាល់ទៅតាមឈ្មោះ ឬថ្នាក់នៃមគ្គនិងផល ឬសំដៅដល់បុគ្គលអ្នកប្រតិបត្តិបានសម្រេចទៅតាមលំដាប់មគ្គនិងផល ជាលោកបញ្ញត្តិពុំមែនជាបរមត្ថបញ្ញត្តិទេ ។

ដែលចាត់ថាជាមគ្គ គឺសំដៅឬហៅទៅតាមលំដាប់មគ្គ ពាក្យថាមគ្គនេះបានដល់ បដិបទាជាគ្រឿងកំចាត់បង់នូវកិលេសទៅតាមលំដាប់ថ្នាក់មាន ពីសោតាបត្តិមគ្គរហូតដល់អរហត្តមគ្គ ។ ដែលចាត់ជាផល គឺសំដៅដល់ផលដែលត្រូវបាន បន្ទាប់ពីមគ្គណាមួយបានកំចាត់បង់កិលេសរលត់ទៅហើយ ផលក៏កើតជាលំដាប់គ្នាភ្លាម ដូចមានបទសូត្រក្នុងធម្មគុណថា ( **អកាលិកោ** ) ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយ - ផលក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ ដូច្នេះហើយទើបបានហៅថា សោតាបត្តិផល ជាលំដាប់ដល់អរហត្តផល មគ្គផលទាំងពីរនេះ ចាត់ថាជាបរមត្ថបញ្ញត្តិ ។

**ស**. សូមអធិប្បាយអំពីពាក្យថា ព្រះអរិយបុគ្គលលោកកំចាត់បង់កិលេសតាមលំដាប់ថ្នាក់ តើកំចាត់ដូចម្តេច គេអាចសំគាល់បានយ៉ាងណាថាបុគ្គលនេះជាព្រះអរិយបុគ្គលថ្នាក់នេះ ជាព្រះអរិយបុគ្គលថ្នាក់នោះ តើមានអ្វីជាខ្នាតជារង្វាស់ ?

**ច**. សំណួរនេះ ពុំមែនជាការងាយដោះស្រាយអធិប្បាយនោះទេ ព្រោះការយល់ដឹងរបស់យើងជាបុថុជ្ជន មិនមែនជាវិស័យនៃព្រះអរិយជនឡើយ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ពុំមែនហួសនិស្ស័យដល់ការស្តាប់ មិនយល់មិនចូលចិត្តនោះទេ ឲ្យតែព្យាយាមសិក្សាសូត្ររៀនអានស្តាប់ជារឿយ ៗ ទៅ ក៏គង់នឹងបានយល់ចូលចិត្តជាមិនខាន បើមិនច្រើនក៏គង់បានខ្លះ ។ ដូច្នេះក្នុងសំណួរនេះ ខ្ញុំសូមលើកពាក្យថា ចំណងជាគ្រឿងចងសត្វលោក មកបញ្ជាក់ជាមុនសិន យើងធ្លាប់ស្តាប់ដឹងមកហើយ ថាកិលេសជាចំណង ប៉ុន្តែកិលេសមានច្រើនណាស់ ដូច្នេះខ្ញុំសូមលើកយកត្រឹមតែសំយោជនៈ

ដប់យ៉ាង មកជាខ្នាតជារង្វាស់ សម្រាប់ឆ្លុះបញ្ចាំងឲ្យយល់ស្គាល់ដឹងថា បុគ្គលបែបណាដែលឋិតនៅក្នុងសភាពជាព្រះអរិយជន ហើយព្រះអរិយជននោះតើមានការលះបង់កិលេស តាមលំដាប់ថ្នាក់ផ្សេងដោយឡែកពីគ្នាយ៉ាងណា ។ មានសំយោជនៈដប់ប្រការនេះឯង ជាគ្រឿងសំអាងសំគាល់ឲ្យបានដឹងយល់ ។

# សំយោជនៈដប់ប្រការ

១. **សក្កាយទិដ្ឋិ** ប្រកាន់ថាកាយនេះជារបស់ខ្លួន ;
២. **វិចិកិច្ឆា** សេចក្តីសង្ស័យមិនចេះដាច់ស្រេច ;
៣. **សីលព្វតបរាមាសៈ** ការប្រកាន់សីលនិងវត្ត ;
៤. **កាមច្ឆន្ទៈ** សេចក្តីពេញចិត្តក្នុងកាម ;
៥. **ព្យាបាទៈ** ការចងអាឃាតព្យាបាទ ;
៦. **រូបរាគៈ** តម្រេកក្នុងរូប ;
៧. **អរូបរាគៈ** តម្រេកក្នុងអរូប ;
៨. **ឧទ្ធច្ចៈ** ចិត្តរវើរវាយ ;
៩. **មានះ** ចិត្តរឹងត្អឹង ;
១០. **អវិជ្ជា** មិនយល់មិនស្គាល់កងទុក្ខ ។

ពាក្យថា **សំយោជនៈ** បានដល់កិលេសចាក់ស្រែះនៅក្នុងសន្តានសត្វលោក ឬថាជាខ្សែ ជាចំណងតែងចងឆ្វាក់ទាក់សត្វលោកមិនឲ្យងាករួចផុតបានអំពីសង្សារវដ្តនេះ ហើយក៏ជាចំណងដ៏ស្វិតស្វាញ ដែលសត្វទាំងឡាយមិនងាយនឹងស្រាយកាត់ចេញបានផង ។ ចំណងដែលចងឆ្វាក់ហើយពុំងាយស្រាយបានគឺកិលេស

នេះ តែងតែចងឆ្វាក់ទាក់សត្វរួបរឹតដិតជាប់មិនអាចងាកខ្លួនចេញបាន ។

## កំណាព្យ បទពាក្យប្រាំពីរ*

**ខ្សែលួសឬវល្លិ៍រួមខ្សែព្ធ**
**ដែលមនុស្សបង្កបង្កើតវេញ**
**ចងដំរីបានយ៉ាងណាមិញ**
**តែងាយស្រាយចេញកាត់វិញបាន ។**
**រីឯចំណងគឺកិលេស**
**ដែលចងចាក់ស្រែះចិត្តសន្តាន**
**នៃសព្វសត្វលោកគ្រប់រូបប្រាណ**
**ពុំងាយស្រាយបានសោះឡើយណា។**

សំយោជនៈទាំងដប់ប្រការនេះ បុគ្គលជាបុថុជ្ជនទោះបីជាពួកណាក៏ដោយ មិនអាចលះកាត់បានតែប្រការណាមួយឡើយ ដូច្នេះ បុគ្គលជាបុថុជ្ជន គឺជាអ្នកធ្ងន់ដោយកិលេសចាក់ស្រែះជំពាក់ដោយចំណង ឆ្លងមិនផុតរត់មិនរួចអំពីភពទាំងបី ។

ចំណែកព្រះអរិយជនរាប់តាំងពីថ្នាក់ដំបូងគឺ សោតាបន្នបុគ្គល បានដល់បុគ្គលអ្នកប្រតិបត្តិបានសម្រេចសោតាបត្តិមគ្គ សោតាបត្តិ-

* ដកស្រង់ចេញពីសៀវភៅ ( មរណកថា ) ឆ្នាំ ២០០៦

ផល ។ ពាក្យថា " សោតា " បានដល់ក្រសែហូរទៅកាន់ព្រះនិព្វាន ក្រសែចិត្តខិតជិតតោងឈោងយកព្រះនិព្វាន ជាដំបូងថ្នាក់ទីមួយ ក្នុងការសម្រេចមគ្គ ជាគ្រឿងកំចាត់បង់សំយោជនៈបានបីខាងដើម គឺលះចោល ៖

• **សក្កាយទិដ្ឋិ** មិនប្រកាន់ហួងហែងជាប់ជំពាក់ជាមួយនឹងរូបរាងកាយ ឬបញ្ចក្ខន្ធនេះទៀតទេ ចិត្តរបស់សោតាលោកមានបញ្ញាថ្លាបរិសុទ្ធ ពិចារណាឃើញប្រចក្សច្បាស់ថា អ្វី ៗ ទាំងអស់ក្នុងលោកនេះ មានការកើតឡើងហើយរលត់ទៅវិញជាធម្មតា ។ បុគ្គលជាសោតាបន្ន លោកតែងបន្លឺវាចាថា ៖

**យំកិញ្ចិ សមុទយ ធម្មំ សព្វន្តំ និរោធ ធម្មន្តិ**
**របស់ណាមានកិរិយាកើតឡើងហើយ**
**របស់នោះមានកិរិយារលត់ទៅវិញជាធម្មតា ។**

• **វិចិកិច្ឆា** ការសង្ស័យមិនដាច់ស្រេច អល់អែករារែកក្នុងចិត្តចំពោះហេតុបច្ច័យជាអតីត អនាគត បច្ចុប្បន្ន ចំពោះគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ឥតមានសល់នៅក្នុងចិត្តសោតាបន្នបុគ្គលទៀតទេ លោកមានសទ្ធាជឿជាក់គុណព្រះរតនត្រ័យយល់ស្គាល់ហេតុបច្ច័យច្បាស់ពិត ឥតមានមិច្ឆាទិដ្ឋិ មច្ឆរិយៈ ជាអ្នកបំពេញទានមានសីលផូរផង់ ។

• **សីលព្វតបរាមាសៈ** ការស្ទាបអង្អែលសីលនិងវត្ត ខ្ញុំសូមបញ្ជាក់អំពីពាក្យថា សីលព្វតបរាមាសៈ ដើម្បីឲ្យងាយចូលចិត្តសិន ពាក្យនេះចែកចេញជាពីរបទ ៖ សីលព្វតៈ បានដល់ទម្លាប់ប្រតិបត្តិខុសទំនង ដែលអ្នកប្រព្រឹត្តជឿថាជាផ្លូវបរិសុទ្ធ នាំឲ្យរួចចាកទុក្ខ,

បរាមាសៈ ការស្ទាបស្ទង់ប្រយុងចិត្តទៅលើការប្រព្រឹត្តដែលខុសទំនងនោះ ការប្រកាន់ ។ រួមសេចក្តីមក បានដល់ការប្រកាន់ស្អិតជាប់ចិត្តទៅលើការប្រតិបត្តិខុស ជឿខុសប្រាសចាកហេតុផលពិត ។ ព្រះសោតាបន្ន លោកមានការជឿទៅលើកម្មនិងផលរបស់កម្មតែម្យ៉ាង ដែលជាមាគ៌ាបដិបត្តិត្រឹមត្រូវតាមសេចក្តីពិត មិនងាកចិត្តទៅរកមង្គលភ្ញាក់ផ្អើល មិនតក់ស្លុតរន្ធត់ខ្លាចរត់ទៅបួងសួងបន់ស្រន់ ឬជឿវត្ថុដទៃក្រៅពីគុណព្រះរតនត្រ័យនេះទៀតទេ ។

ដូច្នេះពាក្យថាអរិយបុគ្គលថ្នាក់សោតានេះ គឺលោកបានកំចាត់បង់ជម្រុះចោលសំយោជនកិលេសបីប្រការ ដូចបានពោលរួចមកហើយ មិនឲ្យមានសេសសល់ឬមិនអាចកើតបានក្នុងខន្ធសន្តានរបស់លោកទៀតឡើយ ចិត្តរបស់លោកទាំងឡាយនោះឥតមានងាករេទៅរកបាបអកុសលទៀតទេ មានតែព្រះនិព្វានជាអារម្មណ៍របស់ចិត្ត ។ ការប្រតិបត្តិដើម្បីកំចាត់កិលេស ជាលំដាប់ថ្នាក់ជាបន្តទៅទៀត រហូតបានអស់សំយោជនៈជាសេក្ខបុគ្គល ចាត់ជាបុគ្គលនៅមានការសិក្សាប្រតិបត្តិក្នុងការកំចាត់បង់ និងកាត់ផ្តាច់ចំណងឲ្យអស់ពីខន្ធសន្តាន លោកមានដំណើរជីវិតប្រព្រឹត្តទៅកាន់ព្រះនិព្វានមិនត្រឡប់កាន់អបាយភូមិដូចបុថុជ្ជនទៀតទេ កើតក្នុងលោកមនុស្ស ឬទេវតាតែមួយជាតិខ្លះ ចេញពីត្រកូលទៅកាន់ត្រកូលតែពីរឬបីជាតិខ្លះ ឬកើតក្នុងលោកមនុស្សឬទេវតាតែប្រាំពីរជាតិទៀតប៉ុណ្ណោះលោកនឹងបរិនិព្វាន លែងមានជាតិកំណើតទៀតហើយ ។

បុគ្គលដែលបានប្រតិបត្តិបានសម្រេចដល់ថ្នាក់សោតា ឈ្មោះថាបានសម្បត្តិដ៏ឧត្តមក្រៃលែងជាជាងសម្បត្តិស្តេចចក្រពត្រាធិរាជ

ទេវតាឥន្ទ្រព្រហ្ម ព្រោះជាសម្បត្តិដែលមានដំណើរឈមឆ្ពោះទៅកាន់ព្រះនិព្វាន មិនមានទុក្ខកង្វល់ទៀតឡើយ ។

សកទាគាមិបុគ្គល បានដល់ព្រះអរិយថ្នាក់ទីពីរ លោកប្រតិបត្តិបានសម្រេចលោកុត្តរធម៌គឺ សកទាគាមិមគ្គសកទាគាមិផល អាចកាត់ផ្តាច់សំយោជនកិលេស បានបីប្រការដូចព្រះសោតាបន្នដែរ តែលោកអាចធ្វើនូវ រាគៈ ទោសៈ មោហៈ ឲ្យបានស្រាលស្តើង លោកមកកើតក្នុងកាមធាតុនេះតែមួយជាតិទៀតប៉ុណ្ណោះនឹងបានសម្រេចព្រះនិព្វានហើយ ។

អនាគាមិបុគ្គល បានដល់ព្រះអរិយថ្នាក់ទីបី លោកប្រតិបត្តិបានសម្រេចលោកុត្តរធម៌ជាអនាគាមិមគ្គអនាគាមិផល អាចកាត់ផ្តាច់សំយោជនកិលេសបានប្រាំប្រការ គឺបីខាងដើមនិងពីរប្រការបន្ថែមទៀត ។

- **កាមច្ឆន្ទៈ** ការពេញចិត្តក្នុងកាម ការមានតម្រេកត្រេកត្រអាល ស្រើបស្រាលប៉ុនប៉ងបំណងប្រាថ្នាក្នុងកាមគុណទាំងឡាយក្តី ។
- **ព្យាបាទៈ** ចិត្តទោមនស្សថ្នាំងថ្នាក់ ប្រទូស្តចងអាឃាតព្យាបាទ ចំពោះសត្វសង្ខារក្តី ព្រះអនាគាបានកំចាត់បង់អស់ពីខន្ធសន្តានឥតមានសេសសល់ទៀតឡើយ ។

ពាក្យថា អនាគាមិ បានន័យថាមិនត្រឡប់មកកើតក្នុងលោកនេះទៀតទេ កាលបើអស់ព្រះជន្មពីមនុស្សនេះ លោកទៅកើតក្នុងសុទ្ធាវាសព្រហ្ម ហើយបរិនិព្វាននៅក្នុងទីនោះឯង ។

អរហន្តៈ បានដល់ព្រះអរិយបុគ្គល ដែលបានសម្រេចអរហត្តមគ្គ អរហត្តផល ជាលោកុត្តរធម៌ខ្ពស់បំផុត ជាអសេក្ខ-

បុគ្គល អស់ការសិក្សាបដិបត្តិកំចាត់កិលេសទៀតហើយ ព្រោះលោកបានផ្តាច់បង់សំយោជនកិលេសអស់ទាំងដប់ហើយគឺ ប្រាំប្រការខាងដើមនិងប្រាំប្រការទៀតគឺ ៖

- **រូបរាគៈ** ការត្រេកត្រអាលជាប់ចិត្ត ពេញចិត្ត ចំពាក់ចិត្តក្នុងភូមិឋានមនុស្ស ទេវតា ព្រហ្មមានរូបក្តី ;
- **អរូបរាគៈ** ការជំពាក់ជាប់ចិត្តក្នុងភពភូមិឋាន ព្រហ្មគ្មានរូបក្តី ;
- **ឧទ្ធច្ចៈ** ចិត្តរវើរវាយ អណ្តែតអណ្តូង រសាប់រសល់ ក្រវល់ក្រវាយ ;
- **មានះ** ចិត្តរឹងត្អឹងប្រកួតប្រកាន់ លើកដាក់ឋានៈទាបខ្ពស់យ៉ាងនេះយ៉ាងនោះ ;
- **អវិជ្ជា** ការល្ងីតល្ងង់ មិនដឹងមិនយល់ពុំស្គាល់កងទុក្ខហេតុដែលនាំឲ្យកើតទុក្ខក្តី ទាំងអស់នេះឥតមានសល់នៅក្នុងចិត្តព្រះអរហន្តទៀតទេ ។

ពួកជនណាមួយដែលព្យាយាមបដិបត្តិ កំចាត់កាត់បំបាត់បង់ឲ្យអស់ចំណងសំយោជនៈទាំងដប់ប្រការបានហើយ ដោយឥតមានសេសសល់ បុគ្គលនោះបានឈ្មោះថាជាព្រះអរហន្ត លោកបានដល់ព្រះនិព្វានខាងផ្លូវចិត្ត ជីវិតលោករស់នៅដោយសន្តិ ស្ងប់ក្សេមត្រជាក់មិនជំពាក់កករល្អក់សៅហ្មងដោយកិលេស ចិត្តលោកទាំងឡាយនោះជាឧបេក្ខា នៅក្នុងចន្លោះសុខនិងទុក្ខ បាបនិងបុណ្យ គុណនិងទោស ខុសនិងត្រូវ ទោមនស្សនិងសោមនស្សលុះអស់ព្រះជន្ម ឈ្មោះថាបាននិព្វានដោយខន្ធ មិនមានជាតិកំណើតទៀតទេ ។

• • •

សំណួរនេះ ខ្ញុំអធិប្បាយវែងឆ្ងាយអន្លាយបន្តិច ព្រោះខ្ញុំចង់បញ្ជាក់ឲ្យអ្នកបានស្តាប់យល់ចូលចិត្ត និងស្គាល់ដឹងពីប្រភេទបុថុ-ជ្ជននិងអរិយជន ឲ្យឃើញថាខុសផ្សេងពីគ្នា ។ បុគ្គលជាបុថុជ្ជន ទោះបីព្យាយាមបដិបត្តិយ៉ាងណា ក៏ឈ្មោះថានៅមិនទាន់បានឆ្លងកន្លងឲ្យផុតភព ឬនៅមិនទាន់សម្លឹងមើលឃើញទិសដៅ ដែលត្រូវទៅរកទីបំផុតភពកំណើតបាន ទោះបីជាបានសម្រេចកុសល មានកុសលឈានជាដើមក្តី ក៏ចាត់ថាជាលោកិយកុសលដែរ ជាផលផ្តល់ឲ្យបដិសន្ធិបានត្រឹមតែកាមលោក រូបលោក អរូបលោក មិនអាចមើលឃើញ ឬមានចិត្តផ្ចិតយកព្រះនិព្វានមកជាអារម្មណ៍បានឡើយ ។

ចំណែកព្រះអរិយបុគ្គល រាប់តាំងពីថ្នាក់សោតាឡើងទៅ ទោះបីការលះកិលេសរបស់លោកផ្សេងដោយឡែកពីគ្នាយ៉ាងណាក៏ដោយ កុសលដែលលោកត្រូវបានសម្រេចជាលោកុត្តរកុសល ជាផលផ្តល់ឲ្យឆ្លងកន្លងផុតចាកលោកិយ ជាវិវដ្តគាមិនីកុសល មិនវិលត្រឡប់មកកាន់អកុសលទៀតទេ ។ ព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើម លោកអាចកំណត់កត់សម្គាល់យល់ប្រាកដមានគោលដៅដឹងពីដំណើរជីវិតរបស់លោក គឺព្រះនិព្វានឥតមានងាករេ ឬសង្ស័យអ្វីសោះឡើយ ។ ព្រះសោតាក្តី, សកទាគាក្តី, អនាគាមិក្តី ទោះបីជាសេក្ខបុគ្គលនៅសិក្សាបដិបត្តិដើម្បីកំចាត់បង់កិលេស ដែលសេសសល់ឲ្យអស់ដោយដាច់ខាតយ៉ាងណា ក៏ដំណើរជីវិតរបស់លោក មិនវិលត្រឡប់មកកាន់ទីថយថោក ទុគតិ, វិនិបាត, នរក, ប្រេត, តិរច្ឆាន, អសុរកាយទៀតឡើយ ហើយពាក្យថាអរិយបុគ្គលតាំងពីសោតា, សកទា, អនាគា, អរហន្ត ចាត់

ថាជាសមណៈទីមួយ, សមណៈទីពីរ, សមណៈទីបី, សមណៈទីបួន កើតមានតែក្នុងព្រះពុទ្ធសាសនា សាសនាដ៏ទៃមិនអាចកើតមានជាដាច់ខាត ។

ការសួររបស់ខ្ញុំឃើញថាវែងឆ្ងាយពេកហើយ ការឆ្លើយមកទាំងប៉ុន្មាន ខ្ញុំបានស្តាប់យល់ចូលចិត្តល្មមសមគួរហើយដែរ ដូច្នេះខ្ញុំសូមឲ្យលោកជួយអធិប្បាយសេចក្តីនៃ " **ធម្មទោសទាំងបួនប្រការ** " បញ្ជាក់ថែមទៀត ដើម្បីឲ្យបានចូលចិត្តយល់កាន់តែច្បាស់ឡើង ។

តាមពិតសេចក្តីដែលមានក្នុង " **ធម្មទោសទាំងបួនប្រការ** " ដែលបានស្តាប់បានអានមក ក៏ហាក់បីដូចជាបានយល់ចូលចិត្តហើយដែរ ខ្ញុំគ្រាន់តែសរសេរបញ្ជាក់បន្ថែម និងលើកយកបទកំណាព្យខ្លះដើម្បីជាការងាយស្រួលក្នុងការអាន និងការស្តាប់ចាប់យកសេចក្តីបន្ថែមទៀត ។





# អធិប្បាយបញ្ជាក់

**១. ឧបនីយតិ លោកោ អទ្ធុវោតិ**
**សត្វលោកមិនទៀង ត្រូវជរានាំទៅកាន់មរណៈ ។**

ពាក្យថាសត្វលោក សំដៅយក នរក, ប្រេត, តិរច្ឆាន, អសុរកាយ, មនុស្ស, ទេវតា, ឥន្ទ្រ, ព្រហ្ម, យមយក្ស, នាគ, គ្រុឌ, គន្ធព្វ, កុម្ភណ្ឌ, អាសុរ ដែលរស់នៅក្នុងភពភូមិឋាន និងមានចិត្តជាប់ជំពាក់ ប្រកាន់ស្អិតដោយវត្ថុកាមនិងកិលេសកាម ។

ពាក្យថាមិនទៀង បានដល់ការប្រែប្រួល ផ្លាស់ប្តូរមិននៅនឹងនរមានដំណើររំកិលចូលទៅ ខិតកាន់តែកៀកកិតជិតទៅរក ។ វត្ថុមានជីវិតក្តី ឥតវិញ្ញាណក្តី ដែលកើតប្រាកដមានមកហើយឥតបានតាំងនៅជាប្រក្រតីទៅតាមសភាពដើមជាយ៉ាងណា ក៏តាំងនៅ

ជាយ៉ាងនោះសោះឡើយ គ្រប់ខណៈបានបញ្ជាក់ឲ្យឃើញច្បាស់អំពីភាពមិនទៀងគឺ **ឧប្បាទៈ** ការកើតឡើងប្រាកដ, **ឋិតិ** ការតាំងនៅ, **ភង្គៈ** ការបែកធ្លាយរលត់រលាយទៅ គ្រប់តែខណៈទាំងរូបធម៌និងនាមធម៌ រមែងមានសភាពស្មើគ្នា ។

សត្វលោក ទោះបីផ្សេងដោយឡែកពីគ្នា ដោយភេទ ជាតិកំណើត ភពភូមិឋាន ឋានៈតំណែងនាទីយសស័ក្តិ ឫទ្ធិអំណាចភោគសម្បត្តិ រូបរាងកាយ មានខន្ធប្រាំ ខន្ធបួន ខន្ធមួយ ជាសញ្ញីសត្វក្តី ជាអសញ្ញីសត្វក្តី គ្រប់សត្វទាំងនោះសុទ្ធតែមិនទៀងតាំងពីបដិសន្ធិកាលមកម្លេះ ដូចជា ជលាពុជៈកំណើត កំណើតមនុស្ស កើតក្នុងគភ៌មាតាក្តី កំណើតតិរច្ឆានកើតនៅក្នុងពោះមេវាក្តី អណ្ឌជៈកំណើត កំណើតសត្វកើតនៅក្នុងស៊ុតក្តី សំសេទជៈកំណើត កំណើតសត្វកើតចេញអំពីញើសក្អែលក្តី ពួកភូមិទេវតារុក្ខទេវតាជាន់ទាបពួកខ្លះ ជាអទិស្សមានកាយ ក៏មានកំណើតប្រហាក់ប្រហែលនឹងមនុស្ស គឺត្រូវកើតនៅក្នុងផ្ទៃមាតាដូចគ្នាដែរ កំណើតដូចពោលមកនេះ សុទ្ធតែត្រូវប្រែប្រួលផ្លាស់ប្តូរ រំកិលទៅតាមកាលវេលាជាដ៏រាប ។

ដូចជាកំណើតមនុស្សយើង ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងថា[១] ពួកសត្វកាលចូលមកកើត ឬថាចាប់តាំងពីមានកំណើតក្នុងផ្ទៃមាតាដំបូងឡើយជាកលលៈ ការកកាញ់បានជាទឹកសើម ល្អិតឆ្មារស្មើនឹងប្រេងល្ងជាប់នៅលើចុងសរសៃសក់ដែលគេ

---

(១) **បិដកលេខ ៦៤**, **ខុទ្ទកនិកាយ មហានិទ្ទេស ជរាសុត្តនិទ្ទេស ទី ៦ ទំព័រ ២២៥ ។**

រលាស់ចោលអស់រយៈប្រាំដងហើយ នៅសល់តែជាតិសើមយ៉ាងណា រូបសត្វលោកកកើតជាគ្រាដំបូងក៏យ៉ាងដូច្នេះឯង តាំងនៅជាសភាពបែបនេះអស់រយៈប្រាំពីរថ្ងៃ ទើបប្រែបានជាអម្ពុទៈ ក្លាយមកជាទឹករាវ ៗ បានប្រាំពីរថ្ងៃ ទើបប្រែមកជាបេសិ ក្លាយទៅជាកកដូចជាទឹកសំណខាប់ តាំងនៅបានជាសភាពបែបនោះប្រាំពីរថ្ងៃ ទើបប្រែទៅជាឃនៈ កកទៅជាដុំសាច់ រូបកកទៅជាដុំសាច់តាំងនៅបានប្រាំពីរថ្ងៃ ទើបផ្លាស់ប្តូរទៅជាបញ្ចសាខា ការដុះចេញបានជាក្បាលមួយ ដៃពីរជើងពីរ ក្នុងរយៈកាលសាមសិបប្រាំថ្ងៃនេះរូបតាំងនៅបាន ដោយកុសលវិបាកជាបច្ច័យ ជាសភាវធម៌ឧបត្ថម្ភទំនុកបម្រុងឲ្យរូបកើតកើនចម្រើនទៅបាន ប៉ុន្តែបានត្រឹមរយៈកាលប៉ុណ្ណឹង បើសត្វលោកបានកសាងសន្សំកុសលមកតិច ឬថាអស់ឥតមានកុសលវិបាកជាបច្ច័យទំនុកបម្រុងតទៅទៀត ក៏ជាហេតុបណ្តាលឲ្យសត្វនោះ អស់ជីវិតរបូតរលូតចេញចាកគភ៌ មិនអាចរង់ចាំដល់កាលប្រសូតចេញមកបាន ។ ក្នុងរយៈវេលាសាមសិបប្រាំថ្ងៃ គឺជាកុសលវិបាកតែម្យ៉ាង បើសត្វណាមានកុសលសន្សំសាងមកច្រើន មានកម្លាំងអាចកាត់បង់ មិនមានអកុសលវិបាកចូលមកបៀតបៀនបានទេ រូបក៏អាចមានចលនា កើតកើនចម្រើនបានជាបសាទរូប ដូចជាភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ជីវិតៈ ហទយៈ ភេទជាប្រុសឬភេទជាស្រី បានពេញលក្ខណៈមិនខ្វះខាត ។

ប៉ុន្តែក្នុងរយៈតមក កុសលវិបាកមានកម្លាំងខ្សោយ អកុសលវិបាកចូលជ្រៀតជ្រែកបានរមែងធ្វើឲ្យបសាទរូប មិនគ្រប់គ្រាន់ឥតពេញបរិបូណ៌ ដូចជាធ្វើឲ្យភ្នែកខ្វាក់ ត្រចៀកថ្លង់ ច្រមុះឆែប ទៅ

ជាគនិយាយមិនកើត វិកលចរិតចិត្តគំនិតមិនប្រក្រតី កំបុតជើងដៃយ៉ាងនេះជាដើម ។

សេចក្តីរៀបរាប់មកដោយសង្ខេបនេះ បញ្ជាក់ឲ្យឃើញពីភាពប្រែប្រួល ផ្លាស់ប្តូររបស់សត្វលោកមានមករហូតចាប់តាំងពីកកាញ់មានកំណើតនៅក្នុងគភ៌ជាដំបូងមកម្ល៉េះ ។ លុះដល់ពេលកើតចេញពីផ្ទៃមាតាមក រូបរាងកាយអាយុជីវិតនេះ ចេះតែប្រែប្រួលផ្លាស់ប្តូរពីសភាពមួយទៅកាន់សភាពមួយ ដូចជាអំពីទារកទារិកាឈានចូលដល់កុមារាកុមារី យុវជនយុវតី ទៅតាមវ័យជាបឋមវ័យ មជ្ឈិមវ័យ បច្ឆិមវ័យ រហូតដល់មានឈ្មោះថាជាលោកយាយលោកតា ទើបនាំគ្នាសម្គាល់ថាជា **ជរា** ព្រោះមើលឃើញច្បាស់ពីអត្តភាពរូបរាងកាយ ដែលក្លាយពីសក់ខ្មៅទៅសក់ស សម្បុរល្អរលើបរលោងក៏ប្រែទៅជាស្រអាប់បែកស្រកាស្វួតកក្រោះ ស្បែកធ្លាប់តែរឹងតឹងក្លាយទៅជាជ្រីវជ្រួញយុលយារទៅ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កម្លាំងកាយ ចេះតែថមថយខ្សោយចុះទៅជាលំដាប់ ។ ភាពចាស់ជរាដែលសម្តែងឲ្យឃើញប្រាកដច្បាស់យ៉ាងដូច្នេះ ក៏មកអំពីភាពមិនទៀងដែលបញ្ជាក់ឲ្យឃើញពីលក្ខណៈនៃការឈានរំកិលខិតជិតចូលដល់កាន់យកនោះឯង ។

កុំថាឡើយជាមនុស្សជាសត្វ ដែលមានកំណើតក្នុងផ្ទៃមាតាសូម្បីតែឧបបាតិកៈជាអបាយិកសត្វដូចជានរក ប្រេត ទេវតា ឥន្ទ្រព្រហ្ម ក៏ឋិតនៅក្នុងសភាពមិនទៀង ។ សត្វនរកត្រូវរងទុក្ខវេទនាស្លាប់កើត ៗ ស្លាប់យ៉ាងឆាប់រហ័សទៅតាមផលកម្មរបស់ខ្លួន ។ ពពួកទេវតាព្រមទាំងព្រហ្មមានរូបក្តី ព្រហ្មឥតរូបក្តី រស់នៅប្រកប

ដោយសេចក្តីសុខ បរិបូណ៌ដោយសម្បត្តិទិព្វ មានអាយុកាលតាំងពីប្រាំរយឆ្នាំទិព្វជារៀងដល់ទៅមួយម៉ឺនប្រាំមួយពាន់ឆ្នាំទិព្វក្តី ពួកព្រហ្មមានអាយុតាំងពីកន្លះឬមួយកប្ប ប្រាំរយកប្ប រហូតដល់ទៅប្រាំបីម៉ឺនបួនពាន់កប្បក្តី ទោះបីមានអាយុច្រើនយ៉ាងនេះក៏ដោយគង់ត្រូវនៅក្នុងសភាពមិនទៀងនាំទៅ ឈានរំកិលខិតចូលទៅជិតទៅតាមលំដាប់កាលវេលា គឺការអស់ទៅ សូន្យទៅនៃអាយុជីវិតទីបំផុតក៏ត្រូវច្យុតចាកភពភូមិឋានរបស់ខ្លួន ។ ដូច្នេះពាក្យថាមិនទៀង ជាហេតុកៀងបញ្ចូលប្រមូលឲ្យចូលទៅកាន់ជរា និងការអស់ទៅសូន្យទៅគឺសេចក្តីស្លាប់ ។ សេចក្តីស្លាប់ បានដល់ការសូន្យសោះអស់ទៅនៃអាយុជីវិត ការបែកធ្លាយរាងកាយ ។ តាមធម្មតាយើងតែងយល់ថា ការស្លាប់នេះលុះតែរាងកាយដេកស្តូកស្តឹងរឹងកំប្រឹងលែងដកដង្ហើមចេញចូល ទើបចាត់ជាការស្លាប់ ប៉ុន្តែសេចក្តីស្លាប់នេះលោកចែកជាបីយ៉ាងគឺ ៖

១. **ខណិកមរណៈ** សេចក្តីស្លាប់គ្រប់ខណៈចិត្ត ;
២. **សម្មតិមរណៈ** សេចក្តីស្លាប់ដោយសន្មតិ ;
៣. **សមុច្ឆេទមរណៈ** សេចក្តីស្លាប់ដោយការផ្តាច់ផ្តិល ។

១. សេចក្តីស្លាប់គ្រប់ខណៈចិត្ត បានដល់តំណនៃជីវិត គឺការរស់នៅនេះជាចលនាប្រព្រឹត្តទៅរបស់ចិត្តដែលមានតំណតភ្ជាប់គ្នាមិនដាច់ គឺកើតឡើងក៏រលត់ទៅវិញគ្រប់ខណៈ ។ ខណៈមុនកើតឡើងហើយរលត់ទៅ ជាបច្ច័យឲ្យខណៈខាងក្រោយកើតបន្តបន្ទាប់ជារៀងរហូតទៅ ប្រៀបដូចបណ្តាញនៃខ្សែទឹករលកដែលយើងចោលភ្នែកក្រឡេកមើលឃើញអំពីចម្ងាយឯនាយពាក់កណ្តាលទន្លេ

ឬសមុទ្រ យើងតែងនឹកគិតថា បណ្ដាញខ្សែទឹករលកបានបណ្ដោញគ្នាមករកច្រាំង គឺជាទឹករសាត់មកតាំងពីកណ្ដាលទន្លេឬសមុទ្រមក ប៉ុន្តែតាមការពិតពុំមែនដូច្នោះទេ ព្រោះទឹករលកជាចង្វាក់មុនកើតឡើង ប៉ោងខ្ពស់ឡើងហើយក៏ស្រកស្រុតរលត់បែកទៅវិញយ៉ាងឆាប់រហ័ស បណ្ដាលឲ្យខ្សែទឹកជាបន្ទាប់ប៉ោងឡើងជារលកចង្វាក់ក្រោយត ៗ មក រហូតធ្វើឲ្យយើងមើលឃើញថា ជាខ្សែទឹករលកជាប់គ្នាតាំងពីកណ្ដាលទន្លេឬសមុទ្រមកម្លេះ ប៉ុន្តែរលកដែលមកប៉ះផ្ទប់នឹងច្រាំង ក៏ជាទឹកដែលនៅជិតជាប់នឹងមាត់ច្រាំងនោះឯងដែលជារលកចង្វាក់ក្រោយបង្អស់ យ៉ាងណាមិញ ជីវិតសត្វលោកក៏ដូច្នោះដែរ ខណៈមុនកើតឡើងហើយក៏សូន្យសោះអស់ទៅ ខណៈក្រោយកើតបន្តជាប់ដូចខ្សែទឹករលក ដែលប៉ោងឡើងបែកទៅវិញបន្តបន្ទាប់គ្នានោះឯង ដូច្នេះទើបលោកចាត់ថា ការស្លាប់តាមខណៈ ( កាលវេលា ) ។ ម្យ៉ាងវិញទៀត រូបដែលកើតឡើងជាដំបូងដូចជាកលលៈរូប កើតឡើងតាំងនៅបានត្រឹមតែប្រាំពីរថ្ងៃ អម្ពុទៈរូបក៏កើតឡើង, កលលៈរូប ក៏រលាយសូន្យសោះបាត់ឈ្មោះអស់ទៅ ។ ការសម្លាប់ត ៗ គ្នា ដូចជាភាពកុមារាកុមារីមានប្រាកដហើយ ភាពជាទារកទារិកាក៏ត្រូវសូន្យសោះអស់ទៅ បានន័យថា ការកើតនិងការរលត់ជាបន្តបន្ទាប់ គឺទៅតាមលំដាប់នៃសភាវធម៌ព្រមទាំងកាលវេលានេះហើយចាត់ថាជា **ខណិកមរណៈ** ។

២. ការស្លាប់ដោយសន្មតិ បានដល់ការស្លាប់របស់បុថុជ្ជន ឬការស្លាប់របស់ពពួកសត្វទាំងឡាយដែលជាលោកិយវិស័យ ស្លាប់ដោយការអស់ខ្យល់ដង្ហើមចេញចូល ភ្លើងធាតុរលត់ជីវិតរលាយរាងកាយបែកធ្លាយ ឥតមានចលនាឥរិយាបថកម្រើកតទៅទៀតបានក្ដី

ការច្យុតឃ្លាតចាកភពភូមិឋានរបស់ពួកទេវតា ឥន្ទ្រ ព្រហ្មក្តី ការស្លាប់របស់ពួកនរក ប្រេត អសុរកាយក្តី ការស្លាប់ដូច្នេះហៅថា សម្មតិមរណៈ គឺការស្លាប់ដោយសន្មតិ ត្រូវត្រឡប់កើតទៀតក្នុងសំសារវដ្ត តាមយថាកម្ម អន្ទោលទៅអន្ទោលមករកទីបំផុតជាតិកំណើតមិនបានឡើយ ចាត់ថាជា **សម្មតិមរណៈ** ។

៣. ការស្លាប់ដោយឥតមានអ្វីសេសសល់នៅ បានដល់ការលះកិលេស ឬការកំចាត់បង់កិលេសរបស់ព្រះអរិយៈ តាំងពីថ្នាក់សោតាបន្នរហូតដល់ព្រះអរហន្ត កិលេសណាដែលលោកលះបង់កំចាត់ចោលហើយ កិលេសទាំងនោះរមែងសូន្យសោះអស់ពូជមិនអាចកើតឡើងមកទៀតបាន ជីវិតព្រះអរហន្តទាំងឡាយ កាលលោកសុគតហើយ ( បរិនិព្វាន ) ឥតមានជាតិកំណើត ក្នុងភពតូចភពធំទៀតទេ ទើបចាត់ថាជា **សមុច្ឆេទមរណៈ** ។

ពាក្យថាសត្វលោកមិនទៀង ត្រូវជរានាំទៅកាន់មរណៈនោះ បានដល់សេចក្តីស្លាប់ខាងដើមគឺ ប្រការទី ១ និងប្រការទី ២ នោះឯង ។

ជីវិតសត្វលោកកើតមកហើយ តែងតែប្រែប្រួលផ្លាស់ប្តូររំកិលទៅតាមកាលវេលា, កាលវេលាទំពារស៊ីអាយុជីវិតរបស់សត្វទាំង - ឡាយ បានន័យថា ថ្ងៃយប់ខែឆ្នាំចេះតែវិវដ្តទៅ, អាយុជីវិតចេះតែខើចអស់ទៅ គឺចេះតែថយចុះពីច្រើនមករកតិច ដែលរាប់ថាកើនឡើងចម្រើនឡើង បានដល់ការកើនចម្រើនខិតចូលជិតដល់ទីបញ្ចប់គឺចុងបំផុតនៃអាយុជីវិត អស់មានអ្វីឲ្យចម្រើនកើនកំណត់រាប់តទៅទៀតបាន ។ ការដែលថយចុះអស់ទៅនៃជីវិត ការកើនចម្រើន

ដល់ចុងបញ្ចប់ក្តី ទាំងនេះសុទ្ធតែជាសភាពមិនទៀង កៀងបញ្ចូលជីវិតទៅរកសេចក្តីស្លាប់ស្មើដូចគ្នាដែលសព្វសត្តាគ្មានសត្វណា អាចគេចវេះជៀសរត់បាន ។

# មរណជីវិត

## បទពាក្យប្រាំបី

នាយគង្វាលគោកៀងគោឲ្យទៅ ឆ្ពោះកាន់គោលដៅគឺទីគោចរ
វាលស្មៅមានទឹកសន្ទឹកខៀវល្អ ធ្វើឲ្យហ្វូងគោត្រេកអរសប្បាយ ។
រីឯជរានិងមច្ចុរាជ មានឫទ្ធិអំណាចលើសត្វទាំងឡាយ
កៀងនៅអាយុជីវិតរូបកាយ សត្វទីជិតឆ្ងាយក៏យ៉ាងនោះដែរ ។
ធ្វើឲ្យរូបកាយសត្វចាស់គ្រាំគ្រា ដាក់ទណ្ឌអាជ្ញារាល់យប់ថ្ងៃខែ
សត្វលោកមិនអាចប្រកែកបានទេ គ្រប់រូបតែងវេជ្រកាន់មរណៈ ។

# ភាពមិនទៀង

## បទពាក្យប្រាំបួន

អនិច្ចា បានន័យថា ការប្រួលប្រែ
ឥតទៀងទេ រេទៅតាម កាលវេលា
ថ្ងៃនិងយប់ ឥតឈប់ឈរ ផ្លាស់វេនគ្នា
បង្កើតជា បានឈ្មោះខែ ហែចូលឆ្នាំ ។
តាមចំណាំ ចាំសម្គាល់ យល់ធម៌ពិត
ជីវិតសត្វ តែងវិបត្តិ ខ្វាត់ប្រែទៅ
ឥតមានអ្វី ឲ្យទៀងទាត់ ប្រាកដនៅ

• • •

| | | | |
|---|---|---|---|
| រូបកាយត្រូវ | ឈានចូលទៅ | ដល់ជរា | ។ |
| ជរាតែង | កៀរប្រមូល | បញ្ចូលសត្វ | |
| ជួបវិបត្តិ | មិនអាចគេច | រត់ផុតបាន | |
| សព្វសត្តា | ត្រូវមរណា | វិនាសប្រាណ | |
| គ្រប់ភូមិឋាន | គេចមិនបាន | សោះឡើយណា ។ | |

## ២. អតាណោ លោកោ អនភិស្សរោ

## សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹងឡើយ ។

ពាក្យថាសត្វលោកឥតមានគ្រឿងការពារ បានសេចក្តីថា មិនអាចការពារតទល់ធន់ស៊ូធ្វើសឹកសង្គ្រាមទាមទារ តតាំងប្រឆាំងប្រកែក យកជ័យជំនះអំពីសេនា ឬអាជ្ញារបស់មច្ចុរាជបានទេ ។ ទោះបីជាព្រះរាជា ឬអ្នកគ្រប់គ្រងមានអំណាចឫទ្ធិចេស្តាបារមីប្រកបដោយពលសេនាទាហាន មានអាវុធយុទ្ធោបករណ៍ដ៏ទំនើបព្រមទាំងស្បៀងអាហារ រក្សាទុកផ្គត់ផ្គង់បម្រុងការពារតតាំងប្រឆាំងតប ឬក៏ការពារដោយគ្រឿងក្រោះ ជីករូងធ្វើរណ្តៅសាងកំពែងហ៊ុមព័ទ្ធកុំឲ្យមច្ចុរាជចូលទៅទន្ទ្រានរុករានបៀតបៀនមិនបាននោះ ពុំមានសោះឡើយ ។

សូម្បីជាចង់រត់គេចរកទីពួនជ្រក ញកភ្នំក្រំថ្ម សមុទ្របឹងបួរ អូរត្រពាំង ទន្លេអណ្តូងស្រះ លើគោកក្នុងទឹក ឮដ៏លំហមេឃចង់ជ្រែកទៅក្នុងបាតសមុទ្រទៅឲ្យផុតដល់ឋានបាតដាល ក្រោមដី ដើម្បីរកទីជ្រកកោនពួនអាស្រ័យ ឲ្យផុតអំពីគ្រោះថ្នាក់ភយន្តរាយឆ្ងាយពីមរណៈនោះមិនមានសោះទេ ។

ពាក្យថា មិនមានទីពឹង បានន័យថាមិនអាចរកយកវត្ថុអ្វីក្នុងលោកិយនេះ មកជាទីពឹងពាក់ពំនាក់អាស្រ័យ ជួយឲ្យផុតចាកទុក្ខភ័យ លែឲ្យឈ្នះសង្គ្រាមមច្ចុរាជដែលមានសេនាច្រើននេះបានឡើយ ។ ចុះសេនាមច្ចុរាជគឺអ្វីខ្លះទៅ ? សេនាមច្ចុរាជគឺ ៖ **ជាតិ, ជរា, ព្យាធិ, មរណៈ** សេនាទាំងបួននេះ ជាគ្រោះថ្នាក់ដែលតាមត្របាក់កៀកកិតជិតកាយ សព្វសត្វទាំងឡាយ គ្រប់ពេលវេលាឥតមានលើកលស់ដោះលែង បន្ធូរបន្ថយមួយវិនាទីក៏ទេដែរ ។ សេនាទីមួយគឺជាតិ បានដល់ការយោនយកកំណើត ការកើតតែងប្រលោមលួងលោម សត្វលោកគ្រប់រូបកាយឲ្យសប្បាយភ្លាំងភ្លេចស្មារតី មាតាបិតា មេបា កាលបើឃើញកូនកើតមក ក៏រមែងមានសេចក្ដីរំភើបត្រេកអរសាទរក្នុងដួងហឫទ័យ ខំពោលស្រដីប្រាប់គេឯងថា ខ្ញុំបានកូនប្រុសឬខ្ញុំបានកូនស្រី ។ ពោលដោយខ្លីសត្វលោក សប្បាយរីករាយនឹងជីវិត ជាតិកំណើត ទោះបីជាជីវិតខ្លួនក្ដី អ្នកដទៃក្ដី ។ តែតាមពិតសេនាទីមួយគឺជាតិនេះហើយដែលធ្វើឲ្យសត្វលោកវង្វេង ស្លុងគំនិតឥតបានគិតដល់អ្វីជាសេចក្ដីទុក្ខភ័យនឹងមានមកចំពោះមុខ ម្ល៉ោះហើយជាតិនេះឯងតែងកៀរប្រមូលបញ្ជូលទៅរកជរា, ជរានាំចូលដល់ព្យាធិ, ព្យាធិនាំចូលទៅកាន់មរណៈដែលម្នាក់ ៗ ត្រូវតែទទួលដោយមិនអាចចៃករំលែក ស្រែករកជំនួយមកជួយរំដោះសម្រាលគ្នាបាន ។

ព្រះរាជា មានពលសេះ ពលដំរី ពលទាហាន មានសេនាអាមាត្យ ស្រីស្នំកំដរឆ្វេងស្ដាំ មានឫទ្ធិអំណាចអាចពឹងពាក់ពំនាក់អាស្រ័យបានក្នុងពេលធ្វើសឹកសង្គ្រាម និងពឹងពំនាក់ជាជំនួយក្នុងកិច្ចការងារតាមបំណងប្រាថ្នារបស់ខ្លួនបានក៏ពិតមែនហើយ តែក៏មិន

អាចពឹងជំនួសបាន ឬជួយឲ្យផុតរួចអំពីចាស់ ឈឺ ស្លាប់នោះឥតអង្គីមានឡើយ ព្រោះរបស់ទាំងអស់នោះ សុទ្ធតែត្រូវចាញ់ឫទ្ធិអំណាចសេនាមច្ចុរាជស្មើដូចគ្នា ។

ជាការពិតណាស់ក្នុងលោកនេះ កិច្ចការខ្លះយើងអាចរំលែកចែកជួយគ្នាពឹងពាក់ពំនាក់អាស្រ័យ ដោយកម្លាំងកាយខ្លះ កម្លាំងទ្រព្យខ្លះបាន ប៉ុន្តែការចាស់ឈឺស្លាប់នេះម្នាក់ ៗ ត្រូវតែទទួល ។ មាតាបិតា ស្វាមីភរិយា បងប្អូនកូនចៅ ញាតិផៅសន្តាន មិត្រសាលោហិតជិតឆ្ងាយ ក៏មិនអាចចែករំលែកយក ឬក៏សម្រាលការឈឺចុកចាប់ សេចក្តីស្លាប់ ពីគ្នាសូម្បីបន្តិចបន្តួចក៏មិនបាន ភោគសម្បត្តិ លាភ យសស័ក្តិ អំណាច អាចយកទៅគម្រាមកំហែងដោះដូរ ទិញចែករំលែកពីមួយទៅមួយ ឬអាចយកទៅសូកប៉ាន់បង្ខិលស្មារតីឲ្យមនុស្សវង្វេងបាន តែក៏មិនអាចយកទៅសូកប៉ាន់អង្វរករសូមឲ្យរួចពីអាជ្ញាទណ្ឌមច្ចុរាជបានឡើយ ។ ការពឹងពាក់វេជ្ជបណ្ឌិត ឬថ្នាំដែលផលិតចេញអំពីវេជ្ជសាស្ត្រឬវេជ្ជកម្មផ្សេង ៗក្តីក៏បានត្រឹមមួយពេលមួយខណៈ មួយរយៈកាលប៉ុណ្ណោះឯង ព្រោះវេជ្ជបណ្ឌិតក៏លោកពុំអាចមានពំនឹងពឹងអាស្រ័យបាន សូម្បីតែខ្លួនលោកទាំងឡាយនោះក៏ត្រូវបែកធ្លាយរំលាយខន្ធ ទៅកាន់បរលោកនាយដែរ ។ ដូច្នេះទើបបញ្ជាក់ឲ្យយល់ចូលចិត្តពិតប្រាកដថាសត្វលោករស់នៅអនាថា ឥតមានគ្រឿងការពារ រស់ដោយកំព្រារងាឥតជម្រកជ្រកពឹងពួន ។

## គាថាធម្មបទ ទណ្ឌវគ្គោ

**( បិដកលេខ ៥២ ទំព័រ ៤៩ )**

• • •

**ន អន្តលិក្ខេ នសមុទ្ទ មជ្ឈេ**
**ន បព្វតានំ វិវរំ បវិស្ស**
**ន វិជ្ជតី សោ ជគតិប្ប ទេសោ**
**យ ត្ថដ្ឋិតំ នប្បសហេយ្យ មច្ចុ ។**

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្ដាលសមុទ្ទ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្ដីស្លាប់បាន ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ សេចក្ដីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។

## គេចមិនផុត រត់មិនរួច

បទពាក្យប្រាំពីរ

បុគ្គលអ្នកមានឫទ្ធិចេស្ដា សម្រាលកាយាបំបាំងប្រាណ
ហោះទៅឰដ៏អាកាសបាន ឬចង់ទៅទីឋានដទៃ ។
ទោះបីមុជចូលបាតសមុទ្រ ចង់ជ្រែកឲ្យផុតហួសផែនដី
រូងភ្នំឬក៏គុម្ពោតព្រៃ ក្រោមមេឃលើដីនោះយ៉ាងណា ។
ក៏មិនអាចគេចផុតរត់បាន រំដោះកាយប្រាណបានពីមារ
ក្រោមមេឃលើផ្ទៃនៃពសុធា សត្តាមិនអាចគេចស្លាប់បាន ៕

## ឥតជម្រកជ្រកអាពោរ

បទពាក្យប្រាំបួន

សត្វក្នុងលោក ឥតជម្រក ជ្រកអាស្រ័យ

...

គ្មានពំនឹង ពឹងលាក់ខ្លួន ពួនគេចភ័យ
តែងពើបពះ ជួបប្រទះ ក្នុងលោកិយ
គ្រោះថ្នាក់ភ័យ មិនអាចលៃ ការពារបាន ។
ភ័យប្រាកដ នាំតក់ស្លុត រន្ធត់ចិត្ត
ភ័យនោះពិត កើតចេញបាន ពីមច្ចុមារ
ទោះចង់រត់ គេចឲ្យផុត ដល់ទីណា
មនុស្សទេវតា ទាំងព្រហ្មា មិនបានឡើយ ៕

**៣. អស្សកោ លោកោ សព្វំ បហាយ គមនីយន្តិ សត្វលោកសុទ្ធតែគ្មានអ្វីជារបស់ខ្លួន សុទ្ធតែត្រូវលះរបស់ទាំងពួងដូច្នេះ ។**

ព្រះធម្មទ្ទេសទីបី ព្រះជិនស្រីឈ្នះមារ ព្រះអង្គទ្រង់សម្ដែងបង្ហាញឲ្យសព្វសត្វបានយល់ចូលចិត្តអំពីពាក្យថា ខ្លួននេះឲ្យបានពិតប្រាកដ កំណត់យល់ស្គាល់ដោយបញ្ញាវែកញែកចែកចេញឲ្យឃើញទៅជាប្រការដែលផ្ទុយអំពីគោលគំនិតទស្សនៈរបស់លោកិយនិយម ។

សត្វលោកគ្រប់រូប តែងមានចិត្តប្រកាន់ស្អិត ស្លុងគំនិតប្រកាន់សម្គាល់យល់ថាជាខ្លួន, ជាប្រាណ, ជាជីវិត, ជាសត្វជាបុគ្គល, ជាយើង, ជារបស់យើងដូច្នេះជាដើម ។ យ៉ាងដូច្នេះហើយ ទើបនាំគ្នាស្លុងគំនិតចូលចិត្តប្រកាន់ស្អិតផ្ទុយពីព្រះពុទ្ធដីកាដែលព្រះអង្គទ្រង់បានត្រាស់ថា សត្វលោកឥតមានអ្វីជារបស់ខ្លួន ។

ត្រង់ដែលសត្វទាំងឡាយ សម្គាល់ថាជាកាយជាប្រាណយើង គេសត្វបុគ្គលនោះគឺជា លោកបញ្ញតិ ជាការសន្មតកំណត់ឡើង ជាលោកវោហារក្នុងការពោលស្តីប្រាស្រ័យទាក់ទង ទៅតាមភាសាជាតិប្រទេសភូមិស្រុកប៉ុណ្ណោះឯង ដើម្បីឲ្យងាយស្រួលក្នុងការពោលស្តី ប្រាស្រ័យនិយាយទំនាក់ទំនងរវាងគ្នានិងគ្នា ។ ដែលព្រះអង្គទ្រង់ត្រាស់សម្តែងថា មិនមែនអ្វីជារបស់ខ្លួននោះ គឺចង់បញ្ជាក់ឲ្យឃើញថា អ្វី ៗ ទាំងអស់ដែលសត្វលោកធ្លាប់តែប្រកាន់ហួងហែងថាជារបស់ខ្លួននោះ វាពុំបានលុះទៅតាមអំណាច មិនអាចស្តាប់បង្គាប់ ឬហាមប្រាមហួងហែងថា កុំឲ្យជាយ៉ាងនេះឬក៏ជាយ៉ាងនោះ តាមបង្គាប់បញ្ជាចំណង់ចំណូលរបស់ចិត្តបានឡើយ។

ធម្មុទ្ទេសទីមួយ ទីពីរ ព្រះអង្គបានបញ្ជាក់ឲ្យឃើញស្គាល់ដឹងយល់ច្បាស់ប្រាកដហើយថា សត្វលោកមិនទៀង ត្រូវជរានាំចូលកាន់មរណៈ ។ ត្រង់ពាក្យថាមិនទៀងក្តី, ជរាក្តី, មរណៈក្តី តើសត្វលោកចង់បាន ចង់ជួបប្រទះ ទទួលយកដូច្នោះដែរឬទេ ? ប្រាកដជាអត់ចង់ហើយ ! ទោះបីជាចង់ក្តី មិនចង់ក្តី ក៏ត្រូវតែជួបប្រទះគេចមិនផុតរត់មិនបានហាមប្រាមមិនកើត មិនអាចឃាត់ឃាំងរាំងរាបញ្ជាប្រាប់តាមចំណង់ប្រាថ្នាបាន ។ ត្រង់ដែលអត្តភាពនេះមិនស្តាប់បង្គាប់ មិនឋិតនៅក្រោមអំណាចចំណូលចំណង់ចង់ប្រាថ្នារបស់សត្វលោកបាននេះឯង ទើបចាត់ថាជា **អនត្តា** មិនមែនជារបស់ខ្លួន ។ សូម្បីតែអត្តភាពនៃរូបកាយនេះ ហាមប្រាមរាំងរាការពារមិនឲ្យចាស់ឈឺស្លាប់ ក៏មិនបានទៅហើយ ចាំបាច់ពោលឡើយដល់ទ្រព្យសម្បត្តិ យសស័ក្តិ តំណែងនាទី អំណាច ភពភូមិឋាននោះ ។

• • •

សត្វលោកត្រូវតែលះរបស់ទាំងពួងហើយទៅដូច្នេះ មាតាបិតា បុត្រភរិយាស្វាមីបងប្អូនញាតិមិត្រសាច់សាលោហិតជិតឆ្ងាយ ជាទីស្រឡាញ់ពេញចិត្តស្និទ្ធស្នាល ធ្លាប់ឈឺឆ្អាលពឹងពាក់រកគ្នាដោយកិច្ចធុរៈផ្សេង ៗ ក្តី ភោគសម្បត្តិ ចំណេះវិជ្ជា តំណែងនាទី យស អំណាច ដែលម្នាក់ ៗ ខំព្យាយាមរករៀនបំពេញធ្វើឲ្យចេះឲ្យកើតមានបានដើម្បីបម្រើដល់អត្តភាព ឲ្យសុខសប្បាយងាយស្រួលខ្ពង់ខ្ពស់ត្រកុំត្រកាល ទាំងខំហួងហែងការពាររាំងរាមិនចង់ឲ្យវត្ថុទាំង-ឡាយនោះ បែកបាក់ធ្លាក់ទៅជាកម្មសិទ្ធិអ្នកដទៃ ឬវិនាសទៅដោយប្រការណា ៗ ទាល់តែសោះ ។ ទោះបីជាយ៉ាងណាក៏ដោយ តើសត្វលោកណាអាចយកអ្វីទៅបាន, សូម្បីតែកាយប្រាណក៏ត្រូវលះចោលនៅលើផែនដីនៃមច្ចុរាជនេះទៅហើយ ? ។

សត្វ ត្រី បក្សាបក្សី ម្រឹគីម្រឹគា ខំម្ទីម្ទាស្ទុះស្ទាហើរចេញពីសំបុកដើរតត្រុកចេញពីលំនៅឋាន, មច្ឆាជាតិហែលព្រោងព្រាតខ្មីឃ្មាតរកចំណីមិនថាជាពេលយប់ ឬជាពេលថ្ងៃដើម្បីចិញ្ចឹមរាងកាយបំប៉នសាច់ឈាមឲ្យបានធំធាត់ តែត្រូវដល់ថ្ងៃកំសត់ត្រូវពួកព្រានចាប់យកមកជាចំណីឆីចំអែតក្រពះ ។ មនុស្សលោកក៏គ្មានអ្វីឲ្យប្លែកដែរ ឥតមានទំនេរខំតត្រុកសម្រុកប្រកបការងារម្ទីម្ទារូតរះអន្ទះអន្ទែងស្វះស្វែងរៀងរាល់ថ្ងៃតាំងពីព្រលឹមទល់ព្រលប់ ឥតហ៊ានឈរឈប់នៅទំនេរ ដើម្បីទំនុកបម្រុងខ្លួនឯងឲ្យមាននាទីតំណែងអំណាចយសស័ក្តិ កេរ្តិ៍ឈ្មោះធនធានឲ្យបានខ្ពង់ខ្ពស់ឆើតឆាយ ទាំងខំតាក់តែងស្អិតស្អាងរាងកាយឲ្យមានសម្ផស្សល្អគួរជាទីពិតពិលរមិលមើលអំពីសំណាក់អ្នកដទៃ ។ ទោះជាយ៉ាងនេះក្តី នៅទីបំផុតជីវិតត្រូវរលត់ កាយនេះក៏ត្រូវដេកស្តូកស្តឹង រឹងកំប្រឹងលែងពោល

• • •

ស្ដី បានទៅជាចំណីនៃអគ្គី ឬត្រូវធរណីគ្របមុខទុកឲ្យជាចំណីនៃសត្វដង្កូវនិងសត្វជន្លេនដូចតែគ្នា បើដូច្នោះចាំបាច់ពោលអ្វីដល់ទៅរបស់ទ្រព្យដទៃក្រៅពីខ្លួននោះ ។

សត្វលោកសុទ្ធតែគ្មានអ្វីជារបស់ខ្លួន បានន័យថាសត្វលោកគ្មានឥស្សរៈភាព មិនមានអំណាចអាចហួងហែងការពារហាមប្រាមឲ្យបានតាមទំនើងចិត្តដែលប្រកាន់ស្អិតជាប់ជំពាក់បានទេ មិនអាចប្រកាន់ថាជារបស់អញ នុ៎ះជាអញ ជាខ្លួនអញ ព្រោះរបស់អស់ទាំងនោះ ចេះតែសូន្យសោះអស់ទៅតាមវេលា អ្វី ៗ ទាំងអស់កើតឡើងដោយហេតុបច្ច័យ រមែងរលត់ទៅវិញដោយហេតុបច្ច័យដូច្នោះដែរ ។

ព្រះថេរដីការបស់ព្រះអស្សជិតត្ថេរ លោកបានសម្ដែងដល់ព្រះឧបតិស្សៈព្រះសារីបុត្ត យ៉ាងនេះថា ៖

**យេ ធម្មា ហេតុប្បភវា**
**តេសំ ហេតុំ តថាគតោ**
**តេសញ្ច យោ និរោធោច**
**ឯវំ វាទី មហាសមណោ ។**

ធម៌ទាំងឡាយឯណា មានហេតុជាដែនកើតឡើង
ព្រះតថាគតពោល នូវហេតុនៃធម៌ទាំងឡាយនោះផង
នឹងពោលនូវសេចក្ដីរំលត់ ព្រមទាំងឧបាយជាគ្រឿងរំលត់
នូវធម៌ទាំងឡាយនោះផង ព្រះមហាសមណៈជាគ្រូអាត្មា
ព្រះអង្គមានវាទៈ( ពាក្យពោល) យ៉ាងនេះជាប្រក្រតី ។

• • •

អ្វីណាដែលកើតឡើងដោយហេតុបច្ច័យណា ក៏រមែងរលត់ទៅវិញដោយហេតុបច្ច័យនោះវិញដែរ ដូចជារាងកាយនេះ គ្រាន់តែជារបស់ផ្សំផ្គុំឡើង កើតឡើងពីចំណែកនីមួយ ៗ ជារបស់ពុកផុយឥតរឹងមាំ តែងដល់នូវភាពគ្រាំគ្រាបែកធ្លាយជាធម្មតា ដូច្នេះហើយទើបព្រះអង្គទ្រង់ត្រាស់ថា មិនមានអ្វីជារបស់ខ្លួន ត្រូវតែលះអត្តភាពជាមនុស្ស សត្វ ទេវតា ឥន្ទ្រ ព្រហ្ម ភពភូមិឋានរបស់ទ្រព្យ ជាតិកំណើតដែលធ្លាប់តែជាប់ជំពាក់ ប្រកាន់ថាជាអញ ជារបស់អញ ហើយទៅតាមយថាកម្មដោយមិនអាចប្រកែកបាន ។ ថាមនុស្ស សត្វក្នុងលោកយើងនេះចុះ ដែលត្រូវបែកធ្លាយរាងកាយ ស្លាប់ដោយជរាពាធឬដោយរោគាពាធបៀតបៀន ចុះទេវតាត្រូវស្លាប់ដោយប្រការយ៉ាងណាដែរ ? ពិតមែនហើយមនុស្សលោកយើង តែងមានចិត្តគិតថា កើតជាទេវតារមែងបានសោយសេចក្ដីសុខបរិបូណ៌ដោយសម្បត្តិទិព្វទាំងដប់ប្រការ មិនគួរណាដល់សេចក្ដីស្លាប់សោះ តែកុំភ្លេចថាទេវតា ឥន្ទ្រ ព្រហ្ម ក៏ជាសត្វលោកដែរ ដូច្នេះសត្វលោក មិនអាចគេចវេះជៀសផុតរត់រួចបានពីសេចក្ដីស្លាប់ទេ គ្រាន់តែពួកទេវតាទាំងនោះគេមានអាយុទិព្វ អាយុវែងតាំងតែពីប្រាំរយឆ្នាំទិព្វ ទៅដល់មួយម៉ឺនប្រាំមួយពាន់ឆ្នាំទិព្វដោយអំណាចនៃកាមាវចរកុសល ។ ពួកព្រហ្មមានអាយុច្រើនចាត់ថាជាកប្ប[១] តាំងពីកន្លះកប្ប ប្រាំរយកប្បរហូតទៅដល់ប្រាំបីម៉ឺនបួនពាន់កប្ប ដោយអំណាចរូបាវចរកុសលខ្លះ អរូបាវចកុសលខ្លះ ។ ពួកទេវតាទាំងនោះឋិតនៅបានតាមអាយុកាលនិងបុញ្ញកាលរៀង ៗ ខ្លួន

(១)កប្ប កាប់ បា.; សំ. ( ន. ) (កល្ប ) កាលដែលតាំងនៅយូរអង្វែង : មួយកប្ប, ភ្លើងប្រល័យកប្ប ។

លុះដល់អស់អាយុអស់បុណ្យហើយ ក៏រមែងច្យុតចាកភពភូមិឋានរបស់ខ្លួន ។

ទេវតាច្យុតដោយមានបុព្វនិមិត្តប្រាំយ៉ាង[១] ៖

១. កម្រងផ្កាទាំងឡាយស្វិតស្រពោន ;
២. សំពត់ទាំងឡាយសៅហ្មង ;
៣. ញើសចេញពីក្លៀក ;
៤. សម្បុរមិនល្អតាំងកើតឡើងក្នុងកាយ ;
៥. មិនត្រេកអរក្នុងទេវាសនៈ ។

កាលបើមាននិមិត្តនេះណាមួយកើតឡើងប្រាកដហើយ ទេវតាតែងភ័យស្លន់ស្លោរ ព្រោះរាងកាយត្រូវលោយចាកភពជាតិកំណើតរបស់ខ្លួនទៅកើតក្នុងទីផ្សេងទៀត ។ ដូច្នេះកុំថាឡើយតែមនុស្ស ទោះបីជាទេវតាឥន្ទ្រព្រហ្ម ក៏ត្រូវតែលះចោលអត្តភាពជាតិកំណើតភពភូមិឋាន ដែលធ្លាប់បានធ្លាប់មាន ធ្លាប់ប្រកាន់ជាប់ជំពាក់ត្រូវតែលះដាក់ចោលទៅដូច្នោះឯង ។

## សុមេធបណ្ឌិត

ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមទីបង្ករត្រាស់ដឹងឡើងក្នុងលោក កាលនោះព្រះបរមសាស្តាសម្មាសម្ពុទ្ធជាព្រះបរមគ្រូនៃយើង ព្រះអង្គបានយោនយកកំណើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ទ្រង់

(១) **បិដកលេខ ៥៣ គម្ពីរខុទ្ទកនិកាយ ឥតិវុត្តកៈ ទំព័រ ១១២**
( មានបុព្វនិមិត្តប្រាំយ៉ាង ដែលធ្វើឲ្យទេវតាច្យុតចាកភព )

ព្រះនាមថា សុមេធបណ្ឌិត មាតាបិតាបានធ្វើមរណកាលអស់ទៅ ព្រះបរមពោធិសត្វបានរស់នៅជាមួយទាសីទាសាជាបរិវារ រហូតដល់ធំពេញវ័យ ។ ថ្ងៃមួយនាយឃ្លាំងបានប្រមូលបញ្ជីទ្រព្យ មកសូត្ររៀបរាប់ជូនសុមេធបណ្ឌិតស្តាប់ថា ទ្រព្យប៉ុណ្ណេះជាកេរខាងឪពុក, ទ្រព្យចំនួនប៉ុណ្ណេះជាកេរខាងម្តាយ, ទ្រព្យប៉ុណ្ណេះជាកេរខាងញាតិ, ទ្រព្យប៉ុណ្ណេះជាកេរខាងជីដូន, ជីតាជាដើម . . . រួចហើយប្រគល់បញ្ជីទ្រព្យឲ្យដល់សុមេធបណ្ឌិត ។

ព្រះបរមពោធិសត្វក្រោយពីបានស្តាប់ចប់ ក៏កើតសេចក្តីសង្វេគក្នុងចិត្តឥតឧបមាដោយគិតថា ៖ " ឱហ្ន៎ ! មាតាបិតា ជីដូនជីតា ញាតិការទាំងអស់របស់អាត្មាអញ ត្រូវលះលោកនេះទៅបន្សល់ទុកនៅទ្រព្យសម្បត្តិព្រមទាំងបញ្ជីឈ្មោះ ទុកឲ្យអ្នកនៅជំនាន់ក្រោយ គាត់ទាំងអស់នោះទៅបាត់ស្ងាត់ស្ងៀម ដោយពុំបានយកវត្ថុអ្វីទៅបានសូម្បីតែបន្តិចបន្តួចឡើយ ចំណែកអាត្មាអញក៏មិនខុសគ្នាឡើយ ត្រូវតែលះលោកនេះហើយទៅ តើនឹងមានប្រយោជន៍អ្វីចំពោះទ្រព្យទាំងនេះ " ។

យល់ប្រាកដដូច្នេះហើយ ទើបប្រគល់ទ្រព្យឲ្យដល់នាយឃ្លាំងព្រមទាំងបរិវារ ហើយរំដោះអាត្មាចេញចាកផ្ទះ ទៅសាងផ្នួសជាតាបសនៅក្នុងព្រៃ ចម្រើនឈានសមាបត្តិរហូតបានសម្រេចជាលោកិយឈាន ។

ការលើកយកប្រវត្តិ សុមេធបណ្ឌិត មកសម្តែងដោយសង្ខេបខ្លី ក៏ចង់បញ្ជាក់ឲ្យយល់ពីព្រះពុទ្ធដីការបស់ព្រះអង្គ ទ្រង់បាន

ត្រាស់ថា សត្វលោកឥតមានអ្វីជារបស់ខ្លួន សុទ្ធតែត្រូវលះរបស់ទាំងពួង ហើយទៅដូច្នោះ ។

# មិនអាចយកអ្វីបាន

## បទព្រហ្មគីតិ

រីឯសម្បត្តិទ្រព្យ ប្រសើរគាប់ផងទាំងឡាយ
អាចជាប់ជិតកិតកាយ បានសប្បាយពេលនៅរស់ ។
ព្រមទាំងស័ក្តិអំណាច អាចរាប់បានទាំងលាភយស
បងប្អូនកូនចៅនោះ កាលនៅរស់បានឃើញគ្នា ។
ទាំងភរិយាស្វាមី ញាតិប្រុសស្រីមាតាបិតា
ទោះជីដូនជីតា ជនជាមិត្រជិតឬឆ្ងាយ ។
នៅពេលជីវិតរស់ ទ្រព្យញាតិនោះនាំរីករាយ
ជាប់ចិត្តស្អិតមិនណាយ មិនចង់ឃ្លាតឆ្ងាយឡើយណា ។
តែគួរឲ្យសង្វេគ អាសូរពេកសព្វសត្តា
កើតមកក្នុងលោកា គ្មានសត្វណាអាចតាំងនៅ ។
ឥតមានអ្វីពឹងពួន សូម្បីខ្លួនឯងក៏ត្រូវ
លះចោលឃ្លាតចេញទៅ សពចោលនៅលើផែនដី ។
ទាំងបងប្អូនកូនចៅ រួមញាតិផៅទ្រព្យអ្វី ៗ
មិនចាំបាច់ពោលស្តី ដៃត្រូវលាតទៅទទេ ៕

# គ្មានអំណាច អាចបញ្ជាបាន

## បទពាក្យប្រាំបួន

អត្តភាព គឺរាងកាយ បែកធ្លាយទៅ
ឥតតាំងនៅ ត្រូវរលត់ ផុតលោកា
ទោះមានចិត្ត គិតបំណង ប៉ងប្រាថ្នា
ខំការពារ ជាយ៉ាងណា ក៏មិនបាន ។
ឥតបើស្តាប់ តាមបង្គាប់ ទម្លាប់ចិត្ត
ចេះតែខិត រំកិលពិត តាមវេលា
កាយត្រូវចាស់ ផ្លាស់ទ្រុឌទ្រោម កាន់មរណា
សព្វសត្តា គ្មានសត្វណា រត់ផុតបាន ។
អនត្តា មិនឋិតនៅ ក្រោមអំណាច
ឥតអាចហាម ប្រាមការពារ ធានាសោះ
ថាកុំឲ្យ ជាយ៉ាងនេះ ឬយ៉ាងនោះ
គ្រប់ទាំងអស់ ឥតស្តាប់សោះ តាមចិត្តឡើយ ៕

**៤. ឩនោ លោកោ អតិត្តោ តណ្ហា ទាសោតិ សត្វលោកមានតែសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ។**

ពាក្យថា តណ្ហា បានដល់ចិត្តដែលប្រាថ្នា ចង់បានចង់មាន អង្គធម៌គឺ លោភៈ គឺការជាប់ជំពាក់ហួងហែង សេចក្តីប្រាថ្នាចង់បានចង់មានចំពោះវត្ថុដែលមិនទាន់បាន មិនទាន់មាន វត្ថុដែលបានមានមកហើយ ក៏ប្រកាន់ជាប់ជំពាក់ចំពោះរបស់ទាំងអស់នោះ

• • •

មិនចង់ឲ្យរបេះរបូតឃ្លាតចេញពីខ្លួន ។

សត្វលោកកើតមកមានតែសេចក្តីខ្វះខាត មិនដែលឆ្អែតឆ្អន់គ្រប់គ្រាន់ល្មមសោះឡើយ ការចង់បានចង់មាននៅមានដរាបណាសេចក្តីខ្វះខាតនៅមានដរាបនោះ ។ សត្វលោកដែលមានសេចក្តីខ្វះខាត ក៏មកអំពីមានតណ្ហាសេចក្តីប្រាថ្នា ការចង់បានចង់មាននេះឯង ។ ដូច្នេះសត្វលោក អាចមានសេចក្តីគ្រប់គ្រាន់ធួនល្មមទៅបាន ក៏លុះត្រាណាមិនមានតណ្ហាជាខាងដើម ។

តណ្ហានាំចិត្តសត្វលោកឲ្យស្ទុះទៅ ឲ្យចង្អៀតចង្អល់ខ្វល់ខ្វាយអន្ទះអន្ទែង ពពួកសត្វដែលអន្ទោល កើត, ចាស់, ឈឺ, ស្លាប់នៅក្នុងភពមានកាមភព រូបភព អរូបភព ក៏ព្រោះតែមានតណ្ហាជាហេតុជាបច្ច័យ ក្រសែទឹកគឺតណ្ហាមានអានុភាព ហូរជ្រួតជ្រាបតាំងពីកាមលោក គឺលោកមនុស្សទេវតារហូតដល់ព្រហ្មលោក គឺលោកជាទីអាស្រ័យនៅនៃពពួកព្រហ្ម ។

# នទីស្មើដោយតណ្ហាមិនមាន

## បទពាក្យប្រាំពីរ

ទោះបីសមុទ្រស្ទឹងទន្លេ ពុំអាចប្រៀបទេនឹងតណ្ហា
ជាមហានទីក្នុងលោកា គ្មាននទីណាប្រដូចបាន ។
ដូចក្រសែទឹកហូរជ្រួតជ្រាប ជារៀងដរាបគ្រប់ទីស្ថាន
ថែមទាំងចាក់ស្រែះចិត្តសន្តាន មិនឲ្យសត្វបានងាកប្រាណរួច៕

ព្រះដ៏មានព្រះភាគ កាលព្រះអង្គទ្រង់បានត្រាស់នូវសម្មា - សម្ពោធិញ្ញាណជាគ្រាដំបូងនៅក្រោមម្លប់ដើមពោធិព្រឹក្ស ព្រះអង្គទ្រង់មានព្រះពុទ្ធដីកាបន្ទុះបង្អាប់តណ្ហានេះថាជាមេជាងសាងអត្តភាពរបស់ព្រះអង្គ ធ្វើឲ្យព្រះអង្គអន្ទោលទៅនៅក្នុងសង្សារវដ្តជាអនេកជាតិ ជាតិនេះហើយតែងនាំមកនូវសេចក្តីទុក្ខដែលមិនអាចប្រមាណបាន ។ ទន្ទឹមនឹងការបានត្រាស់ដឹង ព្រះអង្គបានយល់ស្គាល់ដឹងឃើញប្រចក្សដោយបញ្ញាថា តណ្ហាជាមេជាងសាងអត្តភាពរបស់ព្រះអង្គ មានអវិជ្ជាជាជំនួយជាប្រធាន ។ ព្រះអង្គបានយកជ័យជំនះដោយការកាច់បំបាក់បង់គឺ កិលេសទាំងឡាយធ្វើឲ្យរីងស្ងួតតណ្ហារុះរើមេដំបូលគឺអវិជ្ជា ដោយអរហត្តមគ្គញាណ មានឧបាទិ-សេសនិព្វាន ជាធម្មជាតិផ្តាច់ផ្តិលអស់នូវសង្ខារទាំងឡាយ មានបុញ្ញាភិសង្ខារ, អបុញ្ញាភិសង្ខារ, អនេញ្ជាភិសង្ខារ ឥតមានសេសសល់នៅសូម្បីតែបន្តិចបន្តួចឡើយ ។

តណ្ហាជាមេជាងសាងអត្តភាពសត្វលោកផង និងប្រលោមលួងសត្វលោកឲ្យវង្វេង សប្បាយរីករាយភ្លើតភ្លើនចំពោះអារម្មណ៍ដែលសមប្រាថ្នាផង ជាមេបង្កើតទុក្ខទោសទាំងពួងផង ជាអន្ទាក់ចងឆ្នាក់សត្វលោកមិនឲ្យចេញចាកភពបានផង ជាចៅហ្វាយនាយលើសត្វទាំងឡាយ ដោយបានដាក់ភារៈទម្លាក់ទម្ងន់មកលើសត្វលោក ឥតបានលើកលស់រំដោះសម្រាលសោះឡើយ ទាំងជាម្ចាស់បំណុលផ្តាច់ការមកលើសត្តាគ្មានត្រាប្រណី ព្រោះគ្មានសត្វណាអាចសងបំណុលតណ្ហារួចទេ ។

ការកង្វល់ខ្វល់ខ្វាយរបស់មនុស្សទាំងឡាយ សត្វទាំងឡាយ

ក្នុងការចិញ្ចឹមអត្តភាព គឺរូបរាងកាយជីវិតនេះតាំងតែពីកើតមករហូតដល់ស្លាប់ទៅវិញ ពុំដែលឃើញនរណាម្នាក់ ដែលពោលថាខ្ញុំគ្រប់ហើយដូច្នេះសោះឡើយ ព្រោះតែសេចក្តីប្រាថ្នាឥតមានព្រំដែនទើបធ្វើឲ្យសត្វលោកមានកង្វះខាតមិនចេះឆ្អែតឆ្អន់គ្រប់គ្រាន់ល្មម ភ្នែកមិនឆ្អែតក្នុងការមើលរូប, ត្រចៀកមិនឆ្អែតក្នុងការស្តាប់, ច្រមុះមិនឆ្អែតក្នុងការហិតក្លិន, អណ្តាតមិនឆ្អែតក្នុងការភ្លក្សរស, កាយមិនឆ្អែតក្នុងការពាល់ត្រូវសម្ផស្ស, ចិត្តមិនឆ្អែតក្នុងការនឹកសញ្ជឹងរកអារម្មណ៍ បើគិតមើលទៅក្នុងខ្លួនមនុស្សយើង សុទ្ធតែមិនឆ្អែតទាំងអស់ ។

ជីវិតសត្វលោកក្នុងមួយជាតិ ៗ ជាទាសកររបស់តណ្ហាអន្ទះអន្ទែងខ្វល់ខ្វាយក្តៅក្រហាយតាំងតែកំពុងរស់នៅ រហូតដល់បិទភ្នែកដេកលើធរណីហើយក៏ដោយ នៅតែជំពាក់បំណុលតណ្ហា គ្មានសត្វណាសងរួចសោះអស់ទេ ត្រូវចៅហ្វាយនាយតាមទារបំណុលដល់ទៅភពថ្មីទៀត មិនព្រមលើកលែងឲ្យឡើយ ។

ពួកសត្វក្នុងនរក ត្រូវរងទុក្ខវេទនាក្តៅក្រហល់ក្រហាយព្រោះចំហាយភ្លើងកម្មជាអកុសល ផ្តល់ឲ្យស្លាប់កើត ៗ ស្លាប់ឆាប់រហ័សទទួលផលកម្មនោះរកសុខមិនបាន ។ ពួកប្រេតអសុរកាយរងទុក្ខវេទនាព្រោះការអត់ឃ្លាន សត្វតិរច្ឆានទាំងឡាយខ្វល់ខ្វាយក្នុងការស្វែងរកចំណីចម្អែតក្រពះ, មនុស្សក្រីក្រលំបាកយ៉ាកយ៉ាប់ទុក្ខព្រួយព្រោះអត់ទីជម្រកជ្រកអាស្រ័យ, អាហារបរិភោគ, សម្ភារៈប្រើប្រាស់, ព្រះរាជា, គហបតី, សេដ្ឋី, អ្នកមាន មិនចេះឆ្អែតដោយសម្បត្តិអាណាខេត្រ ភោគៈធនធាន ។

ព្រោះតែចំណង់ និងការស្រេកឃ្លាន ខ្វះខាតត្រូវការនេះ ហើយ សត្វលោក មិនថាយប់មិនថាថ្ងៃ អន្ទះអន្ទែងស្វះស្វែងធ្វើអំពើអាក្រក់ខ្លះ ល្អខ្លះ តាមផ្លូវកាយ វាចា ចិត្ត ចំពោះមុខខ្លះ កំបាំងមុខខ្លះ រហូតដល់ការប្រយុទ្ធច្បាំង តតាំងប្រណាំងប្រជែង កាប់សម្លាប់ ឆក់ប្លន់កេងប្រវ័ញ្ចបោកបញ្ឆោតប្រើកលឧបាយផ្សេង ៗ យកឈ្នះយកចាញ់តាមចំណូលចំណង់តែរៀង ៗ ខ្លួន ។ ទាំងនេះមិនមកពីសេចក្ដីខ្វះខាត មិនចេះឆ្អែតឆ្អន់គ្រប់គ្រាន់នោះទេឬ ? ឬក៏គ្រាន់តែបំពេញតម្រូវការឲ្យតណ្ហានោះឯង . . .

## បុរាណភាសិត

**ស្ដេចមិនឆ្អែតសម្បត្តិអាណាខែត្រ សមុទ្រមិនឆ្អែតស្ទឹងនានា**
**បណ្ឌិតមិនឆ្អែតសុភាសិតពុទ្ធដីកា នេត្រាមិនឆ្អែតគន់រូបកាយ ។**

សេចក្ដីក្នុងសុភាសិតនេះ លោកចង់ពោលបញ្ជាក់ប្រាប់អំពីភាពមិនចេះឆ្អែត ... ។



# ព្រះបាទមន្ធាតុ

**ក្នុង**ខាងដើមនៃភទកប្បនេះ មានព្រះបរមចក្រពត្រាធិរាជមួយព្រះអង្គព្រះនាម ( មន្ធាតុ ) មានមហិទ្ធិឫទ្ធិធំអស្ចារ្យ សោយរាជ្យក្នុងទ្វីបទាំងបួន មានមហាក្សត្រិយ៍ប្រាំបីម៉ឺនបួនពាន់ព្រះអង្គជាបរិវារ ។ មនុស្សក្នុងជំនាន់នោះ មានអាយុកំណត់មួយអសង្ខេយ្យឆ្នាំ ។ ព្រះបាទមន្ធាតុមានឫទ្ធិអស្ចារ្យណាស់ អាចទះដៃធ្វើឲ្យកែវមណីទាំងប្រាំពីរប្រការ ធ្លាក់ចុះមកពីលើអាកាសបានតាមសេចក្ដីប្រាថ្នា អាចហោះហើរដើរលើអាកាសបានដោយអំណាចនៃចក្ករតន៍គ្រងរាជ្យប្រកបដោយសេចក្ដីសុខចម្រើន សម្បូណ៌ហូរហៀតតបើមានខ្វះកន្លះអ្វីបន្តិចបន្តួចឡើយ ។ តែដោយអំណាចនៃសេចក្ដី

ប្រាថ្នា របស់សព្វសត្វមិនចេះស្កប់ស្កល់ ធ្វើឲ្យព្រះបាទមន្ធាតុកើតសេចក្ដីធុញទ្រាន់អផ្សុកនឿយណាយមិនសប្បាយ ជាមួយនឹងសម្បត្តិមនុស្សលោក បានជ្រាបថាសម្បត្តិឋានចាតុម្មហារាជិកាស្អាតវិចិត្រប្រណីតជាជាងសម្បត្តិមនុស្ស ដូច្នេះទើបគ្រវីចក្ករ័តន៍ហោះទៅកាន់ឋានចាតុម្មហារាជិកា ទេវតាទាំងបួនមានសេចក្ដីជ្រះថ្លា បានយាងឲ្យសម្រាកសម្រាន្តនៅក្នុងឋានរបស់ខ្លួន ដោយបានរំលែកសម្បត្តិថ្វាយឲ្យគ្រប់គ្រងក្នុងទីនោះ ។ ព្រះរាជាបានគ្រងរាជ្យសម្រាកសម្រាន្តនៅក្នុងទីនោះបានប្រាំបីម៉ឺនបួនពាន់ឆ្នាំ ក៏មានព្រះទ័យអផ្សុកមិនស្កប់ស្កល់ យល់ដំណឹងថានៅក្នុងឋានតាវតឹង្សមានសម្បត្តិទិព្វប្រណីត ជាងសម្បត្តិក្នុងឋានចាតុម្មហារាជិកាទៅទៀត ទើបហោះទៅកាន់ឋានតាវតឹង្ស ។ សក្កទេវរាជបានទតឃើញហើយមានសេចក្ដីត្រេកអរណាស់ បានយាងព្រះបាទមន្ធាតុឲ្យគ្រប់គ្រងរាជ្យក្នុងទីនោះយ៉ាងត្រកាលក្សេមក្សាន្តព្រះហឫទ័យ ។

ព្រះបាទមន្ធាតុសម្រាកសម្រាន្តក្សាន្តព្រះទ័យដោយសម្បត្តិទិព្វក្នុងទេវស្ថាន រហូតដល់ព្រះឥន្ទ្រច្យុតអស់ព្រះជន្ម ជាតំណតគ្នាសាមសិបប្រាំមួយព្រះអង្គ ។ ព្រះបាទមន្ធាតុកើតមានសេចក្ដីប្រាថ្នាថា ការគ្រប់គ្រងរាជ្យដោយការចែករំលែកសម្បត្តិពីព្រះឥន្ទ្រដូច្នេះមិនអស្ចារ្យទេ បើធ្វើគុតសក្កទេវរាជហើយគ្រប់គ្រងរាជ្យតែម្នាក់ឯងទើបបានអស្ចារ្យ ។ គ្រាន់តែមានអកុសលចេតនាគឺ តណ្ហាកើតឡើងដូច្នោះ ក៏ត្រូវអស់ឫទ្ធិអំណាច មិនអាចគង់នៅក្នុងឋានតាវតឹង្សទៀតបាន ក៏ត្រូវច្យុតទ្រុឌទ្រោមធ្លាក់ចុះមក ចំកណ្ដាលឧទ្យាននៃឋានមនុស្សវិញ ។ នាយឧទ្យានបាលបានឃើញហើយក៏ស្ទុះស្ទាវម្ទីម្ទារត់ទៅទូលព្រះរាជាជារាជត្រកូលឲ្យដឹង ។ ព្រះរាជា

ជាបរិវារទាំងប្រាំបីម៉ឺនបួនពាន់ កាលបើជ្រាបហើយ មានសេចក្ដីត្រេកអរណាស់ នាំគ្នាយាងចូលទៅកាន់ឧទ្យាន រៀបចំចាត់ចែងសយនាសនៈយាងព្រះបាទមន្ធាតុឲ្យឡើងគង់ ។ កាលបើបានឡើងគង់លើសយនាសនៈហើយ ព្រះបាទមន្ធាតុទ្រង់មានព្រះសូរសីហនាទយ៉ាងនេះថា ៖ **តណ្ហា គឺសេចក្ដីប្រាថ្នារបស់សត្វលោកមិនមានទីបំផុតឡើយ** ! ។ មានព្រះវាចាបានត្រឹមតែប៉ុណ្ណោះ ក៏អស់ព្រះជន្មទៅកាន់បរលោកតាមយថាកម្ម ។

សេចក្ដីរៀបរាប់ប្រវត្តិព្រះរាជា គ្រាន់តែជាការបញ្ជាក់បន្ថែមឲ្យឃើញថា សត្វលោកមានតែសេចក្ដីខ្វះខាត មិនចេះឆ្អែត ជាទាសកររបស់តណ្ហាពិត ។

# បំណុលជីវិត

## បទពាក្យប្រាំពីរ

សព្វសត្វកើតមកក្នុងលោកា សុទ្ធជាទាសាតណ្ហាពិត
ខ្វះខាតជានិច្ចក្នុងដួងចិត្ត រស់មួយជីវិតមិនដែលគ្រប់ ។
តណ្ហានាំចិត្តសត្វស្ទុះទៅ ឥតដែលស្ងៀមនៅទាំងថ្ងៃយប់
អន្ទះអន្ទែងរវែងមិនស្ងប់ ពុំចេះស្គាល់ស្កប់គ្រប់ឡើយណា។
ជីវិតដែលឋិតក្នុងលោកិយ ទោះទាំងប្រុសស្រីមនុស្សទេវតា
ឥន្ទ្រព្រហ្មយមយក្សអមនុស្សា ជាខ្ញុំតណ្ហាប្រាកដស្ដែង ។
មិនដែលសត្វណាថាធួនល្មម យល់ព្រមគ្រប់គ្រាន់សម្បត្តិឯង
តណ្ហានាំចិត្តឲ្យគិតក្លែង ប្រណាំងប្រជែងខុសធម្មា ។
ព្រះរាមខំធ្វើសឹកសង្គ្រាម ប្រាថ្នាទាមទារនាងសីតា

ក្រុងរាពណ៍ជាយក្សអសុរា ក្លាយជាទាសាតណ្ហាពិត ។
ហ៊ានលបលួចយកប្រពន្ធគេ ប្រលោមលួងស្នេហ៍ដោយងងឹត
តណ្ហាជារនាំងបាំងចិត្ត ឲ្យហ៊ានប្រព្រឹត្តខុសសីលធម៌ ។
សង្គ្រាមសម្លាប់កាប់ប្រហារ រវាងមនុស្សាដែលបង្ក
រំលោភឈ្លានពាននាំវឹកវរ ជាទាសករនៃតណ្ហា ។
រីការប្រឡងខំប្រកួត បង្អួតសម្រស់ឲ្យអស្ចារ្យ
ប្រុសស្អាតស្រីល្អបវរកញ្ញា ទាំងមុខវិជ្ជានិងយសស័ក្តិ ។
អួតជាតិត្រកូលសម្បត្តិទ្រព្យ សមល្អគួរគាប់ជាប់តាមថ្នាក់
ព្រមទាំងធនធានមានមាសប្រាក់ អួតអាងវណ្ណៈព្រោះតណ្ហា ។
កុំថាឡើយត្រឹមជាតិជាមនុស្ស ទោះបីកោសីយ៍ព្រះឥន្ទ្រា
ជាធំមានឫទ្ធិពិតអស្ចារ្យ គ្រប់គ្រងទេវតាសួគ៌ាឋាន ។
ក៏ត្រូវធ្លាក់ចុះក្នុងអំណាច មិនអាចយកជ័យជំនះបាន
តណ្ហាមោហ៍បាំងចិត្តសន្តាន ត្រូវស្នេហ៍កល្យាណអសុរធីតា ។
ព្យាយាមធ្វើសឹកសង្គ្រាមជ័យ ដណ្តើមឈ្នះដៃព្រោះតណ្ហា
ប្រកួតអួតអាងឫទ្ធិចេស្តា ឥតមានចិន្តាអរអាខ្មាស ។
សត្វលោកសុទ្ធតែជាទាសៈ សម្តែងបញ្ជាក់ឲ្យយល់ច្បាស់
ជាខ្ញុំតណ្ហាប្រាកដណាស់ ចិត្តខ្វះកន្លះមិនចេះឆ្អែត ៕

# ចៅហ្វាយនាយ គឺតណ្ហា

## បទព្រហ្មគីតិ

ពេលកើតមកដៃក្តាប់ ដល់ពេលស្លាប់ទៅដៃលា
ឃើញផ្ទាល់នឹងនេត្រា ខ្វះបញ្ញាការយល់បាន ។
កើតមកមួយជីវិត ចិត្តខិតខំគ្រប់ ៗ ប្រាណ
នឿយហត់តតស្រាកស្រាន្ត ដើម្បីបានផ្គាប់តណ្ហា ។
មិនដែលសត្វណាគ្រប់ ទាំងថ្ងៃយប់តាមបញ្ជា
លុះដល់ពេលមរណា លាហត្ថាទៅទទេ ៕



# អវសានកថា

**កាល**បានស្ដាប់សេចក្ដីអធិប្បាយ ធម្មទោសទាំងបួនប្រការ ឃើញថាសត្វលោក ហាក់បីដូចជារស់នៅទ្រាំចាំតែសេចក្ដីស្លាប់ បើដូច្នោះការរស់នៅរបស់សត្វទាំងឡាយមានប្រយោជន៍អ្វីទៅ, តើយើងត្រូវធ្វើដូចម្ដេចដើម្បីគេចវេះ ជៀសឲ្យផុតរត់ឲ្យរួចអំពីហេតុការណ៍ទាំងនោះបាន ?

យើងបានអានបានស្ដាប់មកហើយ តាំងពីខាងដើមរហូតដល់ចប់ យើងអាចជ្រាបបានថា សេចក្ដីនៃធម្មទ្ទេស ជាព្រះពុទ្ធដីការបស់ព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គសម្ដែងបញ្ជាក់ពីសេចក្ដីពិតនៃជីវិតសត្វលោក ដើម្បីឲ្យយល់ស្គាល់អំពីដំណើរជីវិតពិតជាប្រព្រឹត្តទៅ យ៉ាងដូច្នោះដែលមិនអាចប្រកែកបាន ។

• • •

ដូចជាធម្មទេសទីមួយ បញ្ជាក់ឲ្យឃើញអំពីភាពមិនទៀង រូបរាងកាយសព្វសត្វទាំងឡាយ ចាប់តាំងពីកកើតមក ត្រូវរំកិលខិតជិតចូលកាន់ ជរា ព្យាធិ មរណៈ នៅទីបំផុតត្រូវរលត់សូន្យសោះអស់ទៅ គ្មានអ្វីឲ្យនៅសល់បានពីបំណែកនៃរាងកាយនេះសូម្បីតែបន្តិចបន្តួចឡើយ ។ កាលបើស្តាប់រឿយ ៗ ពិចារណាឲ្យកើតបញ្ញា រមែងមានចិត្តសង្វេគតក់ស្លុត ឃើញទុក្ខទោសពិតរបស់ជីវិត នាំឲ្យមានការនឿយណាយ បន្ទោបង់នូវការស្រវឹងវង្វេងមិនប្រកាន់ស្អិតជាប់ចិត្ត ងងុលងប់ជ្រុលជ្រប់នឹងរាងកាយជីវិតនេះហួសពេក រហូតដល់ទៅភ្លាំងភ្លេចស្មារតីឥតបានធ្វើអ្វី ដើម្បីជាគុណជាប្រយោជន៍សោះទេ ។

សត្វលោកកាលបើគ្មានចិត្តសង្វេគ ឥតឃើញទុក្ខទោសនៃជីវិត តែងតែងឹតវង្វេង មានះលើកកម្ពស់តម្កើងយសស័ក្តិឫទ្ធិអំណាច កាចឃោរឃៅអួតអាងមើលងាយអ្នកដទៃ ខ្វះសេចក្តីមេត្តាករុណា គ្មានគំនិតរិះគិតកែបញ្ហាទោសកំហុសរបស់ខ្លួន ព្រមទាំងមិនអាចរកវិធីរំដោះអាត្មាចេញចាកឲ្យផុតពីទុក្ខទោសបានទេ ។

ព្រះសាស្តាសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង កាលនៅជាព្រះបរមពោធិសត្វ បានយោនយកកំណើតជាសុមេធបណ្ឌិតក្តី ជាកសិព្រាហ្មណ៍ក្តី ក្នុងដំណើរជីវិតព្រះអង្គសុទ្ធតែមានចិត្តសង្វេគពិចារណាយល់ច្បាស់ពីទុក្ខទោស និងព្យាយាមរំដោះជីវិតឲ្យផុតអំពីទុក្ខទោសទាំងនោះបាន ។

ធម្មទេសទីពីរ ទីបី ក៏គង់មានន័យប្រហាក់ប្រហែលនឹងធម្មទេសទីមួយ ដែលមិនពិបាកយល់ណាស់ណាទេ ព្រោះតែមាន

សភាពមិនទៀង ការបែកធ្លាយរលត់អស់សោះសូន្យនៃជីវិតរាងកាយនេះហើយ ទើបមិនមានអ្វីជាគ្រឿងការពារ ជាទីជ្រកកោនពឹងពួន បើអត្តភាពគឺរាងកាយខ្លួនឯងមិនអាចថែរក្សាការពារបាន តើទៅសង្ឃឹមមានពំនឹងពឹងលើរបស់ក្រៅខ្លួននោះដូចម្ដេចនឹងបានទៅ គឺត្រូវតែលះរបស់ទាំងពួងហើយទៅដូច្នេះឯង ។ ត្រង់ចំណុចនេះទ្រង់បញ្ជាក់ឲ្យឃើញគុណទោសរបស់ទ្រព្យសម្បត្តិទាំងឡាយ កាលបើសត្វលោកមានសេចក្ដីប្រាថ្នាខ្លាំងក្លាចំពោះទ្រព្យសម្បត្តិ ក៏រមែងធ្វើចិត្តឲ្យគិតស្វះស្វែងអន្ទះអន្ទែង តក់ក្រហល់ក្រវល់ក្រវាយ ក្នុងការប្រាថ្នាចង់ឲ្យបានស្របបំណងរបស់ខ្លួន ។ ការដែលបានសមបំណងក្ដី មិនសមបំណងក្ដី បានមកហើយជាប់ជំពាក់ចិត្តគិតឃុំគ្រងរក្សាការពារ ដោយការតក់ស្លុតរន្ធត់ខ្លាច រអារអែងក្រែងបារម្ភព្រួយភ័យយប់ថ្ងៃ ចំពោះវត្ថុរបស់នោះក្ដី ទាំងនេះសុទ្ធតែធ្លាក់ចុះជាទាសកររបស់តណ្ហា " ខទី ៤ " ព្រោះតែងនាំឲ្យមានការទុក្ខព្រួយនៅមិនបានស្រណុកឥតបើមានសេចក្ដីសុខទាំងកាយចិត្ត ដូចជាអ្នកជំពាក់បំណុលអ្នកដទៃ យប់ថ្ងៃដើរដេកអង្គុយរមែងឥតបានសុខកាយសប្បាយចិត្តឡើយ ។ អ្នកមានព្រេងភ័ព្វ កើតមកមានទ្រព្យគាប់តាមប្រាថ្នា កាលបើយកទ្រព្យសម្បត្តិទៅចាយវាយប្រើប្រាស់បំពេញចំណង់ចំណូលចិត្តរបស់ខ្លួនខាងផ្លូវខុស ទាំងអស់នេះសុទ្ធតែជាទោស ឈ្មោះថាបានបំផ្លាញជាតិកំណើតខ្លួន ដោយសារតែទ្រព្យសម្បត្តិនោះទៅវិញ ។

ចុះបើទ្រព្យសម្បត្តិរកបានមកក៏យកទៅមិនបាន ការខំស្វះ-ស្វែងរកទ្រព្យយប់ថ្ងៃ ថាមិនចេះឆ្អែតជាខ្ញុំតណ្ហា បើដូច្នេះមានតែកុំរក កុំធ្វើអ្វី នៅសោះអង្គើយព្រងើយហាក់ហីទៅ ទ្រាំរហូតដល់ថ្ងៃ

ស្លាប់មិនស្រួលទេឬ ? ។

ពុំមែនដូច្នោះទេ សូមស្តាប់ព្រះធម៌ហើយសូមកុំឲ្យច្រឡំ ព្រោះព្រះធម៌មានន័យជាសេចក្តីពិត អ្នកស្តាប់ហើយចូលចិត្តយល់តាមសេចក្តីពិត ដោយមានបញ្ញាពិចារណា រមែងមានពន្លឺភ្លឺស្វាងសាងចិត្តគំនិតឲ្យបានរឹងមាំ យល់ចំទៅតាមហេតុផលជាសច្ចធម៌ព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធ ពុំមែនហាមប្រាមមិនឲ្យរកមិនឲ្យរៀន មិនឲ្យហ៊ានធ្វើ ឬក៏មិនឲ្យចង់បានចង់មាននោះទេ ព្រះអង្គមានតែទូន្មានប្រៀនប្រដៅសត្វលោក ឲ្យយល់ស្គាល់ប្រយោជន៍ទាំងបីប្រការគឺ ប្រយោជន៍ក្នុងបច្ចុប្បន្ន ១, ប្រយោជន៍ក្នុងលោកខាងមុខ ១ និងប្រយោជន៍ដ៏ឧត្តមគឺព្រះនិព្វាន ១ ។ ប្រយោជន៍ទាំងបីប្រការនេះ ព្រះអង្គដាស់តឿនក្រើនរំឭកសត្វលោកឲ្យមានស្មារតី យប់ថ្ងៃព្យាយាមបំពេញធ្វើ ។ ជីវិតថ្វីដ្បិតតែមិនទៀងត្រូវបែកធ្លាយខ្ចាត់ខ្ចាយទៅក៏ពិតមែនហើយ តែនៅពេលជីវិតរស់នៅក៏ត្រូវតែព្យាយាមរៀនវិជ្ជាផ្លូវលោកផ្លូវធម៌ គឺការសិក្សាបំពេញកិច្ចការរកទ្រព្យសម្បត្តិទុកផ្គត់ផ្គង់បម្រុងជីវិត ព្រមទាំងចេះរក្សាការពារចំណេះដឹងភោគៈទាំងឡាយមិនឲ្យវិនាសទៅដោយប្រការផ្សេង ៗ និងឲ្យចេះស្គាល់ប្រមាណក្នុងការចាយវាយប្រើប្រាស់ បរិភោគទៅតាមសមត្ថភាពកម្លាំងទ្រព្យដែលខ្លួនរកបាន ដោយជៀសវាងមិនសេពគប់បាបមិត្តទៅប្រព្រឹត្តអបាយមុខ ជាហេតុនាំឲ្យវិនាសធនធាន មានតែការសេពគប់តែនឹងកល្យាណមិត្តប៉ុណ្ណោះ ដែលដឹកនាំគុណប្រយោជន៍ ។

ការព្យាយាមបំពេញប្រយោជន៍ក្នុងបច្ចុប្បន្នប៉ុណ្ណោះនៅមិនទាន់

គ្រប់ល្មមនៅឡើយទេ ព្រោះដូចយើងបានដឹងឮហើយក្នុងធម្មុទ្ទេស សត្វត្រូវលះចោលនូវអត្តភាពគឺរាងកាយនេះ ចោលនៅលើផែនដីនៃមច្ចុរាជ និងត្រូវលះរបស់ទាំងពួងទៅ ទាំងនេះបញ្ជាក់បានថាសត្វលោកមិនអាចយកអ្វីទៅបាន ទាំងទ្រព្យរបស់ជាប្រយោជន៍បច្ចុប្បន្ននេះ ។ កាលបើបានស្តាប់ធម្មុទ្ទេសហើយ មានសេចក្តីសង្វេគមិនប្រមាទឲ្យខាតបង់ប្រយោជន៍ ។ រាងកាយទ្រព្យសម្បត្តិ ពុំអាចពឹងពាក់ពំនាក់អាស្រ័យបាន ក្នុងពេលលះលោកនេះទៅដូច្នោះពិតមែនហើយ ទន្ទឹមនឹងការរស់នៅត្រូវកុំស្លុងគំនិត បណ្តោយចិត្តឲ្យជាប់ជំពាក់តែទ្រព្យសម្បត្តិ ភ្លាំងភ្លេចស្មារតីក្លាយជាទាសករមិនចេះឆ្អែតមានតែកង្វះខាតជានិច្ចជាកាលរហូតដល់ទៅវិញទទេនោះទេ ត្រូវព្យាយាមលៃលករកវត្ថុយកជាប់ទៅជាមិត្តជាទីពឹងប្រាស្រ័យ ដើម្បីកុំឲ្យខ្វះខាតផង កុំឲ្យកំព្រារងាតែឯកឯង ដោយការខំបំពេញប្រយោជន៍ក្នុងលោកខាងមុខទុកឲ្យមានជាប្រចាំគឺ ខំបណ្តុះសទ្ធាការជឿបាបបុណ្យគុណទោស កម្មផល ១, បំពេញសីលប្រាំ, សីលប្រាំបី, សីលដប់, ដោយការវៀរចាកបាបតាមផ្លូវកាយវាចា ១, ចាគៈ ការចែកចាយចំណាយទ្រព្យសម្បត្តិ តាមកម្លាំងដែលខ្លួនមានឲ្យទៅជាទាន ឬការខំដុសខាត់ជំរះចិត្តឲ្យបានបរិសុទ្ធផុតចាកកិលេសជាគ្រឿងសៅហ្មង ១, បញ្ញា ការពិចារណាឃើញទុក្ខទោសរបស់សង្ខារ មិនបណ្តោយចិត្តឲ្យជាប់ជំពាក់ថាជាអត្ត ១, ទាំងនេះចាត់ថាជាទ្រព្យជាប្រយោជន៍ សម្រាប់ជាទីពឹងទៅបរលោក ជាញាតិមិត្តជិតទៅមិនកំព្រារងាកណ្តោចកណ្តែងតែម្នាក់ឯង ។

ប៉ុន្តែប្រយោជន៍ក្នុងលោកនេះក្តី ប្រយោជន៍ក្នុងលោកខាងមុខក្តី សុទ្ធតែជាប្រយោជន៍ដែលឋិតនៅក្នុងវដ្តៈ ជាប់ដោយខ្សែអន្ទាក់

ចំណងនៃតណ្ហា នៅក្រោមសភាពអនិច្ចានាំទៅកាន់ភាពអស់ទៅសូន្យទៅ មិនអាចតាំងនៅតាមប្រក្រតីធម្មតា ។ សុខទុក្ខសើចយំលាយឡំគ្នា កើតចាស់ឈឺស្លាប់ក្នុងសំសារវដ្ដ មិនអាចកំណត់សេចក្ដីទុក្ខ និងរត់ឲ្យរួចចាកអាជ្ញាមច្ចុរាជបាន ។ សត្វដែលមានឧបនិស្ស័យខ្ពស់ រមែងមើលឃើញដឹងយល់អត្ថន័យព្រះធម៌ ដូចជាធម្មុទ្ទេសទាំងបួនប្រការ ជាពុទ្ធដីការបស់ព្រះអង្គ មានចិត្តនឿយណាយធុញទ្រាន់នឹងជីវិតដែលឋិតនៅក្នុងទុក្ខទោស មិនចេះអស់មិនចេះហើយ ទើបមានចិត្តគិតរំដោះជីវិតនេះចេញឲ្យផុតអំពីសភាពដដែល ៗ នេះ ដូច្នេះហើយបានជាព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់សម្ដែងពី បរមត្ថប្រយោជន៍គឺ ព្រះនិព្វាន ដែលឥតមានលោកាមិសៈ មិនជំពាក់ដោយចំណងតណ្ហា មិននៅក្រោមអាជ្ញាមច្ចុរាជ ។

ប្រយោជន៍ទាំងបីប្រការនេះ បានបង្ហាញសម្ដែងឲ្យសត្វលោកបានយល់ស្គាល់ចូលចិត្ត សត្វណាចូលចិត្តស្រឡាញ់ការកើតចាស់ឈឺស្លាប់ សត្វទាំងឡាយនោះបំពេញបានត្រឹមតែប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍លោកខាងមុខប៉ុណ្ណោះ មិនអាចបានលុះឆ្លុះយល់ដល់ប្រយោជន៍ដ៏ឧត្ដមបាន ប៉ុន្តែគ្រប់សព្វសត្វតែងរន្ធត់តក់ស្លុតស្លន់ស្លោរ នៅពេលជួបប្រទះភ័យវិបត្តិ គឺការឈឺចុកចាប់និងសេចក្ដីស្លាប់នេះឯង រមែងមានការធុញទ្រាន់នឿយណាយនឹងសភាពដដែលនេះ ជាហេតុឲ្យមានចិត្តគិតរកផ្លូវចេញចាកឲ្យបានផុតរត់ឲ្យបានរួច ដោយក្ដីសង្វេគតក់ស្លុតរន្ធត់ខ្លាច ដែលអាចឲ្យស្គាល់យល់ពីផលប្រយោជន៍ដ៏ឧត្ដមគឺ ព្រះនិព្វានជាក់ជាមិនខាន ។

ព្រះសិទ្ធត្ថរាជា បានលះបង់ព្រះមហេសី ព្រះរាជបុត្រជាទីស្រឡាញ់ពេញហឫទ័យ ព្រមទាំងរាជសម្បត្តិស្រីស្នំបរិវារ សៀងតូរ្យតន្ត្រី ចេញសាងផ្នួសរស់នៅក្នុងព្រៃ ព្យាយាមបតិបត្តិកំចាត់បង់កិលេស ញ៉ាំងចិត្តឲ្យថ្លាបរិសុទ្ធស្អាត បាននូវបញ្ញាជាពន្លឺ ទ្រង់ជ្រាបច្បាស់អរិយសច្ចធម៌ បានញាណជាសម្មាសម្ពោធិញ្ញាណមានព្រះនាមថ្មីជាព្រះសម្ពុទ្ធ ក៏ព្រោះតែព្រះអង្គមានសេចក្តីសង្វេគដោយបានឃើញរូបមនុស្សចាស់ ឈឺ ស្លាប់ ជ្រះថ្លាចំពោះភេទអ្នកបួស ។

ចំណែកព្រះ **រដ្ឋបាលត្ថេរ** លោកបានសម្តែងពន្យល់ដល់ព្រះបាទកោរព្យៈឲ្យបានជ្រាបថា ការដែលលោកចេញចាកផ្ទះទៅសាងផ្នួស ព្រោះបានយល់សេចក្តីពិតដែលព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ត្រាស់សម្តែង " **ធម្មទេសនបួនប្រការ** " លោកបានព្យាយាមបដិបត្តិដុតកម្តៅកិលេស រហូតរីងស្ងួតហួតហែងអស់បានសម្រេចជាព្រះអរហន្ត មានភាពជាបុគ្គលគ្រប់គ្រាន់ ពេញប្រៀបក្នុងជីវិតមិនមានសេចក្តីខ្វះខាត ទាំងឥតមានជាទាសៈនៃតណ្ហាទៀតឡើយទាំងនេះឈ្មោះថាលោក មានឥស្សរៈភាពលើជីវិត លែងប្រព្រឹត្តនៅក្រោមអំណាចតណ្ហា ឈ្នះអាជ្ញាមច្ចុរាជ ឥតភ័យខ្លាច មិនអន្ទះអន្ទែងតក់ក្រហល់ខ្វល់ខ្វាយ ក្តៅក្រហាយស្រេកឃ្លាន ដោយចំណីនៃកាមារម្មណ៍ និងភោគសម្បត្តិទាំងឡាយ ទាំងបានទម្លាយកំពែងវដ្តៈឲ្យបាក់បែកហែកដំបូលអវិជ្ជា ដែលប្រក់ហ៊ុមព័ទ្ធបិទបាំងទាំងបានកំចាត់ភាពងងឹតឲ្យវិនាសខ្ទាត់ខ្ទាយទៅ បន្សល់នៅតែភាពភ្លឺស្វាងក្នុងចិត្ត ឥតវិលត្រឡប់កើតក្នុងភពទៀតឡើយ ។

សេចក្ដីអធិប្បាយបញ្ជាក់ន័យ " **ធម្មទោសបួនប្រការ** " និដ្ឋិតាសមគួរតាមកាលវេលានឹងបញ្ចប់ សព្វសេចក្ដីនៃព្រះបាលីធម៌ត្រឹមតែប៉ុណ្ណេះ ។ ដោយវិរិយៈសេចក្ដីព្យាយាមក្នុងការសរសេរវាយពុម្ពអក្សរ រៀបចំឲ្យបានជាសៀវភៅដើម្បីចែកចាយចំណាយជាធម្មទាន សូមឲ្យយើងខ្ញុំព្រះករុណាទាំងឡាយ, ព្រះករុណាម្ចាស់, ព្រមទាំងលោក-អ្នកអានទាំងអស់ បានចាក់ធ្លុះយល់ដឹងរសព្រះធម៌ រួមទាំងសត្តនិករ គ្រប់ប្រភេទគ្រប់សញ្ជាតិ មានដំណើរឃ្លាតចាកទុក្ខទាសៈនៃតណ្ហា ឆ្លងចាកត្រើយសំសារវដ្ដ ឆ្ពោះប្រាកដកាន់អមតស្ថានគឺ ព្រះនិព្វាន កុំបីក្លាយជាបការដទៃឡើយ . . . ។

**សូមអនុមោទនា ធម្មទាន**!!!



# កម្រងកំណាព្យ

# ស្ដាប់ពិចារណាកើតបញ្ញា

## បទពាក្យប្រាំពីរ

ស្ដាប់ធម្មទេ្ទសបួនប្រការ ដែលព្រះសាស្ដាទ្រង់សម្ដែង
បាននូវពន្លឺយ៉ាងជាក់ទែង ពុទ្ធសាសន៍ពោលថ្លែងពីជីវិត។
ពន្យល់ប្រាប់ដល់សព្វសត្វលោក កំពុងងុយងោកជោកជាប់ចិត្ត
ឥតបានដឹងយល់ស្គាល់ភាពពិត ឋិតក្នុងងងឹតអវិជ្ជា ។
ប្រកាន់ជាប់ស្អិតជីវិតកាយ ភោគៈទាំងឡាយដោយមោហា
អំណាចយសស័ក្ដិផងនានា ស្វាមីភរិយានិងកូនចៅ ។
មាតាបិតារួមតាដូន មានទាំងបងប្អូនញាតិពង្សផៅ
ទាំងភពភូមិឋានបានឋិតនៅ មិនចង់ឃ្លាតទៅសោះឡើយណា ។
តែព្រះពុទ្ធអង្គទ្រង់សម្ដែង បញ្ជាក់ច្បាថ្លែងដោយទេសនា
សត្វលោកឋិតក្នុងភាពអនិច្ចា នាំកាន់ជរាព្យាធិស្លាប់ ។
ពុំមានអំណាចអាចការពារ ជីវិតសត្តាជួបវិបត្តិ
រាងកាយត្រូវតែឈឺចុកចាប់ ទីបំផុតស្លាប់គេចមិនបាន ។
ឥតមានជម្រកជ្រកពឹងពួន សម្ងំលាក់ខ្លួនឲ្យសុខសាន្ត
សូម្បីសម្បត្តិទាំងភូមិឋាន ខំរកឲ្យបានផ្គាប់តណ្ហា ។
ក៏ត្រូវលះចោលលើផែនដី ពុំអាចយកអ្វីជាប់កាយា
ត្រូវលះសាកសពគ្រប់អង្គា យាត្រាទៅតាមយថាកម្ម ។
នៅពេលបានស្ដាប់ធម្មទេ្ទស ព្រះអង្គទេសនាជាបណ្ដាំ
ស្ដាប់ហើយឮហើយកំណត់ចាំ ន័យព្រះសទ្ធម្មកើតបញ្ញា ។

ដកចិត្តមិនឲ្យជាប់ជំពាក់ កាត់ខ្សែអន្ទាក់គឺតណ្ហា
ព្យាយាមរត់គេចពីសេនា របស់មច្ចុមារទាំងយប់ថ្ងៃ ។
យកសីលសមាធិបញ្ញា មាគ៌ាបដិបត្តិកំចាត់ភ័យ
ឥតមានប្រមាទខាតស្មារតី ទិវារាត្រីលៃប្រតិបត្តិ ។
កំចាត់ឲ្យអស់អវិជ្ជា កិលេសតណ្ហាព្យាយាមកាត់
មិនស្តាយស្រណោះសំសារវដ្ត កំណត់កត់ដៅផ្លូវចាកភព ។
មានព្រះនិព្វានជាអារម្មណ៍ យល់ឥតច្រឡំចំឋានស្ងប់
ដើរដល់ចុងផ្លូវត្រូវបញ្ចប់ ឥតវិលត្រឡប់កើតទៀតឡើយ ។
នេះទើបឈ្មោះថាឈ្នះសេនា ព្រមទាំងមច្ចុមារទាំងអស់ហើយ
ជីវិតឆ្លងផុតឆ្ពោះដល់ត្រើយ នេះជាចម្លើយធម្មទោស ៕

# បុណ្យជាមិត្តជិតជាប់ប្រាណ

## បទព្រហ្មគីតិ

ត្រូវព្យាយាមឲ្យហើយ កុំស្មៀមឡើយក្នុងថ្ងៃនេះ
ដុសខាត់លះកិលេស មិនប្រហែសចាំថ្ងៃស្អែក ។
តើអ្នកណាដឹងថា កាលវេលាដែលត្រូវបែក
ថ្ងៃនេះឬថ្ងៃស្អែក យើងមិនអាចប្រកែកបាន ។
អាជ្ញាមច្ចុរាជ មានអំណាចមិនអាចស្មាន
ព្រមទាំងពលទាហាន តាមបៀតបៀននគរកាយ ។
ធ្វើឲ្យព្រះចិត្តរាជ អស់អំណាចរត់ខ្វាត់ខ្វាយ
បរិវារផងទាំងឡាយ បែកចេញឆ្ងាយឃ្លាតពីគ្នា ។
រូបកាយត្រូវបែកធ្លាយ ឆ្អឹងរោយរាយលើពសុធា
ជីវិតត្រូវមរណា សូន្យសង្ខារចាកលោកិយ ។
តើយកអ្វីទៅបាន ទាំងកាយប្រាណក៏ឥតន័យ
ក្លាយជាធូលីដី ជាចំណីសត្វជន្លេន ។
មិនត្រូវនៅប្រហែស ថ្ងៃយប់នេះធ្វើបុណ្យទាន
ចំណាយទ្រព្យធនធាន ទុកឲ្យបានជាខ្លឹមសារ ។
ទាំងកាយចិត្តសោតទៀត ព្យាយាមឆ្លៀតតាមវេលា
ចម្រើនសីលភាវនា និងបញ្ញាឲ្យកើតមាន ។
ជីវិតពិតនៅរស់ ទើបឈ្មោះថាជាអ្នកបាន
ជួយស្ទួយលើកចិត្តប្រាណ ចាត់ឲ្យមានជាខ្លឹមសារ ។

កាយទ្រព្យឥតខ្លឹមពិត   ជនបណ្ឌិតមានបញ្ញា
ធ្វើកាយនិងភោគា   មានខ្លឹមសារប្រើការបាន ។
ទោះរស់នៅមួយថ្ងៃ   មានតម្លៃមិនអាចស្មាន
សាងកុសលផលទាន   ឲ្យកើតមានកុំប្រមាទ ។
ទាំងជីវិតរស់នៅ   ឬស្លាប់ទៅមិនបង់ខាត
ជីវិតមិនអនាថ [១]   បុណ្យជាញាតិមិត្តតាមទៅ ៕

(១) អនាថ អៈនាត សំ. បា. ( គុ. ) (< ន> អ "មិន, ពុំ, ឥត" + នាថ "ទីពឹង, ពំនាក់" ) ដែលឥតទីពឹង, ឥតពំនាក់ ។ ខ្មែរប្រើសំដៅសេចក្ដីថា "ណែលណោល; កណ្ដែងកណ្ដោច, ត្រមោច; គួរឲ្យអាណិតពេក, គួរឲ្យអាសូរពេក; គួរឲ្យសង្វេគ, ឲ្យស្លុតចិត្ត" : អនាថចិត្ត ចិត្តអាសូរពេក, ចិត្តខ្លោចផ្សា; ចិត្តសង្វេគ ។

# ពេលកើតមកដៃក្ដាប់ ពេលស្លាប់ដៃលា

## បទពាក្យប្រាំពីរ

**កាល**កើតចេញពីផ្ទៃមាតា ទាំងអស់គ្រប់គ្នាហត្ថាក្ដាប់
ពេលវ័យឈានចូលចាស់ឈឺស្លាប់ ហត្ថាធ្លាប់ក្ដាប់បែរជាលា ។
ន័យនេះបញ្ជាក់ឲ្យយល់ច្បាស់ ប្រុសស្រីក្មេងចាស់គ្រប់អាត្មា
គួរកើតសង្វេគពីរូបា កុំមានចិន្ដាឈ្លក់វង្វេង ។
នៅស្រវឹងនឹងជីវិតវ័យ ភ្លាំងភ្លេចស្មារតីថាខ្លួនក្មេង
ជំពាក់ជាប់ចិត្តរូបខ្លួនឯង នៅក្មេងមិនចាស់ឥតរោគា ។
កុំនៅប្រហែសឈ្លក់វង្វេង អំណាចតំណែងស័ក្តិយសា
ទាំងជាតិត្រកូលរួមភោគា ជាប់ស្អិតគិតថាជាអត្តា ។
សត្វលោកត្រូវលះរបស់ទៅ បន្សល់ទុកនៅក្នុងលោកា
សូម្បីរាងកាយនៃអាត្មា ក៏គ្មានសត្វណាអាចយកបាន ។
បន្សល់សាកសពទុកឲ្យនៅ ញាតិមិត្តហែទៅឈាបនដ្ឋាន
បញ្ចុះបូជារួចវិលថ្កាន មកលំនៅឋានលែងអាល័យ ។
តើអ្នកស្លាប់ទៅយកអ្វីបាន សូម្បីកាយប្រាណក៏ឥតន័យ
កើតមកម្នាក់ ៗ ខំក្ដាប់ដៃ ដល់កាលនឹងក្ស័យដៃទទេ ៕

**អជ្ជេវ កិច្ចមាតប្បំ កោជញ្ញា មរណំ សុវេ**
**នហិនោ សង្គរន្តេន មហាសេនេន មច្ចុនា** (១) ។

**ការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ ។**

# កុំចាំថ្ងៃស្អែក

## បទពាក្យប្រាំបួន

ត្រូវព្យាយាម	កុំនៅស្ងៀម	ក្នុងថ្ងៃនេះ
គាស់រំលើង	កកាយប៉ើង	ភ្លើងកិលេស
ខំពន្លត់	គ្រប់សង្កត់	កុំឲ្យឆេះ
មិនប្រហែស	ធ្វេសរង់ចាំ	ដល់ថ្ងៃស្អែក ។
តើនរណា	អាចដឹងបាន	ស្ថានជីវិត
ប្រាកដពិត	ជាយ៉ាងណា	វេលាស្អែក
ការតទល់	របស់យើង	នឹងមច្ចុរាជ
មានអំណាច	សាហាវកាច	មិនអាចបាន ។

(១) គម្ពីរសុត្តន្តបិដក មជ្ឈិមនិកាយ
ឧបរិបណ្ណាសកៈ វិភង្គវគ្គ ភទ្ទេករត្តសូត្រ

# សមាសភាពចូលរួម

១. លោក វ៉ាត សុគន្ធ

២. លោក វ៉ាត តារា ( ទីទី )

៣. លោក វ៉ាត ម៉ូលីវណ្ណា

៤. កញ្ញា វ៉ាត ធារីយ៉ា



# នាមពុទ្ធបរិស័ទ

## មានសទ្ធាជ្រះថ្លាបានបរិច្ចាគបច្ច័យដើម្បីបោះពុម្ព

## សៀវភៅ " ធម្មទ្វេស ៤ យ៉ាង " ចែកជាធម្មទាន

. ឧបាសក **ពេជ្រ សារឿម** និងឧបាសិកា **សិម ចាន់ដារា**
. ឧបាសក **ម៉ិញ សាវ៉ាន** និងឧបាសិកា **សិម ចាន់ធូរ៉ា**
. ឧបាសក **ហ៊ិម ឆាន់** និងឧបាសិកា **សាមិត សោភ័ណ**
. លោក **នូ ស៊ីយឿន** និងអ្នកស្រី **លី សុតី**
. លោក **ឱប ច័ន្ទា** និងអ្នកស្រី **លៀម សុភាព**
. លោក **វ៉ាត តិរក្ស** និងអ្នកស្រី **មៀច វណ្ណា**





# អត្តភាពគឺរាងកាយ រមែងតែបែកធ្លាយទៅ

**( បទពាក្យប្រាំបី )**

ភាជន៍ដីដែលនាយស្មូនឆ្នាំងធ្វើហើយ
ឋិតមិនយូរឡើយតែងបែកធ្លាយទៅ
តូចធំឆៅឆ្អិនមិនបានតាំងនៅ
រមែងតែងត្រូវវិនាសយ៉ាងណា ។
រីឯរូបកាយជីវិតសព្វសត្វ
តែងជួបវិបត្តិនៅក្នុងលោកា
ទោះកើតផ្សេងគ្នាភពឋានទីណា
មច្ចុរាជប្រហារគេចមិនរួចឡើយ ៕

* ដោយឧបាសក **មិញ សាវ៉ាន**

## សម្រាប់ចែកជាធម្មទាន